ហាមលក់
កម្មសិទ្ធិរបស់រដ្ឋ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងអប់រំ យុវជន និងកីឡា

# ទេសចរណ៍

## ១១





នាយកដ្ឋានអភិវឌ្ឍកម្មវិធីសិក្សា
២០១៩

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងអប់រំ យុវជន និងកីឡា**
**លេខ:** ៩៧៣ **អយក.** ប្រក

# ប្រកាស
## ស្ដីពី
## ការអនុញ្ញាតឱ្យបោះពុម្ពផ្សាយសៀវភៅ
## «ទេសចរណ៍ ថ្នាក់ទី១១»
## រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០១ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការបង្កើតក្រសួងអប់រំ យុវជន និងកីឡា
- បានឃើញអនុក្រឹត្យលេខ ១៥៦ អនក្រ.បក ចុះថ្ងៃទី១៨ ខែកក្កដា ឆ្នាំ២០១៦ ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងអប់រំ យុវជន និងកីឡា
- យោងសេចក្ដីសម្រេចលេខ ១១ អយក.សសរ. ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០១៦ របស់ក្រសួងអប់រំ យុវជន និងកីឡា ស្ដីពីប្រព័ន្ធអនុម័តសៀវភៅសិក្សា និងសម្ភារឧបទេស
- យោងរបាយការណ៍ស្ដីពីដំណើរការនៃការអភិវឌ្ឍសៀវភៅសិក្សាគោលមុខវិជ្ជាទេសចរណ៍ថ្នាក់ទី១១ ចុះថ្ងៃសុក្រ ៦កើត ខែពិសាខ ឆ្នាំច សំរិទ្ធិស័ក ព.ស.២៥៦២ ត្រូវនឹងថ្ងៃទី២០ ខែមេសា ឆ្នាំ២០១៨
- តាមសំណើរបស់ប្រធានក្រុមប្រឹក្សាអនុម័តសៀវភៅសិក្សា និងសម្ភារឧបទេស

**សម្រេច**

ប្រការ ១ - អនុញ្ញាតឱ្យបោះពុម្ពផ្សាយសៀវភៅ «ទេសចរណ៍ ថ្នាក់ទី១១» ដែលជាស្នាដៃនិពន្ធ និងរៀបរៀងរបស់នាយកដ្ឋានអភិវឌ្ឍកម្មវិធីសិក្សា ដើម្បីប្រើប្រាស់ជាឯកសារជំនួយ ក្នុងការរៀន និងបង្រៀន នៅតាមសាលារៀនមធ្យមសិក្សាចំណេះទូទៅក្នុងព្រះរាជាណាចក្រកម្ពុជា។

ប្រការ ២ - អគ្គនាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ អគ្គនាយកដ្ឋានអប់រំ នាយកដ្ឋានអភិវឌ្ឍកម្មវិធីសិក្សា និងនាយកដ្ឋានមធ្យមសិក្សាចំណេះទូទៅ មន្ទីរអប់រំ យុវជន និងកីឡារាជធានី ខេត្ត ការិយាល័យអប់រំ យុវជន និងកីឡាក្រុង ស្រុក ខណ្ឌ និងសាលារៀនមធ្យមសិក្សាចំណេះទូទៅមានភារកិច្ចអនុវត្តប្រកាសនេះ។

ថ្ងៃ[illegible] ខែ[illegible] ឆ្នាំច សំរិទ្ធិស័ក ព.ស.២៥៦២
រាជធានីភ្នំពេញ ថ្ងៃទី២៩ ខែ មិថុនា ឆ្នាំ២០១៨

**បណ្ឌិតសភាចារ្យ ហង់ ជួន ណារ៉ុន**

កន្លែងទទួល:
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ទីស្ដីការគណៈរដ្ឋមន្ត្រី
  "ដើម្បីជូនជ្រាបជាព័ត៌មាន"
- ដូចប្រការ២
- ឯកសារ-កាលប្បវត្តិ.អកស.

# អារម្ភកថា

ក្នុងរយៈពេលប្រមាណពីរទសវត្សរ៍កន្លងមកនេះ កម្ពុជាមានសុខសន្តិភាព ស្ថិរភាពនយោបាយ សន្តិសុខ សណ្តាប់ធ្នាប់ពេញលេញ និងមានការអភិវឌ្ឍរីកចម្រើនលើគ្រប់វិស័យ ក្នុងនោះវិស័យទេសចរណ៍មានការរីកចម្រើនគួរជាទីមោទនៈ។ វិស័យទេសចរណ៍ត្រូវបានរាជរដ្ឋាភិបាលកម្ពុជាចាត់ទុកជាមាសបៃតង និងជាការនាំចេញនៅនឹងកន្លែង។ វិស័យនេះចូលរួមអភិវឌ្ឍសេដ្ឋកិច្ច និងសង្គមតាមរយៈការបង្កើតប្រាក់ចំណូលជូនជាតិ បង្កើតការងារទាក់ទាញការវិនិយោគ និងចូលរួមកាត់បន្ថយភាពក្រីក្ររបស់ប្រជាពលរដ្ឋ។

ក្នុងបរិបទអាស៊ានឆ្នាំ២០១៨ ប្រទេសជាសមាជិកអាស៊ានបានទទួលទេសចរអន្តរជាតិចំនួន ១៣០លាននាក់ កើនឡើង៨.៤% ក្នុងនោះទេសចរផ្ទៃក្នុងអាស៊ានមានចំនួនប្រមាណ៤០%។ ទេសចរណ៍អាស៊ានបានបង្កើនចំណូលជូនជាតិប្រមាណ១២% នៃផលិតផលក្នុងស្រុកសរុប និងការងារប្រមាណជាង៤៥លាននាក់ក្នុងនោះការងារផ្ទាល់មានប្រមាណ១៣លាននាក់។

ផ្តើមចេញពីយុទ្ធសាស្ត្រ**ឈ្នះ-ឈ្នះ** របស់**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុនសែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា** នៅឆ្នាំ១៩៩៨ កម្ពុជាបានទទួលសុខសន្តិភាពពេញបរិបូរ ការបង្រួបបង្រួមជាតិ ស្ថិរភាពនយោបាយ សន្តិសុខ និងសុវត្ថិភាពសង្គមពេញផ្ទៃប្រទេស ដែលជាកត្តាមូលដ្ឋានសម្រាប់ការអភិវឌ្ឍលើគ្រប់វិស័យ។ រាជរដ្ឋាភិបាលកម្ពុជាបានស្តារមូលដ្ឋានសេដ្ឋកិច្ចសង្គម វប្បធម៌របស់ខ្លួនឡើងវិញ បន្ទាប់ពីត្រូវបានបំផ្លិចបំផ្លាញដោយសង្គ្រាមស៊ីវិលអូសបន្លាយ ដូចជាការអភិវឌ្ឍធនធានមនុស្ស ហេដ្ឋារចនាសម្ព័ន្ធ និងការអភិវឌ្ឍវិស័យសេដ្ឋកិច្ចផ្សេងៗទៀត ដោយត្រូវដោះស្រាយបញ្ហាប្រឈមនានារាប់មិនអស់។ នាពេលបច្ចុប្បន្ននេះ កម្ពុជាមានការរីកចម្រើនលើគ្រប់វិស័យ ដោយធានាបាននូវកំណើនសេដ្ឋកិច្ចជាមធ្យម ៧.៧% អត្រាគ្មានការងារធ្វើ និងភាពក្រីក្របានធ្លាក់ចុះ។ ជាពិសេស កម្ពុជាបានក្លាយពីប្រទេសដែលមានចំណូលទាប ទៅជាប្រទេសដែលមានចំណូលមធ្យមកម្រិតទាប។ សមិទ្ធិផលទាំងនេះ បានមកពីកិច្ចខិតខំ និងមាគ៌ាដឹកនាំដ៏ឈ្លាសវៃរបស់រាជរដ្ឋាភិបាលក្នុងការអភិវឌ្ឍជាតិលើគ្រប់វិស័យ ក្នុងនោះរួមមានវិស័យទេសចរណ៍ផងដែរ។

ជាក់ស្តែង កម្ពុជាបានទទួលទេសចរអន្តរជាតិចំនួន២៩ម៉ឺននាក់នៅឆ្នាំ១៩៩៨ និងមានកំណើនយ៉ាងឆាប់រហ័សរហូតដល់ជាង៦.២លាននាក់ និងទេសចរជាតិ១១.០៦លាននាក់ កើនឡើង១.៨% នៅឆ្នាំ២០១៨ ដែលនាំចំណូលសេដ្ឋកិច្ចប្រមាណ ៤៣៧៥លានដុល្លារអាមេរិក គឺប្រមាណ១៣%នៃផលិតផលក្នុងស្រុកសរុប។ ជាចក្ខុវិស័យនៅឆ្នាំ២០២០ វិស័យទេសចរណ៍របស់កម្ពុជាសង្ឃឹមថានឹងទទួលបានទេសចរអន្តរជាតិប្រមាណ៧.៥លាននាក់ និងឆ្នាំ២០៣០ប្រមាណ ១៥លាននាក់។

ដើម្បីឆ្លើយតប នឹងកំណើនទេសចរជាតិ និងអន្តរជាតិ នាពេលអនាគត ក្រសួងទេសចរណ៍បានរៀបចំ និងអនុវត្តគោលនយោបាយ ផែនការយុទ្ធសាស្ត្រ ក្នុងការអភិវឌ្ឍធនធានមនុស្សលើវិស័យទេសចរណ៍ឆ្នាំ២០១៧-២០២៥ តាមបង្គោលជាយុទ្ធសាស្ត្រដែលបានកំណត់ដូចខាងក្រោម៖

ឆ្នាំ២០២០ ក្រសួងទេសចរណ៍ និងភាគីពាក់ព័ន្ធត្រូវសហការចូលរួមបង្កើតការងារផ្ទាល់ ឱ្យបានប្រមាណ១លាននាក់ ហើយត្រូវជំរុញឱ្យអ្នកជំនាញយ៉ាងតិច៥០% ត្រូវមានវិញ្ញាបនបត្រ ឬសញ្ញាបត្របញ្ជាក់សមត្ថភាព ស្របតាមស្តង់ដាជាតិ និងអាស៊ាន តាមរយៈការបណ្តុះបណ្តាល ឬការវាយតម្លៃសមត្ថភាព។

ឆ្នាំ២០២៥ ក្រសួងទេសចរណ៍ និងភាគីពាក់ព័ន្ធត្រូវសហការចូលរួមបង្កើតការងារផ្ទាល់ឱ្យបានប្រមាណ១លាននាក់ និងត្រូវសម្រេចឱ្យបានយុទ្ធនាការ "បុគ្គលិកម្នាក់ ជំនាញមួយ" ពោលគឺជំរុញឱ្យអ្នកជំនាញទេសចរណ៍ទាំងអស់ ឱ្យមានវិញ្ញាបនបត្រ ឬសញ្ញាបត្របញ្ជាក់សមត្ថភាពស្របតាមស្តង់ដាជាតិ និងអាស៊ាន។

ឆ្នាំ២០៣០ ក្រសួងទេសចរណ៍ និងភាគីពាក់ព័ន្ធត្រូវសហការចូលរួមសម្រេចឱ្យបានគោលដៅអភិវឌ្ឍប្រកបដោយនិរន្តរភាពទី៤ "ធានាឱ្យបាននូវការអប់រំបណ្តុះបណ្តាលប្រកបដោយគុណភាពសមធម៌ និងបរិយាបន្ន ព្រមទាំងលើកកម្ពស់ឱកាសសិក្សាពេញមួយជីវិតដល់ជនគ្រប់រូប" និងគោលដៅអភិវឌ្ឍប្រកបដោយនិរន្តរភាពទី៨: "ជំរុញកំណើនសេដ្ឋកិច្ច និងការងារសមរម្យដល់ជនគ្រប់រូប" ក្នុងវិស័យទេសចរណ៍កម្ពុជា តាមរយៈការអភិវឌ្ឍមូលធនមនុស្ស ក្រោមបរិបទជាតិ និងតំបន់។

ដើម្បីឆ្លើយតបទៅនឹងតម្រូវការចាំបាច់ផ្នែកទេសចរណ៍ និងការយល់ដឹងជាសាធារណៈពីវិស័យទេសចរណ៍ ក្រសួងអប់រំ យុវជន និងកីឡាសហការជាមួយក្រសួងទេសចរណ៍ បានរៀបចំសៀវភៅទេសចរណ៍ថ្នាក់ទី១១ សម្រាប់សាលារៀនចំណេះទូទៅ។

សៀវភៅទេសចរណ៍ថ្នាក់ទី១១ ផ្តល់ឱ្យសិស្សនូវចំណេះដឹងមូលដ្ឋាន ពីវិស័យទេសចរណ៍យ៉ាងជ្រៅជ្រះសម្រាប់ស្រូបយកបទពិសោធន៍ល្អៗ ក្នុងការពង្រីកចំណេះដឹង និងបំណិនចាំបាច់ដើម្បីលើកកម្ពស់ជីវភាពរស់នៅប្រចាំថ្ងៃ ព្រមទាំងបង្កើនគុណភាព និងប្រសិទ្ធភាពក្នុងវិស័យអប់រំផងដែរ។

ក្រសួងអប់រំ យុវជន និងកីឡា និងក្រសួងទេសចរណ៍ សូមថ្លែងអំណរគុណ និងកោតសរសើរដល់ក្រុមការងារ ដែលបានរួមចំណែកបំពេញការងារនេះយ៉ាងសកម្ម យកអស់កម្លាំងកាយ ចិត្ត ប្រាជ្ញាស្មារតីកសាងឯកសារនេះឱ្យបានសម្រេចជាផ្លែផ្កាដ៏ថ្លៃថ្លានេះ។

ថ្ងៃ សុក្រ ២កើត ខែ [illegible] ឆ្នាំ កុរ ឯកស័ក ព.ស ២៥៦៣

រាជធានីភ្នំពេញ ថ្ងៃទី ២៧ ខែ [illegible] ឆ្នាំ២០១៩

| | |
|---|---|
| រដ្ឋមន្ត្រីក្រសួងទេសចរណ៍ | រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា |
| ថោង ខុន | បណ្ឌិតសភាចារ្យ ហង់ជួន ណារ៉ុន |

# អារម្ភកថា

សៀវភៅទេសចរណ៍ថ្នាក់ទី១១ បានចងក្រងឡើងស្របតាមកម្មវិធីសិក្សារបស់ក្រសួងអប់រំ យុវជន និងកីឡា ដោយមានការចូលរួមពីក្រសួងទេសចរណ៍ ដើម្បីជាជំនួយដល់សិស្សានុសិស្សផ្នែកមធ្យមសិក្សាទុតិយភូមិសម្រាប់រៀន និងគ្រូបង្រៀនមុខវិជ្ជាទេសចរណ៍។ សៀវភៅនេះបានផ្តល់ឱ្យសិស្សពីភាពប្លែកៗនៃវិស័យទេសចរណ៍ ដែលក្នុងនោះមានខ្លឹមសារសំខាន់ៗដូចជាៈ តំបន់ទេសចរណ៍ សក្តានុពលទេសចរណ៍ បរិស្ថាន និងសេវាកម្មទេសចរណ៍ ដែលគេបានអនុវត្តក្នុងវិស័យទេសចរណ៍នាពេលបច្ចុប្បន្ន។

សៀវភៅទេសចរណ៍មានទម្រង់ដូចខាងក្រោមៈ

- មេរៀននីមួយៗមានវត្ថុបំណងច្បាស់លាស់
- ខ្លឹមសារមេរៀនភ្ជាប់ដោយរូបភាព មេរៀនសង្ខេប និងសំណួរ ដែលជាជំនួយឱ្យសិស្សងាយយល់ និងចងចាំមេរៀនបាន។

គណៈកម្មការនិពន្ធសង្ឃឹមថា ឯកសារនេះនឹងក្លាយជាវិភាគទានក្នុងការបង្កើនប្រសិទ្ធភាពបង្រៀន និងរៀនផ្នែកទេសចរណ៍។ យើងខ្ញុំរីករាយ និងទទួលការរិះគន់ ការផ្តល់យោបល់ និងការកែលម្អពីសំណាក់អ្នកពាក់ព័ន្ធទាំងអស់ ក្នុងគោលបំណងធ្វើឱ្យសៀវភៅទេសចរណ៍ថ្នាក់ទី១១នេះកាន់តែល្អប្រសើរឡើងថែមទៀត។

**គណៈកម្មការនិពន្ធ**

## គណៈកម្មការគ្រប់គ្រង

ឯកឧត្តម អ៊ឹម កុច
ឯកឧត្តម ប៉ាក់ សុខុម
លោកជំទាវ ទន់ សាអ៊ឹម
ឯកឧត្តម ជា សែ
លោកបណ្ឌិត ម៉ុក សារ៉ុម
ឯកឧត្តម ណោប សាមុត
លោក ស៊ុន ប៊ុណ្ណា
លោក អោ សៀម

## គណៈកម្មការត្រួតពិនិត្យ

ឯកឧត្តម ជា សែ
ឯកឧត្តម ហ៊ាយ ភីរក្ស
ឯកឧត្តម ទ្រី ឈីវ
លោក ច្រឡឹង សុមេធា
លោក យ៉ឹន ធី
លោក មាន វ៉ាន់ដេត
លោក ឃឹម សារិន
លោកបណ្ឌិត គឹម ប៊ុនណារ៉ា
លោក ព្រំ វិបុល
លោក ពុទ្រា សោភ័ណ្ណារ៉ា
លោក ស្រី សំនិត
លោក កាំង សុខចំរើន
លោកស្រី អ៊ុក លក្ខិណា
លោកស្រី សុខ សុជាមុនី

## គណៈកម្មការនិពន្ធ

ឯកឧត្តម ហ៊ាយ ភីរក្ស
ឯកឧត្តម ទ្រី ឈីវ
លោកស្រី ហ៊ុយ ចន្ធូ
លោក ច្រឡឹង សុមេធា
លោក សូរ ច័ន្ទបូរី
លោក ឈឹម សុខជិន
លោកស្រី ទេព ប៉ុណ្ណារី
លោក សុខ វណ្ណា
លោក លឹម សុជាតិ
លោកបណ្ឌិត គឹម ប៊ុណ្ណារ៉ា
លោក ជា ច័ន្ទដារី
លោក ជួប រតនា
លោក សេង បូរមី

## គណៈកម្មការវាយកុំព្យូទ័រ និងរចនា

លោក សោមនស្ស ភិរម្យ
លោក ទុយ សម្បត្តិ

# មាតិកា

*មេរៀនទី១* **ការយល់ដឹងពីទេសចរណ៍** ..... ១
១. ការធ្វើដំណើរ ..... ១
២. និយមន័យទេសចរណ៍ និងទេសចរ ..... ២
៣. ប្រភេទទេសចរ ..... ២
*មេរៀនទី២* **គោលបំណងទេសចរណ៍** ..... ៥
១. គោលបំណងនៃការធ្វើដំណើរជាទេសចរណ៍ ..... ៥
២. មូលហេតុនៃការធ្វើដំណើរជាទេសចរណ៍ ..... ៥
៣. ប្រភេទនៃការធ្វើដំណើរជាទេសចរណ៍ ..... ៦
*មេរៀនទី៣* **តំបន់ទេសចរណ៍ និងសក្តានុពលទេសចរណ៍នៃព្រះរាជាណាចក្រកម្ពុជា** ..... ១២
១. ស្ថានភាពទូទៅ ..... ១២
២. តំបន់ទេសចរណ៍ ..... ១២
៣. សក្តានុពលទេសចរណ៍ ..... ១៧
*មេរៀនទី៤* **សេវាស្នាក់នៅទេសចរណ៍** ..... ២៦
១. និយមន័យ ..... ២៦
២. ប្រភេទសេវាកម្មស្នាក់នៅទេសចរណ៍ ..... ២៦
*មេរៀនទី៥* **សេវាអាហារ និងភេសជ្ជៈ** ..... ៣១
១. កម្រិតភោជនីយដ្ឋាន ..... ៣២
២. សេវាអាហារដ្ឋានទេសចរណ៍ ..... ៣២
៣. សេវាកម្សាន្តទេសចរណ៍ ..... ៣៣
៤. សេវាកម្សាន្តទេសចរណ៍សម្រាប់មនុស្សពេញវ័យ ..... ៣៣
*មេរៀនទី៦* **ការសម្រួលការធ្វើដំណើរ និង ការដឹកជញ្ជូនទេសចរណ៍** ..... ៣៥
១. ការផ្តល់ព័ត៌មានទេសចរណ៍ និងការបកស្រាយ ..... ៣៥
២. មធ្យោបាយធ្វើដំណើរទេសចរណ៍ ..... ៣៧
៣. បែបបទចេញ ចូលទេសចរណ៍ ..... ៣៧
*មេរៀនទី៧* **ខ្សែទស្សនកិច្ច** ..... ៤១
១. និយមន័យ ..... ៤១
២. សេវាកម្មទេសចរណ៍ ..... ៤១
៣. សមាសធាតុខ្សែទស្សនកិច្ច ..... ៤២

*មេរៀនទី៨* **ព្រឹត្តិការណ៍ទេសចរណ៍** ..... ៤៤
១. ព្រឹត្តិការណ៍ជាតិ ..... ៤៤
២. ព្រឹត្តិការណ៍អន្តរជាតិ ..... ៤៦
*មេរៀនទី៩* **បដិសណ្ឋារកិច្ច** ..... ៤៨
១. ការសំពះ ..... ៤៨
២. ការញញឹម ..... ៤៩
៣. ការស្លៀកពាក់ ..... ៤៩
៤. ការប្រើក្រសែភ្នែក ..... ៥០
៥. ការយកចិត្តទុកដាក់បម្រើភ្ញៀវឱ្យបានរហ័សរហួន ..... ៥០
៦. ការស្តាប់ ..... ៥០
៧. ការអបអរសាទរ ..... ៥១
៨. ការចេះលើកជាសំណួរ ..... ៥១
៩. ការធ្វើឱ្យភ្ញៀវមានទំនុកចិត្ត ..... ៥១
១០. ការបំពេញនូវចំណង់ និងតម្រូវការភ្ញៀវ ..... ៥១
១១. ការដាក់ខ្លួនក្នុងស្ថានភាពភ្ញៀវ(ដាក់ខ្លួនជាអ្នកបម្រើ) ..... ៥១
១២. ការយល់ដឹងពីផលិតផលរបស់ខ្លួន ..... ៥១
១៣. សេចក្តីរំពឹងរបស់ភ្ញៀវក្នុងតម្រូវការបន្ថែម ..... ៥១
១៤. ការធ្វើឱ្យភ្ញៀវមានអារម្មណ៍ថាត្រូវបានគេស្វាគមន៍ ..... ៥២
*មេរៀនទី១០* **ផលប្រយោជន៍នៃទេសចរណ៍** ..... ៥៣
១. ផលប្រយោជន៍សេដ្ឋកិច្ច ..... ៥៣
២. ផលប្រយោជន៍សង្គម ..... ៥៤
៣. ផលប្រយោជន៍វប្បធម៌ ..... ៥៥
៤. ផលប្រយោជន៍បរិស្ថាន ..... ៥៦
*មេរៀនទី១១* **ការប្រឡងប្រណាំងទីក្រុងស្អាត** ..... ៥៨
១. គណៈកម្មាធិការជាតិវាយតម្លៃទីក្រុងស្អាត ..... ៥៨
២. គោលបំណងនៃការប្រឡងប្រណាំងទីក្រុងស្អាត ..... ៥៨
៣. ស្តង់ដាទីក្រុងស្អាត ..... ៥៩
៤. នីតិវិធីនៃការប្រឡងប្រណាំងទីក្រុងស្អាត ..... ៦០
៥. អត្ថប្រយោជន៍នៃការចូលរួមក្នុងការប្រឡងប្រណាំងទីក្រុងស្អាត ..... ៦១
៦. ការប្រឡងប្រណាំងទីក្រុងស្អាត ..... ៦២

*មេរៀនទី១២* **សំណល់ប្លាស្ទិច និងបរិស្ថាន** ........ ៦៤
១. ផលប៉ះពាល់សំណល់ប្លាស្ទិចចំពោះបរិស្ថាន ........ ៦៤
២. ដំណោះស្រាយចំពោះបញ្ហាសំណល់ប្លាស្ទិច ........ ៦៦
**ឯកសារយោង** ........ ៦៩

# ការយល់ដឹងពីទេសចរណ៍

(ទ្រឹស្តី៤ម៉ោង អនុវត្ត៤ម៉ោង)

*ក្រោយពេលសិក្សាមេរៀននេះចប់សិស្សអាច៖*

- ប្រាប់និយមន័យទេសចរណ៍ និងទេសចរ
- បង្ហាញភាពខុសគ្នារវាងទេសចរណ៍ និងទេសចរ
- បង្ហាញភាពខុសគ្នារវាងការធ្វើដំណើរ និងទេសចរណ៍
- រៀបរាប់ និងពន្យល់ប្រភេទទេសចរជាតិ និងទេសចរអន្តរជាតិ។

ទេសចរណ៍ជាវិស័យដ៏មានសក្តានុពលមួយ ក្នុងចំណោមវិស័យអាទិភាពនានារបស់ប្រទេសកម្ពុជា ដែលរាជរដ្ឋាភិបាលកំណត់ថា ទេសចរណ៍ជាមាសបៃតងសម្រាប់រកប្រាក់ចំណូលចូលរដ្ឋ ក៏ដូចជាវិស័យឯកជនផងដែរ។

## ១. ការធ្វើដំណើរ

ការធ្វើដំណើរគឺជាចលនារបស់មនុស្សនៅក្នុងអំឡុងពេលណាមួយ ដូចជាការធ្វើដំណើរក្នុង ឬក្រៅប្រទេស ដើម្បីស្វែងរកទីលំនៅ បំពេញសកម្មភាពការងារ អន្តោប្រវេសន៍បណ្តោះអាសន្ន ឬអចិន្ត្រៃយ៍ ការស្រាវជ្រាវរយៈពេលវែង ដំណើរកម្សាន្ត សួរសុខទុក្ខញាតិមិត្ត និងជំនួញ។ល។ ចំណែកអ្នកធ្វើចលនាទាំងនោះហៅថាអ្នកដំណើរ។

*សកម្មភាពផ្សេងៗនៃការធ្វើដំណើរ*



  

## ២. និយមន័យទេសចរណ៍ និងទេសចរ

### ២.១ ទេសចរណ៍

សំដៅដល់សកម្មភាពទាំងឡាយរបស់បុគ្គល ដែលធ្វើដំណើរទៅ និងស្នាក់នៅកន្លែងផ្សេង ក្រៅពីបរិយាកាសប្រក្រតីរបស់គេ សម្រាប់រយៈពេលកំណត់មួយដែលមិនលើសពីមួយឆ្នាំជាប់ៗគ្នា ដើម្បីសម្រាកលំហែ កម្សាន្ត ធុរកិច្ច និងគោលបំណងទេសចរណ៍ស្របច្បាប់ផ្សេងៗទៀត។

សេចក្តីដូចបានរៀបរាប់ខាងលើបានបង្ហាញឱ្យឃើញថា ទេសចរណ៍កើតឡើងដោយសារការធ្វើដំណើរ ហើយបានរីកចម្រើនពីមួយថ្ងៃទៅមួយថ្ងៃ ដែលជាហេតុធ្វើឱ្យមានការកកើតសកម្មភាពថ្មីៗទៀត ដែលទាមទារឱ្យមានការអភិវឌ្ឍសេវាកម្មស្នាក់នៅ អាហារ ភេសជ្ជៈ ការធ្វើដំណើរ សេវាកម្មកម្សាន្ត និងផលិតផលទេសចរណ៍ផ្សេងៗទៀត។

### ២.២. ទេសចរ

សំដៅដល់បុគ្គលទាំងឡាយ ជាជនជាតិកម្ពុជា ឬជនបរទេសដែលមកដល់តំបន់ផ្សេងក្រៅពីបរិយាកាសប្រក្រតីរបស់គេ ស្នាក់នៅទីនោះចាប់ពីមួយយប់ឡើងទៅ និងមិនលើសពីរយៈពេលដែលកំណត់ ដើម្បីសម្រាកលំហែ កម្សាន្ត ធុរកិច្ច និងគោលបំណងទេសចរណ៍ស្របច្បាប់ផ្សេងៗទៀត ព្រមទាំងមិនទាក់ទងដល់គោលបំណងតាំងទីលំនៅ ឬធ្វើសកម្មភាពណាមួយដែលទទួលប្រាក់កម្រៃនៅទីនោះ។

## ៣. ប្រភេទទេសចរ

ទេសចរត្រូវបានបែងចែកពីរប្រភេទគឺៈ

### ៣.១. ទេសចរជាតិ

- *ទេសចរក្នុងស្រុក*

ទេសចរក្នុងស្រុកសំដៅទៅលើទេសចរជាតិចេញពីលំនៅរបស់ខ្លួន តែពុំឆ្លងកាត់ព្រំដែនទៅបរទេសទេ ដោយគ្រាន់តែឆ្លងកាត់ពីខេត្តមួយទៅខេត្តមួយ ឬពីតំបន់មួយទៅតំបន់មួយទៀត។

ដូចនេះយើងអាចនិយាយបានថា ទេសចរក្នុងស្រុកគឺពលរដ្ឋជាម្ចាស់ស្រុក ឬម្ចាស់ប្រទេសដែលបានធ្វើដំណើរកម្សាន្ត នៅក្នុងប្រទេសកំណើតរបស់ខ្លួន ដោយចាកចេញពីលំនៅអចិន្ត្រៃយ៍ទៅតំបន់ទេសចរណ៍ណាមួយ។ ឧទាហរណ៍ សុខមានស្រុកកំណើតនៅខេត្តសៀមរាប ធ្វើដំណើរជាមួយគ្រួសារទៅកម្សាន្តនៅឆ្នេរអូរឈើទាលខេត្តព្រះសីហនុ។

- *ទេសចរជាតិចេញក្រៅស្រុក*

យើងកំណត់ទេសចរក្រៅស្រុក គឺរាល់ទេសចរដែលធ្វើដំណើរចេញពីទីលំនៅអចិន្ត្រៃយ៍របស់ខ្លួន ឆ្ពោះទៅកាន់ប្រទេសមួយទៀត ក្នុងគោលបំណងលំហែ កម្សាន្ត ឬដោយគោលបំណងទេសចរណ៍ផ្សេងៗទៀត។

ទេសចរក្រៅស្រុក គឺសកម្មភាពរបស់ជនជាតិខ្មែរយើងធ្វើដំណើរចេញទៅបរទេស។ ឯទេសចរក្នុងស្រុកជាទេសចរជនជាតិខ្មែរ ដែលធ្វើដំណើរកម្សាន្តក្នុងប្រទេសរបស់ខ្លួនតែប៉ុណ្ណោះ។ កំណើនទេសចរជាតិគឺអាស្រ័យទៅនឹងសេដ្ឋកិច្ចនៃប្រទេសនោះផងដែរ។

ដើម្បីឱ្យកាន់តែយល់ច្បាស់យើង នឹងលើកយកឧទាហរណ៍មកបង្ហាញ។ សុវណ្ណារ៉ាជាជនជាតិខ្មែរ បានធ្វើដំណើរពីប្រទេសកម្ពុជាដែលជាស្រុកកំណើត ទៅកម្សាន្តនៅប្រទេសសឹង្ហបុរី ចំនួនមួយសប្តាហ៍។ ដូចនេះយើងអាចនិយាយបានថា សុវណ្ណារ៉ាជាទេសចរជាតិក្រៅស្រុក ដែលចាកចេញពីប្រទេសកំណើតទៅកម្សាន្តនៅប្រទេសផ្សេងទៀត។ ក៏ប៉ុន្តែ សុវណ្ណារ៉ាគឺជាទេសចរអន្តរជាតិសម្រាប់ប្រទេសសឹង្ហបុរី។

### ៣.៤. ទេសចរអន្តរជាតិ

ទេសចរអន្តរជាតិ គឺជាទេសចរបរទេសគ្រប់ជាតិសាសន៍ និងគ្រប់ប្រភេទ ដែលចូលមកទស្សនា ឬស្នាក់នៅក្នុងប្រទេសយើង យ៉ាងតិចបំផុតរយៈពេលមួយយប់។ ភ្ញៀវបែបនេះមកក្នុងឋានៈ ជាផ្លូវការ ជាទេសចរណ៍ អ្នកជំនួញ សិស្សមកសិក្សា ឬធ្វើកម្មសិក្សា ឬមកក្នុងសកម្មភាពផ្សេងៗទៀត ទោះជាចូលមកតាមផ្លូវគោក ផ្លូវអាកាស ឬផ្លូវទឹកក្តី។ ឧទាហរណ៍ ជនជាតិបារាំងបានធ្វើដំណើរពីប្រទេសរបស់ពួកគេ មកកម្សាន្តនៅខេត្តសៀមរាប។ ដូចនេះ ជនជាតិបារាំងទាំងនោះគឺជាទេសចរអន្តរជាតិសម្រាប់ប្រទេសកម្ពុជា។

ទេសចរអន្តរជាតិគិតបញ្ចូល៖

- ទេសចរដែលស្នាក់នៅមិនលើសពីមួយយប់ ទោះជានៅក្នុងការស្នាក់អាស្រ័យជាឯកជន ឬពាណិជ្ជកម្មក៏ដោយ
- ទេសចរដែលធ្វើដំណើរកម្សាន្តក្នុងថ្ងៃតែមួយ
- ទេសចរដែលមិនបានស្នាក់នៅមួយយប់នៅក្នុងប្រទេសដែលមកកម្សាន្ត។

គេមិនគិតបញ្ចូលអ្នកធ្វើដំណើរតាមរថភ្លើងទេ ប្រសិនបើគេស្នាក់នៅក្នុងរថភ្លើងនោះ។ ប្រទេសខ្លះគិតស្ថិតិទេសចរអន្តរជាតិដោយយោងទៅលើតែចំនួនទេសចរពិតប្រាកដ។ ឯប្រទេសខ្លះទៀត គេគិតទាំងចំនួនទេសចរដែលឆ្លងកាត់ព្រំដែនចូលមកក្នុងប្រទេស ដោយសំអាងលើរយៈពេលលើសពី២៤ម៉ោងដែលឆ្លងកាត់។ នៅប្រទេសកម្ពុជា យើងស្រង់ស្ថិតិទេសចរអន្តរជាតិដែលចូលមកតាមចំនួនជាក់ស្តែង ដោយចូលមកតាមអាកាសយានដ្ឋានអន្តរជាតិ តាមច្រកព្រំដែនគោក និងសមុទ្រ។

**មេរៀនសង្ខេប**

*ការធ្វើដំណើរ* គឺជាចលនារបស់មនុស្សនៅក្នុងអំឡុងពេលណាមួយ នៅរយៈពេលណាមួយ ដូចជាការធ្វើដំណើរក្នុងប្រទេសបំពេញសកម្មភាពការងារដើម្បីរកប្រាក់ចំណូល ការធ្វើ

ដំណើរទៅតំបន់ផ្សេងៗ ដើម្បីបំពេញការងារក្នុងអង្គភាពខ្លួន ការធ្វើដំណើរកម្សាន្ត ការទៅព្យាបាល ជំងឺ។ល។ ចំណែកអ្នកធ្វើចលនាទាំងនេះហៅថាអ្នកដំណើរ។

***ទេសចរណ៍*** សំដៅដល់សកម្មភាពទាំងឡាយរបស់បុគ្គល ដែលធ្វើដំណើរទៅ និងស្នាក់នៅកន្លែងផ្សេងក្រៅពីបរិយាកាសប្រក្រតីរបស់គេ សម្រាប់រយៈពេលកំណត់មួយ ដែលមិនលើសពីមួយឆ្នាំជាប់ៗគ្នា ដើម្បីសម្រាក លំហែ កម្សាន្ត ធុរកិច្ច និងគោលបំណងទេសចរណ៍ស្របច្បាប់ផ្សេងៗទៀត។

***ទេសចរ*** សំដៅដល់បុគ្គលទាំងឡាយជាជនជាតិកម្ពុជា ឬជនបរទេសដែលមកដល់តំបន់ផ្សេងក្រៅពីបរិយាកាសប្រក្រតីរបស់គេ ហើយស្នាក់នៅទីនោះចាប់ពីមួយយប់ឡើងទៅ និងមិនលើសពីរយៈពេលដែលកំណត់ដើម្បីសម្រាកលំហែ កម្សាន្ត ធុរកិច្ច និងគោលបំណងទេសចរណ៍ស្របច្បាប់ផ្សេងៗទៀត ព្រមទាំងមិនទាក់ទងដល់គោលបំណងតាំងទីលំនៅ ឬធ្វើសកម្មភាពណាមួយដែលទទួលប្រាក់កម្រៃនៅទីនោះ។

***ទេសចរជាតិ*** មានៈ

***ទេសចរក្នុងស្រុក*** ជាទេសចរពលរដ្ឋម្ចាស់ស្រុក ឬម្ចាស់ប្រទេស ធ្វើដំណើរកម្សាន្តក្នុងប្រទេសកំណើតរបស់ខ្លួនដោយចាកចេញពីលំនៅអចិន្ត្រៃយ៍ទៅតំបន់ទេសចរណ៍ណាមួយ តែពុំឆ្លងកាត់ព្រំដែនទៅបរទេសទេ។

***ទេសចរជាតិចេញក្រៅស្រុក*** គឺពល់សកម្មភាពនៃទេសចរដែលធ្វើដំណើរចេញពីទីលំនៅអចិន្ត្រៃយ៍ឆ្ពោះទៅកាន់ប្រទេសមួយទៀត ក្នុងបំណងលំហែកម្សាន្ត ឬដោយបំណងណាផ្សេងទៀត។ ឧទាហរណ៍ ទេសចរជនជាតិខ្មែរយើងធ្វើដំណើរចេញទៅបរទេស។

***ទេសចរអន្តរជាតិ*** គឺជាទេសចរបរទេសគ្រប់ជាតិសាសន៍ និងគ្រប់ប្រភេទដែលចូលមកក្នុងប្រទេសមួយផ្សេងទៀតហើយស្នាក់នៅយ៉ាងតិចបំផុតរយៈពេលមួយយប់។

## សំណួរ

១. តើការធ្វើដំណើរជាអ្វី? ចូរលើកឧទាហរណ៍បញ្ជាក់ឱ្យបាន ៥ សកម្មភាព។

២. តើទេសចរណ៍ជាអ្វី? ចូរលើកឧទាហរណ៍បញ្ជាក់ឱ្យបាន៣សកម្មភាព។

៣. ចូរបង្ហាញភាពខុសគ្នារវាងការធ្វើដំណើរ និងទេសចរណ៍។

៤. តើទេសចរជាអ្វី?

៥. ដូចម្តេចដែលហៅថាទេសចរអន្តរជាតិ?

# គោលបំណងទេសចរណ៍

(ទ្រឹស្តី៤ម៉ោង អនុវត្ត៤ម៉ោង)

*សិក្សាមេរៀននេះចប់សិស្សអាចៈ*

- រៀបរាប់និងពន្យល់គោលបំណងសំខាន់ៗនៃការធ្វើដំណើរជាទេសចរណ៍
- បង្ហាញមូលហេតុសំខាន់ៗ ឬកត្តាដែលជំរុញការធ្វើដំណើរជាទេសចរណ៍
- រៀបរាប់ និងពន្យល់ប្រភេទនៃការធ្វើដំណើរជាទេសចរណ៍។

បុគ្គលទាំងឡាយមុននឹងចាកចេញពីលំនៅដ្ឋានអចិន្ត្រៃយ៍របស់គេទៅកាន់តំបន់ណាមួយជាទេសចរណ៍តែងតែមានគោលបំណងដោយឡែករៀងៗខ្លួន។

## ១. គោលបំណងនៃការធ្វើដំណើរជាទេសចរណ៍

គោលបំណងដែលកំណត់ទៅតាមតម្រូវការលើការពង្រឹងកម្លាំងកាយ កម្លាំងចិត្ត និងបម្រើឱ្យចំណង់លើការបង្កើននូវការស្វែងយល់ពីមជ្ឈដ្ឋានប្លែកៗជុំវិញដូចជាៈ

- កម្សាន្តលំហែអារម្មណ៍ជាមួយនឹងភាពយន្ត ល្ខោន មហោស្រព ពិព័រណ៍
- បរបាញ់ នេសាទ គំនូរ ចម្លាក់ សិក្សា និងស្រាវជ្រាវវប្បធម៌ ប្រវត្តិសាស្ត្រ
- ជនជាតិ និងដើមកំណើត(វប្បធម៌ជនជាតិ សាសនា ភាសា អរិយធម៌។ល។)
- ងូតទឹក សម្រាកតំបន់ឆ្នេរ លេងល្បែង លំហែ ធ្វើបំលាស់ប្តូរបរិយាកាស
- បន្ធូរអារម្មណ៍ ស្វែងយល់អំពីវប្បធម៌ ប្រវត្តិសាស្ត្រ ប្រពៃណី
- ទស្សនាប្រាសាទបុរាណ ជីវិតរាត្រី និងសាកល្បងអាហារ
- សិក្សាស្រាវជ្រាវអំពីធម្មជាតិ សត្វព្រៃ បក្សាបក្សី តំបន់ទេសភាព។ល។



*ទិដ្ឋភាពមួយចំនួនដែលទាក់ទងនឹងគោលបំណងស្វែងយល់ ទស្សនា និងសកម្មភាពផ្សេងៗ*

## ២. មូលហេតុនៃការធ្វើដំណើរជាទេសចរណ៍

មូលហេតុដែលនាំឱ្យពលរដ្ឋធ្វើដំណើរជាទេសចរណ៍នោះមានច្រើនយ៉ាង ហើយត្រូវបាន

កំណត់ទៅតាមមូលហេតុផ្សេងៗគ្នា។ មូលហេតុឬកត្តាជំរុញឱ្យមានការធ្វើដំណើរជាទេសចរណ៍មាន៖

- សម្រាក សប្បាយ លំហែ(តំបន់សមុទ្រ ឆ្នេរខ្សាច់ ទឹកជ្រោះ និងសកម្មភាពផ្សេងៗ)
- ស្វែងយល់ (ទស្សនារមណីយដ្ឋាន ប្រាសាទ សម្បត្តិវប្បធម៌ អរិយធម៌។ល។)
- កីឡា (ចូលរួមកម្សាន្ត ទស្សនា និងលេងកីឡាដើម្បីលំហែអារម្មណ៍)
- ព្យាបាល និងសាសនា
- ទៅលេងញាតិមិត្ត មិត្តភក្តិ ស្រុកកំណើត។ល។
- អាជីវកម្ម ប្រជុំ សន្និសីទ សិក្ខាសាលា
- វប្បធម៌(ចង់ដឹងច្រើនអំពីប្រទេសដទៃ របាំ ចម្រៀង សាសនា ទំនៀមទម្លាប់ ប្រពៃណី)
- ការចង់ធ្វើបំលាស់ប្តូរ និងស្វែងរកអ្វីដែលប្លែកពីធម្មតាទាក់ទងនឹងធម្មជាតិ ភូមិសាស្ត្រ
- ចង់ឃើញពីភាពអស្ចារ្យ និងចូលរួមក្នុងព្រឹត្តិការណ៍នៅក្នុងតំបន់ណាមួយ
- ចំណង់លើការលំហែតាមតំបន់ភ្នំ ខ្ពង់រាប វាលទំនាប សត្វព្រៃ ព្រៃព្រឹក្សា ទេសភាព
- សម្រាក និងលំហែតំបន់កសិដ្ឋាន ដំណាំផ្លែឈើ ចម្ការ ការដាំដុះ
- ចំណង់ក្នុងការទស្សនាសារមន្ទីរ តន្ត្រី ល្ខោន ទិញសម្លៀកបំពាក់ ទទួលទានម្ហូបអាហារ។

## ៣. ប្រភេទនៃការធ្វើដំណើរជាទេសចរណ៍

ប្រភេទនៃការធ្វើដំណើរជាទេសចរណ៍ដោយផ្អែកលើភាពទាក់ទាញរួមមាន៖

### ៣.១. ទេសចរណ៍វប្បធម៌



*ទិដ្ឋភាពនានាដែលទាក់ទងនឹងទេសចរណ៍វប្បធម៌*

ទេសចរណ៍ប្រភេទនេះផ្អែកលើតំបន់ប្រវត្តិសាស្ត្រ វប្បធម៌ ប្រពៃណី ទំនៀមទម្លាប់ ការស្លៀកពាក់ របាំ តន្ត្រី ល្ខោន សិប្បកម្ម និងវិធីផ្សេងៗ។ឧទាហរណ៍ តំបន់សៀមរាបអង្គរ របាំអប្សរា ល្ខោនស្បែកធំ។ល។

### ៣.២. អេកូទេសចរណ៍

អេកូទេសចរណ៍សំដៅដល់ទម្រង់ទេសចរណ៍ផ្អែកលើធម្មជាតិ ដែលមានគោលបំណងអភិរក្សបរិស្ថានធម្មជាតិ និងវប្បធម៌តំបន់ ជួយលើកកម្ពស់ជីវភាពរស់នៅ សុខមាលភាពរបស់ប្រជាពលរដ្ឋមូលដ្ឋាន ផ្ដល់បទពិសោធន៍ល្អដល់ទេសចរ និងការធ្វើដំណើរប្រកបដោយការទទួលខុសត្រូវ និងកម្សាន្ត កោតសរសើររៀនសូត្រពីធម្មជាតិ។



*ទិដ្ឋភាពនានាដែលទាក់ទងនឹងអេកូទេសចរណ៍*

### ៣.៣. កសិទេសចរណ៍

កសិទេសចរណ៍គឺជាប្រភេទទេសចរណ៍ផ្អែកលើកសិកម្មនៅជនបទ។ ផលិតផលកសិកម្ម វិធីដាំដុះ និងរបៀបរស់នៅជនបទ គឺជាភាពទាក់ទាញដ៏ចម្បង សម្រាប់ឱ្យទេសចរទស្សនា និងទទួលបទពិសោធន៍។



*ទិដ្ឋភាពនានាដែលបង្ហាញពីកសិទេសចរណ៍*

### ៣.៤. ទេសចរណ៍សហគមន៍



*ទិដ្ឋភាពនានានៅតាមសហគមន៍*

ទេសចរណ៍សហគមន៍ គឺជាប្រភេទទេសចរណ៍ដែលគ្រប់គ្រងដោយសហគមន៍មូលដ្ឋាន។ ប្រជាជននៅក្នុងសហគមន៍មូលដ្ឋានមានកាតព្វកិច្ចថែរក្សា ការពារ និងអភិរក្សប្រពៃណី ទំនៀមទម្លាប់ និងធនធានរបស់ខ្លួនសម្រាប់បម្រើឱ្យវិស័យទេសចរណ៍។

### ៣.៥. ទេសចរណ៍ផ្សងព្រេង

ទេសចរណ៍ប្រភេទនេះអាចប្រឈមមុខនឹងសកម្មភាពគ្រោះថ្នាក់មួយចំនួន។ ទេសចរណ៍ផ្សងព្រេងមានដូចជា ការធ្វើដំណើរទៅតំបន់ដាច់ស្រយាល ការឡើងភ្នំ និងការជិះទូកតាមទឹកជ្រោះ។ល។



*រូបភាពទាក់ទងនឹងសកម្មភាពផ្សងព្រេងរបស់ទេសចរ*

### ៣.៦. ទេសចរណ៍ស្ម័គ្រចិត្ត

ទេសចរណ៍ស្ម័គ្រចិត្ត គឺជាប្រភេទទេសចរណ៍ដែលទេសចរស្ម័គ្រចិត្តចូលរួម និងផ្តល់ការគាំទ្រដល់គម្រោងអភិវឌ្ឍសំដៅលើកកម្ពស់សុខុមាលភាព ជីវភាពប្រជាជនមូលដ្ឋាន។ ឧទាហរណ៍ ទេសចរជួយច្រូតស្រូវសហគមន៍ ទេសចរជួយបង្រៀនភាសាដល់កុមារ។



*រូបភាពមួយចំនួនដែលទាក់ទងនឹងសកម្មភាពទេសចរណ៍ស្ម័គ្រចិត្ត*

### ៣.៧. ទេសចរណ៍សម្រាកលំហែ

ទេសចរណ៍សម្រាកលំហែ ជាសកម្មភាពរបស់ទេសចរ ដែលធ្វើដំណើរចាកចេញពីលំនៅអចិន្ត្រៃយ៍ ឆ្ពោះទៅកន្លែងណាមួយដែលសម្បូរទៅដោយធម្មជាតិដូចជា ទន្លេ សមុទ្រ ទឹកធ្លាក់ ទឹកជ្រោះ ព្រៃភ្នំ។ល។ ក្នុងការសម្រាកលំហែចុងសប្តាហ៍ ឬវិស្សមកាល។ ទេសចរណ៍ប្រភេទនេះស្នាក់នៅរយៈពេលយូរ រហូតដល់ពីរសប្តាហ៍។

### ៣.៨. ទេសចរណ៍ជំនួញ

ជាប្រភេទទេសចរណ៍ដែលធ្វើដំណើរក្នុងគោលបំណងកំណត់ បញ្ជាក់ និងបង្កើតទំនាក់ទំនងសម្រាប់ការងារអាជីវកម្មជាមួយអ្នកមានលទ្ធភាពជាដៃគូ និងចូលរួមក្នុងពិធីធំៗដូចជាសិក្ខាសាលា

ការប្រជុំតូចធំ សន្និបាត សន្និសីទ ពិធីតាំងពិព័រណ៍។ល។ ទេសចរណ៍ប្រភេទនេះ ធ្វើឡើងតាមការស្វែងយល់ និងសិក្សាអំពីលក្ខន្តិកៈសម្រាប់ធ្វើការងារអាជីវកម្ម និងត្រៀមទិញទំនិញសម្រាប់យកទៅធ្វើពាណិជ្ជកម្ម។ល។




*សកម្មភាពខ្លះៗដែលទាក់ទងនឹងទេសចរណ៍អាជីវកម្ម*

### ៣.៩. ទេសចរណ៍សុខុមាលភាព

ជាទេសចរណ៍ដែលធ្វើឡើងតាមរយៈតម្រូវការលើការពង្រឹងសុខភាព ស្តារកម្លាំងកាយចិត្តបន្ធូរអារម្មណ៍។ ទេសចរណ៍ប្រភេទនេះ កំណត់តម្រូវការលើធាតុអាកាសល្អ តំបន់ភ្នំ(ជាពិសេសរូងភ្នំ) តំបន់ឆ្នេរសមុទ្រ តំបន់កីឡា រមណីយដ្ឋាន និងថៃរក្សាសុខភាព ដោយការប្រើប្រាស់ថ្នាំបុរាណ ឬទឹកដោះគោសម្រាប់ត្រាំ ឬផុង ឬវិធីសាស្ត្របុរាណ។ល។



*តំបន់កម្សាន្តនានាដែលទេសចរអាចទទួលបាននូវផាសុកភាព*

### ៣.១០. ទេសចរណ៍វេជ្ជសាស្ត្រ

ជាសកម្មភាពបុគ្គលចាកចេញពីលំនៅអចិន្ត្រៃយ៍ ឆ្ពោះទៅកន្លែងជាក់លាក់ណាមួយ ក្នុងឬក្រៅប្រទេសក្នុងគោលបំណងវះកាត់ ព្យាបាលជំងឺ ឬកែសម្ផស្សជាដើម។

### ៣.១១. ទេសចរណ៍កីឡា

ជាបំណងទេសចរណ៍ដែលកំណត់បានដោយសារការធ្វើដំណើរដើម្បីហាត់លេងកីឡា ដើម្បីចូលរួមប្រកួត និងទស្សនាការលេងកីឡា ការប្រកួតប្រជែងកីឡាដូចជា បាល់ទាត់ វាយសី បាល់បោះ ប្រដាល់ ឡើងភ្នំ ហែលទឹក ។ល។



*រូបភាពដែលទាក់ទងនឹងសកម្មភាពទេសចរណ៍កីឡា*

### ៣.១២. ទេសចរណ៍សាសនា

ជាបំណងទេសចរណ៍ដែលធ្វើឡើង តាមតម្រូវការលើការគោរពសាសនា និងស្វែងយល់ពីសាសនា។ ទេសចរណ៍ប្រភេទនេះត្រូវបានបែងចែកជាការធ្វើដំណើរដើម្បីទស្សនាស្ថាបត្យកម្មសំណង់ និងអគារសាសនា ចូលរួមក្នុងពិធីបុណ្យសាសនា និងពិធីប្រារព្ធបូជាលាងកំហុស។ល។



*ទិដ្ឋភាពមួយចំនួនដែលទាក់ទងនឹងទេសចរណ៍សាសនា*

### ៣.១៣. ទេសចរណ៍សួរសុខទុក្ខ

ជាបំណងទេសចរណ៍ដែលធ្វើដំណើរដើម្បីមកលេងជួបជុំបងប្អូន ញាតិមិត្ត និងជួបជាមួយមនុស្សដែលជាទីគាប់ចិត្ត និងស្រឡាញ់ ទិញវត្ថុអនុស្សាវរីយ៍ និងជំនូន។ល។

ផ្អែកលើច្បាប់ស្តីពីទេសចរណ៍ បានកំណត់និយមន័យឱ្យគោលបំណងទេសចរណ៍ថា៖ គោលបំណងទេសចរណ៍ សំដៅដល់គោលបំណងសំខាន់ៗដូចជា ការសម្រាកលំហែ កម្សាន្ត និងទស្សនា។



*សកម្មភាពដែលបង្ហាញពីការសួរសុខទុក្ខ*

**មេរៀនសង្ខេប**

***គោលបំណងនៃការធ្វើដំណើរជាទេសចរណ៍*** មានប្រាំមួយសំខាន់ៗគឺៈ ទេសចរណ៍ស្វែងយល់ ទស្សនា និងការកម្សាន្ត ទេសចរណ៍សុខភាព និងព្យាបាល ទេសចរណ៍អាជីវកម្ម ឬធុរកិច្ច ទេសចរណ៍កីឡា ទេសចរណ៍សាសនា ទេសចរណ៍សួរសុខទុកញាតិសន្តាន និង មិត្តភក្តិ។

***គោលបំណងទេសចរណ៍សំដៅដល់គោលបំណងសំខាន់ៗ*** ដូចជា សម្រាកលំហែកម្សាន្ត ទស្សនា សាសនា សកម្មភាពកីឡា ធុរកិច្ចសាកសួរសុខទុក្ខញាតិសន្តាន ព្យាបាលសុខភាព សិក្សាស្រាវជាវ និងគោលបំណងទេសចរណ៍ស្របច្បាប់ផ្សេងទៀត។

***មូលហេតុនៃការធ្វើដំណើរជាទេសចរណ៍*** មានៈ សម្រាក សប្បាយ លំហែ ស្វែងយល់ កីឡា ព្យាបាល និងសាសនា ទៅលេងញាតិមិត្ត មិត្តភក្តិ ស្រុកកំណើត អាជីវកម្ម ប្រជុំ សន្និសីទ សិក្ខាសាលា វប្បធម៌ប្រទេសដទៃ(របាំ ចម្រៀង សាសនា ទំនៀមទម្លាប់ ប្រពៃណី) ការចង់ធ្វើបំលាស់ប្តូរ និងស្វែងរកអ្វីដែលប្លែកពីធម្មតា ភាពអស្ចារ្យ និងចូលរួមក្នុងព្រឹត្តិការណ៍នៅក្នុងតំបន់ណាមួយទស្សនាសារមន្ទីរ។

***ប្រភេទនៃការធ្វើដំណើរជាទេសចរណ៍*** ដោយផ្អែកលើភាពទាក់ទាញមានៈ ទេសចរណ៍វប្បធម៌ អេកូទេសចរណ៍ ឬទេសចរណ៍ធម្មជាតិ ទេសចរណ៍ទីក្រុង ទេសចរណ៍សុខភាព ទេសចរណ៍ផ្សងព្រេង កសិទេសចរណ៍ ទេសចរណ៍ស្ម័គ្រចិត្ត ទេសចរណ៍សហគមន៍ ។ល។

## សំណួរ

១. តើគោលបំណងនៃការធ្វើដំណើរជាទេសចរណ៍មានអ្វីខ្លះ? ចូររៀបរាប់ឱ្យបានយ៉ាងតិច៥។

២. តើមូលហេតុ ឬកត្តាអ្វីខ្លះដែលជំរុញឱ្យមានការធ្វើដំណើរជាទេសចរណ៍? តាមយោបល់របស់ប្អូន តើមូលហេតុអ្វីដែលសំខាន់ជាងគេសម្រាប់ប្អូន? ចូរបកស្រាយពន្យល់?

៣. តើប្រភេទទេសចរណ៍ដោយផ្អែកទៅលើប្រភេទទាក់ទាញមានអ្វីខ្លះ?

៤. អ្វីទៅជាទេសចរណ៍វប្បធម៌? ចូរពន្យល់។

# តំបន់ទេសចរណ៍ និងសក្តានុពលទេសចរណ៍ នៃព្រះរាជាណាចក្រកម្ពុជា

(ទ្រឹស្តី៦ម៉ោង អនុវត្ត៨ម៉ោង)

*សិក្សាមេរៀននេះចប់សិស្សអាចៈ*

- រៀបរាប់ និងពន្យល់តំបន់ទេសចរណ៍ និងសក្តានុពលទេសចរណ៍
- ចូលរួមអភិរក្ស និងអភិវឌ្ឍតំបន់ទេសចរណ៍ ។

## ១. ស្ថានភាពទូទៅ

ធនធានធម្មជាតិ និងវប្បធម៌ដ៏វិសេសវិសាលត្រូវបានគេចាត់ទុកថា "កម្ពុជាជាឃ្លាំងធម្មជាតិ និងវប្បធម៌"។ នៅសម័យអង្គរអរិយធម៌ខ្មែរបានរីកលូតលាស់ដល់កម្រិតកំពូល ជាហេតុនាំឱ្យប្រវត្តិវិទូចាត់ទុកប្រទេសខ្មែរសម័យនោះថា មហាអំណាចនៅភូមិភាគអាស៊ីអាគ្នេយ៍។ អ្នកសិក្សាស្រាវជ្រាវជាតិ និងអន្តរជាតិ បានសរសេរកត់ត្រាជាច្រើនដើម្បីពិពណ៌នាពន្យល់ និងកោតសរសើរអំពីអរិយធម៌អង្គរ ជាពិសេសអំពីប្រាសាទអង្គរវត្តដែលជាអច្ឆរិយវត្ថុដ៏អស្ចារ្យមួយក្នុងពិភពលោក។ ក្រៅពីសម្បត្តិវប្បធម៌ខ្មែរយើងក៏ នៅមានសម្បត្តិធម្មជាតិសម្បូរបែបថែមទៀតដូចជា ទន្លេ ស្ទឹង បឹងបួ សមុទ្រ ព្រៃព្រឹក្សា សត្វព្រៃ។ល។ ស្ទើរតែពេញមួយឆ្នាំដោយសារអាកាសធាតុត្រូពិច(ក្តៅហើយសើម) រុក្ខជាតិនៅកម្ពុជាមានពណ៌បៃតងរហូត ដែលជាលក្ខណៈទាក់ទាញដ៏ពិសេសមួយសម្រាប់ទេសចរណ៍។

លើសពីនេះទៀត កម្ពុជាមានសក្តានុពលធំធេងណាស់ សម្រាប់ការអភិវឌ្ឍទេសចរណ៍វប្បធម៌ និងធម្មជាតិ។ បើគិតត្រឹមតែប្រាង្គប្រាសាទបុរាណ កម្ពុជាជាប្រទេសតែមួយគត់ក្នុងទ្វីបអាស៊ីដែលមានប្រាង្គប្រាសាទបុរាណជាង១០០០ដែលមានអាយុកាលរាប់ពាន់ឆ្នាំ និងគ្រឹះប្រាសាទរាប់ពាន់កន្លែងផ្សេងទៀតដែលស័ក្តិសមនឹងកិត្តិនាម "កម្ពុជាៈ ព្រះរាជាណាចក្រនៃវប្បធម៌" ។

## ២. តំបន់ទេសចរណ៍

សម្រាប់វិស័យទេសចរណ៍នៅកម្ពុជា គេចែកតំបន់ទេសចរណ៍ជាបួនតំបន់គឺៈ

### ២.១. ភ្នំពេញ និងតំបន់ជុំវិញ

ភ្នំពេញ និងតំបន់ជុំវិញជាតំបន់វាលរាបរួមមានៈ រាជធានីភ្នំពេញ ខេត្តកណ្តាល ខេត្តកំពង់ស្ពឺ ខេត្តកំពង់ឆ្នាំង ខេត្តពោធិសាត់ ខេត្តកំពង់ចាម ខេត្តត្បូងឃ្មុំ ខេត្តស្វាយរៀង ខេត្តព្រៃវែង និងខេត្តតាកែវ។

***តំបន់ទេសចរណ៍ភ្នំពេញ*** ៖ ព្រះបរមរាជវាំង សារមន្ទីរជាតិ វត្តភ្នំ វត្តឧណ្ណាលោម មាត់ទន្លេ កោះពេជ្រ ផ្សារធំថ្មី ផ្សារអ៊ីអន ផ្សារទួលទំពូង សារមន្ទីរប្រល័យពូជសាសន៍ទួលស្លែង វាលពិឃាតជើងឯក រមណីយដ្ឋានចម្ការព្រីង មជ្ឈមណ្ឌលសិប្បកម្ម(កោះដាច់ ចម្ការស្ទេហ៍) ...។




- ***តំបន់ទេសចរណ៍ខេត្តកណ្តាល*** ៖ ភ្នំឧត្តុង ភ្នំប្រសិទ្ធិ វត្តភ្នំធនមន្ត វត្តស្លាងភ្នំ វត្តគៀនស្វាយក្រៅ វត្តទំពែក វត្តអង្គរជ័យ ...។
- ***តំបន់ទេសចរណ៍ខេត្តកំពង់ស្ពឺ*** ៖ អំពែភ្នំ ឧទ្យានជាតិព្រះសុរាម្រិតកុសមៈ រមណីយដ្ឋានគិរីរម្យ ចំបក់ ភ្នំព្រៃខ្មែរ ទេវទឹកពុះ ទឹកធ្លាក់ជ្រៀវ ...។
- ***តំបន់ទេសចរណ៍ខេត្តកំពង់ឆ្នាំង*** ៖ ភ្នំរាប់បាត ភ្នំសន្ទូច ភ្នំក្រាំងរមាស ភ្នំតារាជ ...។
- ***តំបន់ទេសចរណ៍ខេត្តពោធិសាត់*** ៖ បូជនីយដ្ឋានអ្នកតាឃ្លាំងមឿង បាក់ត្រា ភ្នំបាឃ្លះ កំពង់លួង ...។
- ***តំបន់ទេសចរណ៍ខេត្តកំពង់ចាម*** ៖ ប្រាសាទនគរបាជ័យ ភ្នំប្រុស ភ្នំស្រី ភ្នំហាន់ជ័យ(ភ្នំជ័យគិរី) ប្រាសាទភ្នំជើងព្រៃ ជ្រោយចេក ...។
- ***តំបន់ទេសចរណ៍ខេត្តត្បូងឃ្មុំ*** ៖ ហ្លួងព្រះស្តេចកន ប្រាសាទព្រះធាតុបាស្រី ទឹកធ្លាក់ហោង ភ្នំខ្នងក្រពើ អន្លង់ជ្រៃ ...។
- ***តំបន់ទេសចរណ៍ខេត្តតាកែវ*** ៖ ភ្នំដា ភ្នំបាយ៉ង ប្រាសាទនាងខ្មៅ ភ្នំជីសូរ ទន្លេបាទី ភ្នំតាម៉ៅ ប្រាសាទជប់វាល វត្តភ្នំខ្លែង សារមន្ទីរ ...។
- ***តំបន់ទេសចរណ៍ខេត្តព្រៃវែង*** ៖ បារាយណ៍អណ្តែត បាភ្នំ ប្រាសាទចុងស្រុក ...។
- ***តំបន់ទេសចរណ៍ខេត្តស្វាយរៀង*** ៖ ព្រៃបាសាក់ ព្រំដែនអន្តរជាតិបាវិត ...។

## ២.២. សៀមរាបអង្គរ និងតំបន់ជុំវិញ

សៀមរាបអង្គរ និងតំបន់ជុំវិញរួមមាន៖ ខេត្តសៀមរាប ខេត្តបាត់ដំបង ខេត្តប៉ៃលិន ខេត្តឧត្តរមានជ័យ ខេត្តព្រះវិហារ ខេត្តកំពង់ធំ និងខេត្តបន្ទាយមានជ័យ។

- ***ខេត្តសៀមរាប*** ជាខេត្តសម្បូរទៅដោយសំណង់វប្បធម៌ប្រវត្តិសាស្ត្រជាច្រើនមានដូចជា៖
    - ប្រាសាទអង្គរវត្ត
    - ប្រាសាទពីអង្គរវត្តទៅអង្គរធំ (ប្រាសាទតាព្រហ្មកិល ប្រាសាទភ្នំបាខែង ប្រាសាទបក្សីចាំក្រុង ប្រាសាទរោងរមុង ប្រាសាទថ្មបាយក្អែក ប្រាសាទបី)
    - អង្គរធំ (ប្រាសាទបាយ័ន ព្រះងោក ព្រះអង្គធ្លក ប្រាសាទបាពួន ប្រាសាទភិមានអាកាស ព្រះលានជល់ដំរី ព្រះលានស្តេចគំលង់ ប្រាសាទទេពប្រណម ប្រាសាទព្រះប៉ាលីឡៃ ព្រះពិធូរ ប្រាសាទសួរព្រ័ត ប្រាសាទឃ្លាំងខាងជើង និងឃ្លាំងខាងត្បូង វិហារប្រាំពីរល្វែង ប្រាសាទមង្គលលាថិ ប្រាសាទតុប)




    - ប្រាសាទស្ថិតនៅរង់តូច (ប្រាសាទធម្មនន្ទ ប្រាសាទចៅសាយទេវតា ប្រាសាទតាកែវ ប្រាសាទលាក់នាង ស្ពានថ្ម ប្រាសាទតានៃ ប្រាសាទតុប ប្រាសាទតាព្រហ្ម ប្រាសាទបន្ទាយក្តី ស្រះស្រង់ ប្រាសាទកុដិគូរ ប្រាសាទក្រវ៉ាន់ ប្រាសាទជុំ)

- ប្រាសាទស្ថិតនៅវង់ធំ (ប្រាសាទប្រែរូប ប្រាសាទតុប ប្រាសាទលាក់នាង ប្រាសាទមេបុណ្យខាងកើត ប្រាសាទតាសោម ប្រាសាទក្រោលគោ ប្រាសាទនាគព័ន្ធ ប្រាសាទព្រះខ័ន ប្រាសាទព្រៃ ប្រាសាទបន្ទាយព្រៃ ក្រោលរមាស ប្រាសាទទន្លេស្ងួត)
- ប្រាសាទដទៃទៀត (ប្រាសាទព្រៃប្រាសាទ ប្រាសាទបន្ទាយធំ ប្រាសាទទ ប្រាសាទមេបុណ្យខាងលិច ប្រាសាទអកយំ ប្រាសាទបន្ទាយសំរែ ប្រាសាទបន្ទាយស្រី ប្រាសាទបឹងមាលា)
- បារាយណ៍ទឹកថ្លា ភ្នំបូក ក្បាលស្ពាន ភ្នំគូលេន ភ្នំពើងតានាន់(ទេសភាពថ្មដុះ) រលួស (ប្រាសាទព្រះគោ ប្រាសាទបាគង ប្រាសាទលលៃ) ប្រាសាទភ្នំក្រោម ភូមិវប្បធម៌។

សៀមរាបអង្គរគឺជាតំបន់ទេសចរណ៍ល្បីល្បាញបំផុតនៅព្រះរាជាណាចក្រកម្ពុជា ជាពិសេសប្រាសាទអង្គរវត្តដែលមានឈ្មោះល្បីនៅលើពិភពលោក ហើយមានទេសចរបរទេសជាច្រើនចង់មកទស្សនាស្ថាបត្យកម្មបុរាណដែលជាកេរ្តិ៍ដំណែលប្រវត្តិសាស្ត្ររបស់បុព្វបុរសខ្មែរ និងជាអច្ឆរិយវត្ថុដ៏អស្ចារ្យមួយនៅលើពិភពលោក។

- ***ខេត្តបាត់ដំបង*** ៖ ខេត្តបាត់ដំបងមានតំបន់ទេសចរណ៍ដូចជា៖ ប្រាសាទបាសែត ប្រាសាទបាណន់ ប្រាសាទវត្តឯកភ្នំ ប្រាសាទស្នឹង ភ្នំសំពៅ អាងកំពីងពួយ សេកសក ...។
- ***ខេត្តប៉ៃលិន*** ៖ ខេត្តប៉ៃលិនមានតំបន់ទេសចរណ៍ធម្មជាតិដូចជា៖ ភ្នំយ៉ាត ភ្នំកុយ វត្តរតនសោភ័ណ អូរអែប អូរតាវៅ ...។
- ***ខេត្តឧត្តរមានជ័យ*** ៖ ខេត្តឧត្តរមានជ័យមានតំបន់ទេសចរណ៍ធម្មជាតិនិងប្រវត្តិសាស្ត្រដូចជា អូរស្មាច់ តំបន់វប្បធម៌ខ្មែរក្រហម(ផ្ទះតាម៉ុក) ទឹកធ្លាក់ចំប៉ី(ទឹកធ្លាក់ល្អាងតាថង) ...។
- ***ខេត្តព្រះវិហារ*** ៖ តំបន់ទេសចរណ៍នៅខេត្តព្រះវិហារមាន៖ ប្រាសាទព្រះវិហារ ប្រាសាទកោះកេរ្តិ៍ ប្រាសាទបាកាន ឬប្រាសាទព្រះខាន់ ប្រាសាទនរាយ ប្រាសាទភ្នំព្រលាន ប្រាសាទនាគបួស ប្រាសាទឈូក ប្រាសាទគោកបេង ជើងភ្នំត្បែងវត្តបាក់កាំ វត្តពើងព្រះគោ ...។
- ***ខេត្តកំពង់ធំ*** ៖ តំបន់ទេសចរណ៍ខេត្តកំពង់ធំមាន៖ ប្រាសាទសម្បូរព្រៃគុក ប្រាសាទគុហានគរ ភ្នំសន្ទុក ព្រៃប្រស់ វត្តប្រាសាទ វត្តកំពង់ធំ វត្តក្ដីដើម វត្តប្រាសាទអណ្តែត ...។
- ***ខេត្តបន្ទាយមានជ័យ*** ៖ តំបន់ទេសចរណ៍ខេត្តបន្ទាយមានជ័យមាន៖ ភ្នំបាក់ និងភ្នំជញ្ជាំងល្អាងភ្នំតូច អាងទឹកកងវ៉ា ប្រាសាទបន្ទាយឆ្មារ អាងទឹកត្រពាំងថ្ម ...។

## ២.៣. តំបន់ឆ្នេរ ឬតំបន់ភូមិភាគនិរតី

តំបន់ឆ្នេររួមមាន ខេត្តព្រះសីហនុ ខេត្តកំពត ខេត្តកោះកុង និងខេត្តកែប។

- ***តំបន់ទេសចរណ៍នៅខេត្តព្រះសីហនុ*** មាន៖ ឆ្នេរអូរឈើទាល ឆ្នេរសុខា ឆ្នេរប្រាំពីរជាន់ ឆ្នេរលំហែកាយ ឬឆ្នេរឯករាជ្យ ឆ្នេរដើមជ្រៃ កោះពស់ ភ្នំលើ ទឹកជ្រោះក្បាលឆាយ ឧទ្យានជាតិព្រះសីហនុរាម ...។
- ***តំបន់ទេសចរណ៍ខេត្តកំពត*** មាន៖ ភ្នំបូកគោ ទឹកឈូ ភ្នំកំពង់ត្រាច ព្រែកអំពិល ...។




- ***តំបន់ទេសចរណ៍ខេត្តកែប*** មាន៖ ឆ្នេរកែប ភ្នំសសៀ កោះទន្សាយ ...។
- ***តំបន់ទេសចរណ៍ខេត្តកោះកុង*** មាន៖ រមណីយដ្ឋានចាំយាម ពាមក្រសោប យុនឆាងយុនផែន ទឹកធ្លាក់តាតៃ ទឹកធ្លាក់ជីផាត កោះមូល ក្បាលឆាយ ឬកោះប៉ោ កោះស្ដេច ...។

## ២.៤. តំបន់អេកូទេសចរណ៍ភូមិភាគឦសាន និងបឹងទន្លេសាប

### *ក. ភូមិភាគឦសាន*

ភូមិភាគឦសាន គឺជាតំបន់ភ្នំ និងខ្ពង់រាប។ តំបន់នេះរួមមាន ខេត្តក្រចេះ ខេត្តស្ទឹងត្រែង ខេត្តរតនគិរី និងខេត្តមណ្ឌលគិរី។

- ***តំបន់ទេសចរណ៍ខេត្តក្រចេះ*** មាន៖ ភ្នំសំបុក វត្តសសរ១០០ កាំពី ភ្នំសំបុក តំបន់វប្បធម៌ភ្នំព្រះ ភ្នំសុពណ៌កាឡី កោះផ្ដៅ។
- ***តំបន់ទេសចរណ៍ខេត្តស្ទឹងត្រែង*** មាន៖ អូរពងមាន់ ថាលាបរិវាត់ រមណីយដ្ឋានកោះខ្សាច់ រមណីដ្ឋានទឹកធ្លាក់អូរចាប អាងត្រីផ្សោតអន្លង់ស្វាយធំ។
- ***តំបន់ទេសចរណ៍ខេត្តរតនគិរី*** មាន៖ បឹងយក្សលោម ទឹកធ្លាក់កាចាញ ទឹកធ្លាក់កាទៀង ទឹកធ្លាក់ចាអ៊ុង ភ្នំឥសីបតម: ឬភ្នំស្វាយ វាលរំប្លង់។

តំបន់ទេសចរណ៍ខេត្តមណ្ឌលគិរីមាន៖ ទឹកជ្រោះប៊ូស្រា ទឹកជ្រោះសែនមនោរម្យ ទឹកជ្រោះរមនា ទឹកជ្រោះជ្រៃធំ ឆ្នេរទន្លេ ចម្ការស្រល់ ឆ្នេរទន្លេ រមណីយដ្ឋានភ្នំដោះក្រមុំ ជម្រកសត្វព្រៃភ្នំណាំលៀរ។




## ២. បឹងទន្លេសាប

តំបន់ទេសចរណ៍នៅបឹងទន្លេសាបមាន៖ ភូមិបណ្តែតទឹកលើបឹងទន្លេសាប (មុខផ្សារក្រោមខេត្តកំពង់ឆ្នាំង ចុងឃ្នាស ព្រែកទាល់ ...) តំបន់សំបុកសត្វស្លាបលើបឹងទន្លេសាប(ព្រែកទាល់...)។

# ៣. សក្តានុពលទេសចរណ៍

## ៣.១. ភ្នំពេញ និងតំបន់ជុំវិញ

រាជធានីភ្នំពេញគឺជាបេះដូង និងជាមជ្ឈមណ្ឌលនយោបាយ ពាណិជ្ជកម្ម វប្បធម៌ និង ទេសចរណ៍នៃកម្ពុជាព្រះរាជាណាចក្រអច្ឆរិយៈ។ ភ្នំពេញជារាជធានីដ៏ចំណាស់មួយនៅអាស៊ី និងមានទីតាំងជាយុទ្ធសាស្ត្រនៅចំណុចប្រសព្វបួនមុខនៃទន្លេមេគង្គ។ ភ្នំពេញតភ្ជាប់ជាមួយពិភពលោកតាម



*ព្រះបរមរាជវាំង*



*សារមន្ទីរជាតិ*

គ្រប់មធ្យោបាយដឹកជញ្ជូនទេសចរណ៍ទាំងផ្លូវគោក ផ្លូវអាកាស ដែលមានព្រលានយន្តហោះអន្តរជាតិភ្នំពេញក្នុងការទទួលអ្នកដំណើរបានជាងមួយលាននាក់ក្នុងមួយឆ្នាំ។



*ទិដ្ឋភាពទីក្រុងភ្នំពេញ*

រាជធានីភ្នំពេញ ជាមជ្ឈមណ្ឌលប្រមូលផ្តុំនូវរតនសម្បត្តិ បេតិកភណ្ឌ វប្បធម៌ជាច្រើនដែលជាប្រភពធនធានដ៏សំខាន់សម្រាប់ការទាក់ទាញទេសចរដូចជា សារមន្ទីរជាតិ ព្រះបរមរាជវាំង វិមានឯករាជ្យ ទីតាំងប្រវត្តិសាស្ត្រវត្តភ្នំ សំណង់ស្ថាបត្យកម្មសម័យអាណានិគម និងវិមានឈ្នះឈ្នះ។ ជាងនេះទៅទៀត រាជធានីភ្នំពេញមានសណ្ឋាគារប្រណិត និងសេវាកម្មទេសចរណ៍ជាច្រើនប្រភេទ។ នៅតំបន់ជុំវិញរាជធានីក៏មានសក្តានុពលទាក់ទាញទេសចរណ៍វប្បធម៌ និងធម្មជាតិ ដោយភ្ជាប់ពីលក្ខណៈទេសចរណ៍ទីក្រុង ទេសចរណ៍ជនបទ និងកសិទេសចរណ៍ ពិសេសសម្រាប់អ្នករស់នៅទីក្រុង និងភ្ញៀវបរទេស។



*វិមានឯករាជ្យ*



*វិមានឈ្នះ-ឈ្នះ*



វត្តភ្នំដូនពេញ



ផ្សារធំថ្មី

រាជធានីភ្នំពេញ និងតំបន់ជុំវិញនៅមានសក្តានុពលច្រើនដើម្បីពន្យាការស្នាក់នៅរបស់ភ្ញៀវបាន យូរដូចជា ការទស្សនាកម្សាន្តលើនាវាតាមដងទន្លេមេគង្គ ទន្លេសាប ទន្លេចតុមុខ។ ការទស្សនាសហគមន៍ប្រជាជននៅតាមដងទន្លេ ភូមិសិប្បកម្ម តម្បាញ ចម្លាក់ប្រាក់ តំបន់កសិទេសចរណ៍ និងតំបន់បេតិកភណ្ឌវប្បធម៌។ ការកម្សាន្តនៅពេលរាត្រីតាមដងទន្លេចតុមុខ ផ្សាររាត្រីប្រកបដោយសុវត្ថិភាព និងការទស្សនាមណ្ឌលពាណិជ្ជកម្ម និងផ្សារលក់ដូរ។ល។

## ៣.២. សៀមរាបអង្គរ និងតំបន់ជុំវិញ




រូបភាពផែនទីតំបន់អង្គរ

តំបន់សៀមរាបអង្គរ គឺជាតំបន់ទាក់ទាញទេសចរណ៍បែបវប្បធម៌ដ៏ល្បីនៅប្រទេសកម្ពុជា។ ភាពទាក់ទាញផ្នែកវប្បធម៌រួមមានប្រាសាទ បេតិកភណ្ឌវប្បធម៌ ស្ថាបត្យកម្ម ភូមិបុរាណ តំបន់សាសនា

សកម្មភាពកសិកម្មដែលគួរឱ្យចាប់អារម្មណ៍នូវឧបករណ៍ចាស់ៗ មុខរបរចិញ្ចឹមជីវិតបែបបុរាណ សកម្មភាពជីវិតប្រចាំថ្ងៃ ប្រពៃណី និងទំនៀមទម្លាប់អ្នកស្រុក រឿងព្រេង សម្លៀកបំពាក់ប្រពៃណី អាហារប្រចាំតំបន់ ទំនៀមទម្លាប់ពិសេស ពិធីបុណ្យ សិប្បកម្ម វត្ថុបុរាណ ការសម្តែងសិល្បៈ តំបន់ប្រវត្តិសាស្ត្រ អគារសារមន្ទីរ និងវប្បធម៌ផ្សេងៗទៀត។


ប្រាសាទអង្គរវត្ត


ខ្លោងទ្វារអង្គរធំ


ស្រះស្រង់


ប្រាសាទបន្ទាយស្រី

ក្រៅពីធនធានវប្បធម៌ សៀមរាបអង្គរ និងតំបន់ជុំវិញក៏នៅមានធនធានធម្មជាតិ និងកែច្នៃដូចជា ភ្នំ បឹង(អាងទឹកកំពីងពួយ អាងទឹកត្រពាំងថ្ម) ទឹកធ្លាក់រមណីយដ្ឋាន... ក្នុងការទាក់ទាញទេសចរទៅទស្សនាកម្សាន្ត។


ប្រាសាទបាយ័ន


ប្រាសាទមេបុណ្យ

## ៣.៣. តំបន់ឆ្នេរ ឬតំបន់ភូមិភាគនិរតី



*ទិដ្ឋភាពនៅតំបន់ឆ្នេរសមុទ្រ*

តំបន់ឆ្នេរនៃប្រទេសកម្ពុជាមានធនធានធម្មជាតិជាច្រើនដែលជាសក្តានុពលទាក់ទាញទេសចរ ដូចជា សត្វសមុទ្រ កោះ ឆ្នេរខ្សាច់ពណ៌ស ព្រៃកោងកាង ស្រែអំបិល និងផ្កាថ្មជាដើម។ តំបន់ឆ្នេរផ្តល់ឱ្យទេសចរនូវបទពិសោធន៍មួយដែលខុសប្លែកពីតំបន់ផ្សេងៗទៀតនៅក្នុងប្រទេសដោយសារលក្ខណៈប្លែកពីគេនៃធម្មជាតិរបស់វា។ នៅតាមបណ្តោយឆ្នេរ មានវត្ថុទាក់ទាញទេសចរជាច្រើនដូចជា ឆ្នេរខ្សាច់



*រមណីយដ្ឋានកោះសង្ហា*



*រមណីយដ្ឋានតាតៃ*

ដ៏ល្អ ខ្យល់អាកាសបរិសុទ្ធ ទឹកសមុទ្រដ៏ថ្លា និងខ្សាច់ពណ៌ស កោះតូចៗដ៏ស្អាតជាង៦០ និងជីវិតសត្វសមុទ្រជាច្រើន ព្រៃកោងកាងជាច្រើនប្រភេទ ឧទ្យានជាតិ និងវប្បធម៌ក្នុងតំបន់។ លើសពីនេះទៀត ដំណាំដូងប្រេង កៅស៊ូ ដូង ម្រេច ទុរេន និងធញ្ញជាតិផ្សេងទៀតក៏មានដាំនៅតំបន់នេះដែរ។

ដោយសារសក្តានុពលនៃធនធានខាងលើ តំបន់ឆ្នេរក្លាយជាប៉ូលដ៏សំខាន់ សម្រាប់ស្រូបទាញទេសចរជាតិ និងអន្តរជាតិ។ ឆ្នេរសមុទ្រកម្ពុជាត្រូវបានក្លាយជាសមាជិកនៃក្លឹបឆ្នេរសមុទ្រដ៏ស្អាតបំផុតលើពិភពលោក ហើយកិត្តិនាមនេះកំពុងលើកតម្កើងកិត្យានុភាពឆ្នេរសមុទ្រកម្ពុជា លើឆាកអន្តរជាតិ។

### ៣.៤. តំបន់អេកូទេសចរណ៍ភូមិភាគឦសាន និងបឹងទន្លេសាប

#### *ក. តំបន់អេកូទេសចរណ៍ភូមិភាគឦសាន*



*ទិដ្ឋភាពនៅតំបន់ភូមិភាគឦសាន*

ភូមិភាគឦសានភ្ជាប់គ្នាដោយខេត្ត៤គឺៈ ខេត្តក្រចេះ ស្ទឹងត្រែង រតនគិរី និងខេត្តមណ្ឌលគិរី។ តំបន់នេះមានសក្តានុពលទាក់ទាញផ្នែកអេកូទេសចរណ៍ ដោយផ្អែកលើមូលដ្ឋាន "សម្បត្តិវប្បធម៌ និងធនធានធម្មជាតិ" ពិសេសវប្បធម៌ ប្រពៃណីរស់នៅរបស់បងប្អូនជនជាតិដើមភាគតិច និងសត្វផ្សោតមេគង្គដ៏កម្រមានក្នុងលោក។ ក្រៅពីនេះភូមិភាគឦសានជាតំបន់សម្បូរព្រៃឈើ ភ្នំ ទឹកធ្លាក់ ជីវៈចម្រុះ តំបន់ការពារ ឧទ្យានជាតិ ដូចជាឧទ្យានជាតិវីរៈជ័យ តំបន់រ៉ាមសារ ទេសភាព អាកាសធាតុល្អ ពិសេសនៅខេត្តមណ្ឌលគិរី និងភាពសម្បូរបែបនៃសត្វព្រៃដែលជាប្រភពទាក់ទាញទេសចរយ៉ាងសំខាន់។ ឧទាហរណ៍ កន្លែងទេសចរណ៍ជាច្រើនដូចជា បឹងយក្សឡោមនៅខេត្តរតនគិរី ទឹកជ្រោះប៊ូស្រានៅខេត្តមណ្ឌលគិរី អន្លង់ផ្សោតកាំពីនៅខេត្តក្រចេះ ។



*សកម្មភាពទស្សនាផ្សោតមេគង្គ(ក្រចេះ)*



*ផ្សោតទន្លេ*


ផ្ទះជនជាតិភាគតិច


ជនជាតិភាគតិច


ទឹកជ្រោះប៊ូស្រា

### ខ. តំបន់អេកូទេសចរណ៍បឹងទន្លេសាប

ក្រៅពីតំបន់អេកូទេសចរណ៍នៅភូមិភាគឦសាន បឹងទន្លេសាបគឺជាតំបន់អេកូទេសចរណ៍ដ៏ធំមួយនៅព្រះរាជាណាចក្រកម្ពុជា។ បឹងទន្លេសាបមិនគ្រាន់តែជាផ្លូវទឹកសម្រាប់នាវាចរប៉ុណ្ណោះទេ តែថែមទាំងជាជង្រុកត្រីដ៏សម្បូរបែប និងសម្បូរទៅដោយជីវៈចម្រុះជាច្រើនប្រភេទ។ ក្រៅពីនេះតំបន់បឹងទន្លេសាបមានព្រៃលិចទឹក តំបន់ជម្រកសត្វស្លាប តំបន់នេសាទ ភូមិបណ្តែតទឹក។ល។ ធនធានខាងលើគឺជាសក្តានុពលដ៏សំខាន់ក្នុងការទាក់ទាញទេសចរមកធ្វើដំណើរកម្សាន្តតាមផ្លូវទឹក ទស្សនាភូមិអ្នកនេសាទ ភូមិបណ្តែតទឹក ព្រៃលិចទឹក តំបន់ជម្រកសត្វស្លាប។ល។

ក្រៅពីធនធានធម្មជាតិ វប្បធម៌ និងហេដ្ឋារចនាសម្ព័ន្ធផ្សេងៗ ការគ្រប់គ្រង និងការចូលរួមរបស់ប្រជាពលរដ្ឋ ទេសចរពិសេសអ្នកប្រកបអាជីវកម្ម និងសេវាកម្មក្នុងវិស័យទេសចរណ៍ មានសណ្ឋាគារផ្ទះសំណាក់ ទីកន្លែងកម្សាន្ត ភោជនីយដ្ឋាន ការដឹកជញ្ជូន... អនុវត្តតាមការណែនាំរបស់ក្រសួង





*តំបន់ទេសចរណ៍បឹងទន្លេសាប*

ទេសចរណ៍ និងអាជ្ញាធរមូលដ្ឋានដូចជាសេវាល្អ តម្លៃសមរម្យ គុណភាពល្អជាដើម។ ម៉្យាងទៀតប្រជាពលរដ្ឋនិងទេសចរទាំងអស់ចូលរួមថែរក្សា និងសម្អាតបរិស្ថានឱ្យបានស្អាត ដើម្បីទាក់ទាញ ទេសចរ។

ដោយមើលឃើញថា កម្ពុជាមានសក្តានុពលទេសចរណ៍ដូចខាងលើ បានជាក្រុមប្រឹក្សាភិបាលទេសចរណ៍ និងពាណិជ្ជកម្មសហភាពអឺរ៉ុបបានវាយតម្លៃ "កម្ពុជាជាប់ជាគោលដៅទេសចរណ៍ល្អបំផុតលើពិភពលោកសម្រាប់ឆ្នាំ២០១៦"។ ហើយក្នុងឱកាសនោះដែរ សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជាក៏បានទទួលរង្វាន់មេដាយជ្រើសតាំងជា "សមាជិកកិត្តិយសនៃបណ្ឌិតសភាទេសចរណ៍អឺរ៉ុប" នៅថ្ងៃទី២២ មិថុនា ឆ្នាំ២០១៦ផងដែរ។

**មេរៀនសង្ខេប**

***តំបន់ទេសចរណ៍នៅកម្ពុជាមានបួន*** តំបន់ធំៗគឺ

១. ភ្នំពេញ និងតំបន់ជុំវិញ

២. សៀមរាបអង្គរ និងតំបន់ជុំវិញ

៣. តំបន់ឆ្នេរ ឬតំបន់ភូមិភាគនិរតី

៤. តំបន់អេកូទេសចរណ៍នៅភូមិភាគឦសាន និងបឹងទន្លេសាប។

***សក្តានុពលទេសចរណ៍នៃតំបន់នីមួយៗ*** ៖

- **ភ្នំពេញ**ជាមជ្ឈមណ្ឌលប្រមូលផ្តុំនូវរតនសម្បត្តិ បេតិកភណ្ឌវប្បធម៌ មជ្ឈមណ្ឌលពាណិជ្ជកម្ម... ដូចជា សារមន្ទីរជាតិ ព្រះបរមរាជវាំង ទីតាំងប្រវត្តិសាស្ត្រ សណ្ឋាគារប្រណិត ផ្សារទំនើប និងសេវាកម្មទេសចរណ៍ជាច្រើនប្រភេទ។ នៅតំបន់ជុំវិញរាជធានីក៏មានធនធានវប្បធម៌ និងធម្មជាតិ កន្លែងកម្សាន្តធម្មជាតិ និងកែច្នៃ ភូមិសិប្បកម្ម តម្បាញចម្លាក់...ធនធានទាំងអស់នេះ គឺជាសក្តានុពលទាក់ទាញទេសចរទៅលេងកម្សាន្តទស្សនកិច្ច។ល។
- ***សៀមរាបអង្គរ និងតំបន់ជុំវិញ*** មានដូចជា ប្រាសាទ បេតិកភណ្ឌវប្បធម៌ ស្ថាបត្យកម្មបុរាណ តំបន់សាសនា វត្ថុបុរាណ តំបន់ប្រវត្តិសាស្ត្រ អគារ សារមន្ទីរ និងវប្បធម៌ផ្សេងៗ

ទៀត។ សៀមរាបអង្គរនិងតំបន់ជុំវិញក៏នៅមានធនធានធម្មជាតិ និងកែច្នៃ ដូចជាភ្នំ បឹង រមណីយដ្ឋាន និងសេវាកម្មទេសចរណ៍ជាច្រើនប្រភេទក្នុងការទាក់ទាញទេសចរ ទៅទស្សនាកម្សាន្ត។

- ***តំបន់ឆ្នេរ ឬតំបន់ភូមិភាគនិរតី*** មានដូចជា សត្វសមុទ្រ កោះ ឆ្នេរ ទឹកធ្លាក់ ភ្នំ ព្រៃកោងកាង និងផ្កាថ្មជាដើម។ ក្រៅពីធនធានធម្មជាតិ តំបន់ឆ្នេរមានកំពង់ផែអន្តរជាតិ រមណីយដ្ឋាន ឧទ្យានជាតិ វប្បធម៌ក្នុងតំបន់ សេវាកម្មទេសចរណ៍ផ្សេងៗ ដំណាំប្រចាំតំបន់ដូចជាដូង ម្រេច ទុរេន។ល។
- ***តំបន់អេកូទេសចរណ៍ភូមិភាគឦសាន និងបឹងទន្លេសាប***
  - ភូមិភាគឦសានមានដូចជា ប្រពៃណីរស់នៅរបស់បងប្អូនជនជាតិដើមភាគតិច ព្រៃឈើ ជីវៈចម្រុះ ឧទ្យានជាតិ តំបន់រ៉ែមសារ ទេសភាព ទឹកធ្លាក់ ភ្នំ និងភាពសម្បូរបែបនៃសត្វព្រៃ ដែលជាប្រភពទាក់ទាញទេសចរទៅកម្សាន្ត។
  - បឹងទន្លេសាបមាន ព្រៃលិចទឹក តំបន់ជម្រកសត្វស្លាប តំបន់នេសាទ ភូមិបណ្តែតទឹក ការកម្សាន្តតាមផ្លូវទឹក ការទស្សនាភូមិអ្នកនេសាទ។ល។

ក្រៅពីធនធានដូចខាងលើ ការគ្រប់គ្រង និងការចូលរួមរបស់ប្រជាពលរដ្ឋ ទេសចរ អ្នកប្រកបអាជីវកម្ម និងសេវាកម្មក្នុងវិស័យទេសចរណ៍មានសណ្ឋាគារ ផ្ទះសំណាក់ កន្លែងកម្សាន្ត ភោជនីយដ្ឋាន ការដឹកជញ្ជូន...អនុវត្តតាមការណែនាំរបស់ក្រសួងទេសចរណ៍និងអាជ្ញាធរមូលដ្ឋាន ដូចជាសេវាល្អ តម្លៃសមរម្យ។ល។ ម៉្យាងទៀតប្រជាពលរដ្ឋ និងទេសចរចូលរួមសម្អាតបរិស្ថានឱ្យបានស្អាតដើម្បីទាក់ទាញទេសចរ។

## សំណួរ

១. នៅកម្ពុជាតើគេបែងចែកតំបន់ទេសចរណ៍ជាប៉ុន្មានតំបន់? តំបន់អ្វីខ្លះ? ចូររៀបរាប់ឈ្មោះទីកន្លែងទេសចរណ៍ឱ្យបានដប់ក្នុងមួយតំបន់?

២. តើអ្វីជាសក្តានុពលទាក់ទាញទេសចរសំខាន់ជាងគេនៅតំបន់សៀមរាបអង្គរ? ចូរពន្យល់ពីសក្តានុពលនៃតំបន់នោះ។

៣. ចូរប្អូនបង្ហាញពីសក្តានុពលទេសចរណ៍នៅកន្លែងទេសចរណ៍មួយដែលប្អូនបានទៅលេងកម្សាន្តរួចពន្យល់ពីសក្តានុពលទេសចរណ៍នៅកន្លែងទេសចរណ៍នោះ?

# សេវាស្នាក់នៅទេសចរណ៍

(ទ្រឹស្ដី៤ម៉ោង អនុវត្ត៤ម៉ោង)

*សិក្សាមេរៀននេះចប់សិស្សអាច ៖*

- ឱ្យនិយមន័យសេវាកម្មស្នាក់នៅទេសចរណ៍
- ធ្វើចំណាត់ថ្នាក់សេវាស្នាក់នៅទេសចរណ៍តាមប្រភេទនីមួយៗ។

សេវាកម្មស្នាក់នៅជាធាតុមួយដ៏សំខាន់សម្រាប់ទេសចរណ៍។ សេវាកម្មស្នាក់នៅបានបំពេញសេចក្ដីត្រូវការសម្រាប់ការស្នាក់អាស្រ័យ និងផ្ដល់សេវាកម្មផ្សេងៗទៀតជាច្រើន ដែលស្ថិតនៅឆ្ងាយពីទីកន្លែងរស់នៅអចិន្ត្រៃយ៍នៃអ្នកទេសចរ។ គ្មានទីស្នាក់នៅគឺគ្មានទេសចរណ៍។

## ១. និយមន័យ

សេវាកម្មស្នាក់នៅ គឺជាសេវាកម្មរបស់មូលដ្ឋានអាជីវកម្ម សេវាកម្មទេសចរណ៍មួយចំនួន មានសណ្ឋាគារ ផ្ទះភ្ញៀវ ផ្ទះស្នាក់ ម៉ូតែល បឹងកាឡូ ផ្ទះជួល កន្លែងបោះជំរំ។ល។ ដែលផ្ដល់លទ្ធភាពដល់អ្នកដំណើរ ឬអ្នកទេសចរទទួល និងទិញសេវាកម្មផ្សេងៗដូចជា បន្ទប់ស្នាក់នៅ ម្ហូបអាហារ ភេសជ្ជៈ ឬសេវាដទៃទៀតដែលគេត្រូវការ។ ឧទាហរណ៍ សកម្មភាពកម្សាន្តសប្បាយ ប្រព័ន្ធព័ត៌មាន ភ្នាក់ងារទេសចរណ៍ សេវាកម្មដឹកជញ្ជូន សេវាកម្មហាត់ប្រាណ ម៉ាស្សាសុខភាព ស្ប៉ា និងសេវាកម្សាន្ត។

ការទិញសេវាកម្មនៅក្នុងមូលដ្ឋានអាជីវកម្មសេវាកម្មស្នាក់នៅ(បន្ទប់ស្នាក់នៅ និងសេវាកម្មរួមផ្សំដទៃទៀត) អាចធ្វើបានភ្លាមៗ ឬដោយការទិញកក់ទុកជាមុន។

## ២. ប្រភេទសេវាកម្មស្នាក់នៅទេសចរណ៍

សេវាកម្មស្នាក់នៅទេសចរណ៍មានច្រើនប្រភេទដូចជា៖

### ២.១. សណ្ឋាគារ




*ទិដ្ឋភាពសណ្ឋាគារដែលមានលំដាប់ខ្ពស់*

សណ្ឋាគារគឺជាអគារបង្កើតឡើងបម្រើការស្នាក់នៅ ដែលមានទីតាំងស្ថិតនៅក្នុងទីប្រជុំជនជាយក្រុង ឬតំបន់រមណីយដ្ឋាន និងអាចផ្តល់នូវសេវាពេញលេញដល់ភ្ញៀវដូចជា សេវាស្នាក់នៅ ភោជនីយដ្ឋាន សេវាបម្រើអាហារភ្ញៀវដល់បន្ទប់ សេវាបោកគក់ ហាងទំនិញ កន្លែងរៀបចំពិធីជប់លៀង សាលប្រជុំ និងចំណតរថយន្ត។



*សណ្ឋាគារ*



*បន្ទប់សណ្ឋាគារ*

### ២.២. ផ្ទះភ្ញៀវ

ផ្ទះភ្ញៀវ ជាអគារដែលមានបំពាក់សម្ភារៈសម្រាប់ស្នាក់នៅ និងផ្តល់សេវាមានកម្រិត។ នៅប្រទេសកម្ពុជាយើងមានទម្លាប់ហៅ ផ្ទះភ្ញៀវថាជា "ផ្ទះសំណាក់"។ ផ្ទះភ្ញៀវអាចជាអគារតែមួយជាន់ផ្ទាល់ដី ឬជាអគារច្រើនជាន់។ ជាទូទៅស្តង់ដាក្នុងបន្ទប់របស់ផ្ទះភ្ញៀវមានតែគ្រែប៉ុណ្ណោះ។

### ២.៣. ម៉ូតែល

ម៉ូតែលត្រូវបានទទួលស្គាល់ថាជាអគារស្នាក់នៅដែលបម្រើសេវាកម្មមានកម្រិត សម្រាប់អ្នកដំណើរ ឬទេសចរ ជាទូទៅស្ថិតនៅតាមដងផ្លូវជាតិ ហើយមានចំណតរថយន្តធំទូលាយ។ ពាក្យម៉ូតែល (Motel) នេះក្លាយមកពីពាក្យ Motorists Hotel ប្រែថាផ្ទះសំណាក់សម្រាប់អ្នកបើកបររថយន្ត។ ម៉ូតែលទីមួយលើពិភពលោក ត្រូវបានបង្កើតឡើងនាឆ្នាំ ១៩១៣ នៅរដ្ឋ អារីហ្សូណា (Arizona) នៃសហរដ្ឋអាមេរិច។ លុះដល់ឆ្នាំ ១៩៣០ ទើបម៉ូតែលបានសាយភាយពាសពេញពិភពលោក។ នៅស្រុកយើងពុំសូវមានម៉ូតែលទេ ដោយសារចំងាយផ្លូវខ្លីពីទីក្រុងមួយទៅទីក្រុងមួយទៀត។ ប្រភេទម៉ូតែលមានដូចជា: ម៉ូតែលតាមផ្លូវ ម៉ូតែលទីក្រុង ម៉ូតែលវិស្សមកាល។



*ម៉ូតែល*



*បន្ទប់ម៉ូតែល*

## ២.៤. ប៊ឹងកាឡូ



ប៊ីងកាឡូ



បន្ទប់ប៊ីងកាឡូ

ប៊ឹងកាឡូជាអគារដាច់ដោយឡែកៗពីគ្នាឬជាប់គ្នា ស្ថិតនៅជាន់ផ្ទាល់ដី ជាទូទៅគេច្រើនប្រទះឃើញប៊ឹងកាឡូមាននៅតាមរមណីយដ្ឋានធម្មជាតិដូចជា នៅមាត់បឹង មាត់សមុទ្រ ជើងភ្នំ លើភ្នំ ...។ ប៊ឹងកាឡូមានបន្ទប់ស្នាក់នៅជាច្រើន។ ក្នុងប៊ឹងកាឡូអាចមានសម្បទាទេសចរណ៍ជាច្រើនផ្សេងទៀត ដូចជា អាងហែលទឹក ភោជនីយដ្ឋាន កន្លែងហាត់កីឡា ហាងលក់វត្ថុអនុស្សាវរីយ៍ផលិតក្នុងស្រុកជាដើម។

## ២.៥. ផ្ទះស្នាក់

ជាកន្លែងផ្តល់សេវាកម្មស្នាក់នៅដែលមានស្តង់ដា និងសម្បទាកម្រិតមធ្យម មានន័យថាផ្តល់សេវាកម្មតិចជាងសណ្ឋាគារ និងជាពិសេសបម្រើសេវាផ្តល់បន្ទប់ច្រើនជាងសេវាដទៃទៀត។ ពេលខ្លះអាចមានភ្ជាប់នឹងការបម្រើអាហារ និងភេសជ្ជៈ។

- ***ផ្ទះស្នាក់សហគមន៍*** គឺជាកន្លែងដែលភ្ញៀវស្នាក់នៅជាមួយគ្រួសារម្ចាស់ផ្ទះ និងទទួលបានបទពិសោធន៍ពីការរស់នៅប្រចាំថ្ងៃពីគ្រួសារម្ចាស់ផ្ទះ និងសហគមន៍ដោយផ្ទាល់ ឬដោយប្រយោល។
- ***ផ្ទះស្នាក់ជនបទ*** គឺជាប្រភេទនៃបន្ទប់ស្នាក់នៅមួយបែបនៅតាមផ្ទះ ឬលំនៅដ្ឋានប្រជាពលរដ្ឋនៅតាមកសិដ្ឋាន ចម្ការ ឬវាលស្រែតាមតំបន់ជនបទដែលម្ចាស់កសិដ្ឋាន ម្ចាស់ចម្ការ ឬប្រជាកសិករធ្វើការរៀបចំឱ្យមានសេវាកម្មស្នាក់នៅ និងម្ហូបអាហារ(ពិសេសអាហារពេលព្រឹក) សម្រាប់ទទួលភ្ញៀវទេសចរមកវិស្សមកាល ឬដំណើរកម្សាន្តដែលមកទស្សនាកម្សាន្តតំបន់នោះចាប់ពី១យប់ ឬអ្នកបម្រើការស្ម័គ្រចិត្តដែលមកបំពេញភារកិច្ចលក្ខណៈបណ្តោះអាសន្ននៅតាមសហគមន៍ និងជនបទ។
- ***ផ្ទះស្នាក់ទីក្រុង*** គឺជាប្រភេទនៃបន្ទប់ស្នាក់នៅមួយបែបនៅតាមផ្ទះ ឬលំនៅដ្ឋានប្រជាពលរដ្ឋនៅទីក្រុង ឬតាមទីប្រជុំជន ដែលម្ចាស់ផ្ទះធ្វើការរៀបចំឱ្យមានសេវាកម្មស្នាក់នៅ និងម្ហូបអាហារ(ពិសេសអាហារពេលព្រឹក) សម្រាប់ទទួលភ្ញៀវទេសចរធ្វើវិស្សមកាល ឬទស្សនាកម្សាន្តតំបន់នោះចាប់ពី១យប់ ឬអ្នកបម្រើការស្ម័គ្រចិត្តដែលមកបំពេញភារកិច្ចលក្ខណៈបណ្តោះអាសន្ននៅទីក្រុង ឬទីប្រជុំជន។

សេវាកម្មស្នាក់នៅទេសចរទាំងឡាយ សុទ្ធតែមានចំណាត់ប្រភេទ និងចំណាត់ថ្នាក់ដែលផ្តល់ភាពងាយស្រួលសម្រាប់ការគ្រប់គ្រង។ ឧទាហរណ៍ សម្រាប់សណ្ឋាគារចំណាត់ថ្នាក់ត្រូវបានកំណត់ដោយសញ្ញាផ្កាយ១រហូតដល់ផ្កាយ៥ ឬលេខរ៉ូម៉ាំងពីលេខ I រហូតដល់លេខ V។

**មេរៀនសង្ខេប**

- ***និយមន័យ***

សេវាកម្មស្នាក់នៅទេសចរណ៍ គឺជាមូលដ្ឋានអាជីវកម្ម មានដូចជា សណ្ឋាគារ ផ្ទះភ្ញៀវ ផ្ទះស្នាក់ ម៉ូតែល បឹងកាឡូ ផ្ទះជួល កន្លែងបោះជំរំ...។

- ***សណ្ឋាគារ***

សណ្ឋាគារគឺជាអគារបម្រើការស្នាក់នៅ ស្ថិតនៅក្នុងទីប្រជុំជន ជាយក្រុង ឬតំបន់រមណីយដ្ឋាន។ សណ្ឋាគារផ្តល់សេវា ស្នាក់នៅ ភោជនីយដ្ឋាន បម្រើអាហារ បោកគក់ ហាងទំនិញ កន្លែងជប់លៀង សាលប្រជុំ និងចំណតរថយន្ត។

- ***ផ្ទះភ្ញៀវ***

ផ្ទះភ្ញៀវ ជាអគារដែលមានបំពាក់សម្ភារៈស្នាក់នៅ និងសេវាមានកម្រិត។ ផ្ទះភ្ញៀវអាចជាអគារតែមួយជាន់ផ្ទាល់ដី ឬជាអគារច្រើនជាន់ បន្ទប់របស់ផ្ទះភ្ញៀវមានតែគ្រែប៉ុណ្ណោះ។

- ***ម៉ូតែល***

ម៉ូតែលជាអគារស្នាក់នៅដែលបម្រើសេវាកម្មមានកម្រិត សម្រាប់អ្នកដំណើរ ឬទេសចរ។ ជាទូទៅម៉ូតែលស្ថិតនៅតាមដងផ្លូវជាតិ ហើយមានចំណតរថយន្តធំទូលាយ។ ប្រភេទម៉ូតែលមានដូចជា: ម៉ូតែលតាមផ្លូវ ម៉ូតែលទីក្រុង ម៉ូតែលវិស្សមកាល។

- ***បឹងកាឡូ*** ជាអគារដាច់ដោយឡែកៗពីគ្នាក្នុងបរិវេណតែមួយ បង្កើតឡើងបម្រើឱ្យការស្នាក់នៅ និងអាចមានច្រើនយូនីត(Unit) ក្នុងអគារតែមួយ ហើយភាគច្រើនត្រូវបានរៀបចំឡើងក្នុងតំបន់ទេសចរណ៍។
- ***ផ្ទះស្នាក់*** : ជាកន្លែងផ្តល់សេវាកម្មស្នាក់នៅកម្រិតមធ្យម។ ផ្ទះស្នាក់ចែកជា ៖
  - ***ផ្ទះស្នាក់សហគមន៍*** គឺជាកន្លែងដែលភ្ញៀវស្នាក់នៅជាមួយគ្រួសារម្ចាស់ផ្ទះ។
  - ***ផ្ទះស្នាក់ជនបទ*** គឺជាប្រភេទនៃបន្ទប់ស្នាក់នៅមួយបែបនៅតាមផ្ទះ ឬលំនៅដ្ឋានប្រជាពលរដ្ឋនៅតាមកសិដ្ឋាន ចម្ការ ឬវាលស្រែតាមតំបន់ជនបទ។
  - ***ផ្ទះស្នាក់ទីក្រុង*** គឺជាប្រភេទនៃបន្ទប់ស្នាក់នៅមួយបែបនៅតាមផ្ទះ ឬលំនៅដ្ឋានប្រជាពលរដ្ឋនៅទីក្រុង ឬតាមទីប្រជុំជន។

## សំណួរ

១. ចូរឱ្យនិយមន័យសេវាស្នាក់នៅទេសចរណ៍។

២. តើសណ្ឋាគារបម្រើឱ្យសេវាស្នាក់នៅទេសចរណ៍ដូចម្តេច?

៣. តើផ្ទះស្នាក់បម្រើឱ្យសេវាស្នាក់នៅទេសចរណ៍ដូចម្តេច?

៤. តើម៉ូតែលបម្រើឱ្យសេវាស្នាក់នៅទេសចរណ៍ដូចម្តេច? ម៉ូតែលបែងចែកជាប្រភេទអ្វីខ្លះ?

៥. តើសេវាកម្មស្នាក់នៅទេសចរណ៍ផ្សេងៗមានអ្វីខ្លះ?

# សេវាអាហារ និងភេសជ្ជៈ

**(ទ្រឹស្តី២ម៉ោង អនុវត្ត២ម៉ោង)**

### *សិក្សាមេរៀននេះចប់សិស្សអាចៈ*

- រៀបរាប់ប្រភេទភោជនីយដ្ឋានទេសចរណ៍ អាហារដ្ឋានទេសចរណ៍ និងសេវាកម្សាន្តទេសចរណ៍
- ពន្យល់សេវាកម្សាន្តទេសចរណ៍សម្រាប់មនុស្សពេញវ័យ។

សេវាម្ហូបអាហារ និងភេសជ្ជៈ ជាឧស្សាហកម្មធំមួយសម្រាប់ទេសចរណ៍ និងការធ្វើដំណើរជារៀងរាល់ថ្ងៃ។ នៅក្នុងពិភពលោកមនុស្សរាប់សិបលាននាក់ បានទទួលសេវាភោជនីយដ្ឋានមានលក្ខណៈគ្រួសារ កន្លែងលក់អាហាររហ័សទាន់ចិត្ត និងអាហារដែលបម្រើក្នុងសណ្ឋាគារ។ អាហារ និងភេសជ្ជៈមួយចំនួនបានពឹងផ្អែកទៅលើវិស័យទេសចរណ៍ ជាពិសេសក្នុងទីតាំងកម្សាន្តតំបន់ទេសចរណ៍ និងរមណីយដ្ឋាន។



*ភោជនីយដ្ឋាន*



*មុខម្ហូបប្រចាំហាង*



*ភោជនីយដ្ឋានតាមកាណូត ឬកប៉ាល់*



*មុខម្ហូបសម្រាប់ភ្ញៀវ*

## ១. កម្រិតភោជនីយដ្ឋាន

ភោជនីយដ្ឋានឈរជួរទីមួយក្នុងការផ្តល់អាហារ និងភេសជ្ជៈដល់ភ្ញៀវដែលស្ថិតក្នុងសេវាបម្រើកម្រិតខ្ពស់។ ក្នុងបញ្ជីរាយមុខម្ហូប គេប្រទះឃើញមានរាយឈ្មោះមុខម្ហូបច្រើនប្រភេទដូចជា ម្ហូបត្រជាក់ ក្តៅ បង្អែម ផ្លែឈើ ព្រមទាំងភេសជ្ជៈគ្រប់ប្រភេទ(ភេសជ្ជៈគ្មានជាតិអាល់កុល និងភេសជ្ជៈមានជាតិអាល់កុល) ដែលអាចឱ្យភ្ញៀវជ្រើសរើសបានតាមចំណង់ចំណូលចិត្តរបស់ភ្ញៀវ។

ភោជនីយដ្ឋានទេសចរណ៍គឺជាអាជីវកម្មបម្រើសេវាម្ហូបអាហារ និងភេសជ្ជៈដែលមានអ្នកបម្រើប្រកបដោយភាពទទួលខុសត្រូវខ្ពស់នៅគ្រប់ទីកន្លែង និងបម្រើឱ្យទេសចរណ៍ជាធំ។

ប្រភេទភោជនីយដ្ឋានមានដូចជា៖

### ១.១. ភោជនីយដ្ឋានខ្នាតធំ

ជាអាជីវកម្មបម្រើសេវាម្ហូបអាហារ ភេសជ្ជៈដែលមានអ្នកបម្រើ មានម្ហូបអាហារ និងភេសជ្ជៈច្រើនមុខសម្រាប់ជ្រើសរើស សម្ភារៈទំនើប ការបម្រើសេវាកម្រិតខ្ពស់តាមលក្ខណៈស្តង់ដា មានបម្រើអាហារច្រើនពេល និងរៀបចំបម្រើក្នុងពិធីផ្សេងៗ(មានការប្រគុំតន្ត្រីកំដរនៅពេលល្ងាច យប់ ឬគ្មានការប្រគុំតន្ត្រី)។

### ១.២. ភោជនីយដ្ឋានខ្នាតមធ្យម

មានបម្រើសេវាម្ហូបអាហារចម្អិនស្រាប់ បម្រើដោយសេរី មានលក់នំ ភេសជ្ជៈគ្មានជាតិស្រវឹង ឬមានជាតិស្រវឹងតិចដែលរៀបចំនៅក្បែរអតិថិជន។

### ១.៣. ភោជនីយដ្ឋានខ្នាតតូច

មានផ្តល់ម្ហូបអាហារ ភេសជ្ជៈគ្មានជាតិស្រវឹង ឬមានជាតិស្រវឹងតិច ដែលមុខម្ហូបមានកំណត់ទៅតាមបណ្ណមុខម្ហូប ចំនួនកៅអីក្រោម១០០ គ្មានការប្រគុំតន្ត្រី ហើយពុំមានសម្ភារៈទំនើប។




*អាហារដ្ឋាន*



*ភោជនីយដ្ឋាន*

## ២. សេវាអាហារដ្ឋានទេសចរណ៍

អាហារដ្ឋានទេសចរណ៍ ជាអាជីវកម្មផ្តល់សេវាម្ហូបអាហារ ភេសជ្ជៈ ដែលមានអ្នកបម្រើ ឬបម្រើដោយខ្លួនឯង។ អាហារដ្ឋានខ្លះមានបម្រើច្រើនពេល ខ្លះមានតែមួយពេល ឬពីរពេល។ អាហារដ្ឋានប្រភេទនេះមាននៅតាម សាលារៀន អន្តេវាសិកដ្ឋាន សណ្ឋាគារ រោងចក្រ សម្រាប់សិស្ស និស្សិត ព្រម

ទាំងបុគ្គលិកដែលធ្វើការនៅទីនោះប៉ុណ្ណោះ។ ប៉ុន្តែកន្លែងខ្លះ ភ្ញៀវខាងក្រៅក៏អាចចូលទៅទទួលទានបានដែរ។

## ៣. សេវាកម្សាន្តទេសចរណ៍

នៅតំបន់ទេសចរណ៍ត្រូវយកចិត្តទុកដាក់រៀបចំ និងអភិវឌ្ឍឱ្យបានល្អ និងសម្បូរបែបនូវសេវាកម្សាន្ត ហើយមានគុណសម្បត្តិទាក់ទាញខ្ពស់ អាចទទួលយកបានសម្រាប់ទេសចរទាំងឡាយ។ ការបង្កើតសេវាកម្សាន្តទេសចរណ៍ សំដៅដល់ទីតាំងសេវាកម្មដែលធ្វើអាជីវកម្មបម្រើឱ្យការសម្រាកលំហែ និងកម្សាន្តតាមគោលបំណងទេសចរណ៍ស្របច្បាប់ ហើយប្រភេទអាជីវកម្មទាំងនោះត្រូវបានកំណត់ដោយរដ្ឋមន្ត្រីក្រសួងទេសចរណ៍។ មណ្ឌលកម្សាន្តទេសចរណ៍ដែលមានសេវាកម្សាន្ត គឺមានគោលបំណងបំពេញការកម្សាន្តរបស់ភ្ញៀវ។

## ៤. សេវាកម្សាន្តទេសចរណ៍សម្រាប់មនុស្សពេញវ័យ

សេវាកម្សាន្តទេសចរណ៍សម្រាប់មនុស្សពេញវ័យមាន៖

### ៤.១. រង្គសាល

រង្គសាល គឺជាកន្លែងដែលភ្ញៀវមកកម្សាន្តនាពេលរាត្រី។ នៅក្នុងរង្គសាលមានសេវាកម្សាន្តសម្រាប់បម្រើភ្ញៀវដូចជាការលេងភ្លេងកំដរ ការរាំបង្ហាញភ្ញៀវទស្សនា កម្មវិធីផ្សេងៗ ភេសជ្ជៈគ្រប់ប្រភេទ ព្រមទាំងអាហារសម្រន់ និងម្ហូបអាហារបន្ទាប់បន្សំ។

### ៤.២. ឌីស្កូ

ឌីស្កូជាកន្លែងដែលភ្ញៀវមករាំកម្សាន្តនាពេលរាត្រី។ នៅក្នុងឌីស្កូមានតែកន្លែងរាំកម្សាន្ត ភេសជ្ជៈគ្រប់ប្រភេទបម្រើភ្ញៀវ និងម្ហូបអាហារបន្ទាប់បន្សំ។

### ៤.៣. ខារ៉ាអូខេ

ខារ៉ាអូខេមានប្រភពមកពីប្រទេសជប៉ុនសម្រាប់ភ្ញៀវមកកម្សាន្តពេលរាត្រី។ នៅក្នុងខារ៉ាអូខេមានសេវាកម្សាន្តដូចជា ការច្រៀងលេងកម្សាន្តដោយមានម៉ាស៊ីនចាក់សាច់ភ្លេងសុទ្ធអមជាមួយ ហើយភ្ញៀវអាចទទួលទានភេសជ្ជៈគ្រប់ប្រភេទ និងគ្រឿងក្លែមបន្តិចបន្តួចបាន។

### ៤.៤. ភៀរហ្គាឌិន

ជាភោជនីយដ្ឋានដែលបម្រើភេសជ្ជៈគ្រប់ប្រភេទ និងមុខម្ហូបអាហារមានកំណត់ ព្រមទាំងមានតន្ត្រីកំដរសម្រាប់ភ្ញៀវជាតិ អន្តរជាតិច្រៀង និងស្តាប់កម្សាន្ត។

### ៤.៥. ប៊ីវាយអូ

ប៊ីវាយអូ គឺជាកន្លែងកម្សាន្តនាពេលរាត្រី។ ភ្ញៀវមកកម្សាន្តដោយស្តាប់ភ្លេង ទស្សនាការរាំបង្ហាញកម្មវិធីផ្សេងៗ។ ចំពោះភេសជ្ជៈ បើភ្ញៀវចង់ទទួលទាន គេតម្រូវឱ្យភ្ញៀវទិញយកមកពីហាងខាងក្រៅចូលមកក្នុងហាង ដោយគ្រាន់តែបង់ថ្លៃសំបុត្រសម្រាប់ចូលប៉ុណ្ណោះ។ ហាងប្រភេទខ្លះ គេគិតថ្លៃទៅលើចំនួនដបស្រាដែលភ្ញៀវទិញមកផងដែរ។ សេវាកម្សាន្តទេសចរណ៍សម្រាប់មនុស្សពេញវ័យ គឺ

ជាទីតាំងសេវាកម្មទាំងឡាយដែលធ្វើអាជីវកម្មបម្រើឱ្យការសម្រាកលំហែ និងកម្សាន្ត សម្រាប់មនុស្សពេញវ័យ ដែលប្រភេទអាជីវកម្មទាំងនោះត្រូវបានកំណត់ដោយអនុក្រឹត្យ។

**មេរៀនសង្ខេប**

- ***ភោជនីយដ្ឋានទេសចរណ៍*** គឺជាអាជីវកម្មបម្រើសេវាម្ហូបអាហារ និងភេសជ្ជៈ ដែលមានអ្នកបម្រើប្រកបដោយភាពទទួលខុសត្រូវខ្ពស់នៅគ្រប់ទីកន្លែង និងបម្រើឱ្យទេសចរណ៍ជាធំ មានដូចជា៖ ភោជនីយដ្ឋានខ្នាតធំ ខ្នាតមធ្យម និងខ្នាតតូច។
- ***សេវាអាហារដ្ឋានទេសចរណ៍*** ជាអាជីវកម្មផ្តល់ម្ហូបអាហារ ភេសជ្ជៈដែលមានអ្នកបម្រើ ឬបម្រើដោយខ្លួនឯង និងការផ្តល់សេវាម្ហូបអាហារ ភេសជ្ជៈមានកំណត់។ ភ្ញៀវខាងក្រៅក៏អាចចូលទៅទទួលទានបានដែរ។
- ***សេវាកម្សាន្តទេសចរណ៍*** សំដៅដល់ទីតាំងសេវាកម្មដែលធ្វើអាជីវកម្មបម្រើឱ្យការសម្រាកលំហែ និងកម្សាន្តតាមគោលបំណងទេសចរណ៍ស្របច្បាប់។
- ***សេវាកម្សាន្តទេសចរណ៍សម្រាប់មនុស្សពេញវ័យ*** សំដៅដល់សេវាកម្មទាំងឡាយដែលបើកអាជីវកម្ម បម្រើការស្នាក់នៅ លំហែកម្សាន្តសម្រាប់មនុស្សពេញវ័យដូចជា រង្គសាលឌីស្កូ ខារ៉ាអូខេ បីវាយអូ។

## សំណួរ

១. តើសេវាភោជនីយដ្ឋានទេសចរណ៍ជាអ្វី?

២. គេបែងចែកភោជនីយដ្ឋានជាប៉ុន្មានប្រភេទ?
ចូររៀបរាប់ពីប្រភេទនីមួយៗ។

៣. ដូចម្តេចដែលហៅថាអាហារដ្ឋានទេសចរណ៍?
អាហារដ្ឋានទេសចរណ៍មានប៉ុន្មានប្រភេទ? អ្វីខ្លះ?

៤. តើសេវាកម្សាន្តទេសចរណ៍សម្រាប់មនុស្សពេញវ័យមានអ្វីខ្លះ?
ចូរពន្យល់ប្រភេទសេវាកម្សាន្តទេសចរណ៍នីមួយៗ។

# ការសម្រួលការធ្វើដំណើរ និង ការដឹកជញ្ជូនទេសចរណ៍

(ទ្រឹស្តី២ម៉ោង អនុវត្ត២ម៉ោង)

*សិក្សាមេរៀននេះចប់សិស្សអាចៈ*

- បង្ហាញពីការផ្តល់ និងបកស្រាយព័ត៌មានសម្រាប់ភ្ញៀវទេសចរ
- រៀបរាប់ប្រភេទមធ្យោបាយធ្វើដំណើរ(ផ្លូវគោក ផ្លូវទឹក និងផ្លូវអាកាស)
- រៀបរាប់បែបបទចេញ-ចូលទេសចរណ៍(លិខិតឆ្លងដែន ទិដ្ឋាការ លិខិតអនុញ្ញាតផ្សេងៗ)។

ដើម្បីធ្វើឱ្យមានការទាក់ទាញទេសចរមកទស្សនាកម្សាន្ត នៅតំបន់ទេសចរណ៍ណាមួយម្តងទៀត គ្រប់ប្រទេស ឬតំបន់គោលដៅទេសចរណ៍ទាំងអស់ ត្រូវរៀបចំសម្រួលការធ្វើដំណើរ ដែលមានភាពទាក់ទាញបន្ថែមទៀត។ នៅក្នុងនោះដែរ គេត្រូវរៀបចំការផ្តល់ និងបកស្រាយព័ត៌មានសម្រាប់ភ្ញៀវទេសចរ មធ្យោបាយធ្វើដំណើរ និងរៀបចំបែបបទចេញ-ចូលទេសចរណ៍(លិខិតឆ្លងដែន ទិដ្ឋាការ លិខិតអនុញ្ញាតផ្សេងៗ លិខិតសុខភាព និងភាពមានជំងឺផ្សេងៗ និងលិខិតបង់ពន្ធគយ)ឱ្យមានលក្ខណៈល្អប្រសើរទៅតាមតម្រូវការរបស់ភ្ញៀវ។

## ១. ការផ្តល់ព័ត៌មានទេសចរណ៍ និងការបកស្រាយ

ការផ្តល់ព័ត៌មាន និងការបកស្រាយមានគោលបំណងផ្តល់ចំពោះការដឹងជាក់លាក់ដល់ភ្ញៀវទេសចរ អំពីតំបន់ដែលគេទៅទស្សនា។ ចំណែកគោលដៅសំខាន់នៃការផ្តល់ព័ត៌មាន គឺងាយស្រួលដល់ភ្ញៀវនូវសារៈសំខាន់នៃតំបន់ (នៅទីណា របៀបណា ការរំពឹងទុក អ្វីគួរធ្វើ អាកប្បកិរិយាបែបណា...)។ ការបកស្រាយទាក់ទងទៅនឹងការស្វែងយល់ និងសិក្សាពីតំបន់ដែលគេទៅទស្សនា។ ព័ត៌មានគឺជាសមាសធាតុដ៏សំខាន់ និងចាំបាច់នៅក្នុងការគ្រប់គ្រងទេសចរ។ ជាទូទៅភ្ញៀវទេសចរធ្វើដំណើរទៅកាន់តំបន់ណាមួយតែងតែពុំបានស្គាល់តំបន់នោះជាមុនទេ។

### ១.១. ការផ្តល់ព័ត៌មានទេសចរណ៍

សេវាកម្មព័ត៌មានទេសចរណ៍ត្រូវបានចែកជាពីរគឺ ព័ត៌មានសម្រាប់ទេសចរ និងព័ត៌មានសម្រាប់អ្នករៀបចំចាត់ចែងការងារទេសចរណ៍ ឬទីភ្នាក់ងារទេសចរណ៍។

- *ព័ត៌មានសម្រាប់ទេសចរ*

ទេសចរត្រូវការព័ត៌មាន មុនពេលគេចាកចេញទៅតំបន់ដែលពួកគេមានផែនការទៅទស្សនា ដើម្បីឱ្យពួកគេអាចរៀបចំដំណើរកម្សាន្តរបស់ពួកគេបានយ៉ាងរៀបរយ ឧទាហរណ៍ ប្រភេទសម្លៀកបំពាក់ ឧបករណ៍ប្រើប្រាស់បន្ថែម តម្រូវការផ្នែកសុខភាព...នេះគឺជាផ្នែកមួយនៃការរកទីផ្សារ។ ជាងនេះទៅទៀត ពួកគេត្រូវការព័ត៌មានបន្ថែមនៅពេលពួកគេធ្វើដំណើរ។ ម្យ៉ាងទៀត ដើម្បីធ្វើដំណើរទៅ

កាន់តំបន់ណាមួយ ទេសចរត្រូវការជាចាំបាច់នូវព័ត៌មានពីទីកន្លែងដែលនឹងទៅដល់ ឧទាហរណ៍ពីទំនៀមទម្លាប់ប្រពៃណី វិន័យក្បួនខ្នាតដែលតម្រូវឱ្យអនុវត្ត ព័ត៌មានពីធនធានដែលទាក់ទាញទេសចរណ៍ ផែនទីតំបន់ទេសចរណ៍ ផែនទីរមណីយដ្ឋាន និងផ្លូវក្នុងតំបន់ទេសចរណ៍ ព័ត៌មានពីឧស្សាហកម្មទេសចរណ៍ ទស្សនាវដ្តី សៀវភៅផ្ទត់ ស៊ីឌីរ៉ូម(CD-Room) និងផ្តល់ព័ត៌មានទេសចរណ៍តាមអ៊ិនធឺណែត។

- *ព័ត៌មានសម្រាប់អ្នករៀបចំទំនាក់ទំនងការងារទេសចរណ៍ ឬទីភ្នាក់ងារទេសចរណ៍*

អ្នករៀបចំចាត់ចែងការងារទេសចរណ៍(ទីភ្នាក់ងារទេសចរណ៍) ត្រូវការព័ត៌មានច្រើន ពិសេសគឺដើម្បីបង្កើតខ្សែទស្សនកិច្ច អ្នកទាំងនោះ(ការីទេសចរណ៍)ចាំបាច់ត្រូវសិក្សា ទទួលបានព័ត៌មានជាច្រើនពីធនធានទេសចរណ៍ រមណីយដ្ឋាន ឧស្សាហកម្មទេសចរណ៍ និងព័ត៌មានទេសចរណ៍ផ្សេងៗទៀត។

### ១.២. ការបកស្រាយ

ការបកស្រាយគឺជាការផ្តល់នូវចំណេះដឹង ភាពរីករាយ ភាពគួរឱ្យចាប់អារម្មណ៍នៃវត្ថុទាក់ទាញនីមួយៗ និងទំនាក់ទំនងរបស់វាដល់ភ្ញៀវទេសចរ។

- *សារៈសំខាន់នៃការបកស្រាយ*

ការបកស្រាយគឺជាវិធីសាស្រ្តទំនាក់ទំនងមួយ ដែលពោរពេញទៅដោយសិល្បៈ ការច្នៃប្រឌិតដែលទាក់ទាញ និងលើកទឹកចិត្តឱ្យភ្ញៀវស្វែងយល់អំពីប្រជាជន ក៏ដូចជាធនធានក្នុងតំបន់។

ការបកស្រាយមានសារៈសំខាន់ព្រោះ៖

  - ផ្តល់ព័ត៌មានទាក់ទងនឹងសហគមន៍
  - ធ្វើឱ្យទេសចរ មិនវង្វេងផ្លូវ
  - ត្រួតពិនិត្យសកម្មភាពភ្ញៀវចៀសវាងផលប៉ះពាល់មិនល្អ
  - ធ្វើឱ្យភ្ញៀវយល់ និងបង្កើនចំណេះដឹងទាក់ទងនឹងវប្បធម៌ប្រពៃណីរបស់សហគមន៍
  - ធ្វើឱ្យភ្ញៀវទទួលបានបទពិសោធន៍ ដែលមានគុណភាព និងមានតម្លៃ។

- *ប្រភេទនៃការបកស្រាយ*

ការបកស្រាយមានពីរប្រភេទគឺការបកស្រាយដោយមនុស្ស និងការបកស្រាយដោយមិនប្រើមនុស្ស(ការប្រើប្រាស់សញ្ញា)។

ការបកស្រាយដោយប្រើមនុស្សគឺការធ្វើឡើងតាមរយៈអ្នកនាំភ្ញៀវ (មគ្គុទ្ទេសក៍ទេសចរណ៍) ដោយពួកគេជាអ្នកផ្តល់ព័ត៌មាន ធ្វើការបកស្រាយទៅលើរឿងរ៉ាវដែលគួរឱ្យចាប់អារម្មណ៍ ដឹកនាំដំណើរកម្សាន្តផ្តល់បទបង្ហាញផ្សេងៗ និងចែករំលែកចំណេះដឹងពីសកម្មភាពក្នុងតំបន់ជាមួយភ្ញៀវដោយផ្ទាល់ដូចជា ភូមិសាស្រ្ត ប្រវត្តិសាស្រ្ត ធម្មជាតិ វប្បធម៌ សិល្បៈ ប្រពៃណីទំនៀមទម្លាប់ និងសេដ្ឋកិច្ចសង្គមនៃទីកន្លែងទស្សនា ដើម្បីបង្កើនការចាប់អារម្មណ៍របស់ភ្ញៀវ។

ការបកស្រាយដោយមិនប្រើមនុស្ស មានដូចជាការបង្ហាញដោយក្តារព័ត៌មាន រូបភាព ការតាំងពិព័រណ៍ និងការផ្សព្វផ្សាយ។

## ២. មធ្យោបាយធ្វើដំណើរទេសចរណ៍

ក្នុងវិស័យទេសចរណ៍ការផ្លាស់ប្តូរពីកន្លែងមួយទៅកន្លែងមួយទៀត អាស្រ័យទៅនឹងមធ្យោបាយដឹកជញ្ជូន។ ការដឹកជញ្ជូនទាំងខាងផ្លូវគោក ផ្លូវទឹក និងអាកាសធ្វើឱ្យទេសចរមានការងាយស្រួលប្រើប្រាស់ពេលវេលាជាក់លាក់ សន្សំពេលវេលា សន្សំលុយកាក់ និងរហ័សទាន់ចិត្ត។

ការដឹកជញ្ជូនទេសចរណ៍បានចែកចេញជាច្រើនផ្នែក ដែលផ្នែកនីមួយៗមានតម្រូវការចាំបាច់សម្រាប់ការធ្វើដំណើរជាទេសចរណ៍មិនអាចខ្វះបាន។ ការធ្វើដំណើរតាមផ្លូវដែកមានរថភ្លើង ផ្លូវអាកាសមានយន្តហោះ ផ្លូវគោកមានរថយន្ត យានយន្តតូចឬធំ និងមធ្យោបាយផ្សេងៗ ផ្លូវទឹកមាននាវាតូចធំ ទូកតាមសមុទ្រ បឹង ទន្លេ ព្រែក ជាមធ្យោបាយដែលមនុស្សប្រើប្រាស់ សម្រាប់ចូលទៅកាន់តំបន់ ប្រទេស ឬទ្វីបណាមួយ។ ចំនួន និងទីតាំងនៃចំណតអាកាសយានដ្ឋាន កំពង់ផែសមុទ្រ កំពង់ផែទឹកសាប ការអភិវឌ្ឍផ្លូវ និងប្រព័ន្ធបណ្តាញផ្សេងៗ ជាផ្នែកមួយសម្រាប់បង្កលក្ខណៈល្អប្រសើរក្នុងការធ្វើដំណើរ។ ជាមួយគ្នានេះ ទេសចរណ៍ត្រូវប្រើប្រាស់នូវគ្រប់មធ្យោបាយផ្សេងៗ ដើម្បីដោះដូរទីកន្លែងតាមរយៈការធ្វើដំណើរ ដូចជាយន្តហោះ នាវាចរ មធ្យោបាយដីគោក។ មធ្យោបាយដឹកជញ្ជូនផ្តល់លទ្ធភាពដល់ទេសចរណ៍ ក្នុងការតភ្ជាប់គ្នាពីតំបន់មួយទៅតំបន់មួយ ពីទីក្រុងមួយទៅទីក្រុងមួយពីប្រទេសមួយទៅប្រទេសមួយ និងពីទ្វីបមួយទៅទ្វីបមួយទៀត។

## ៣. បែបបទចេញ ចូលទេសចរណ៍

រាល់មនុស្សទាំងអស់ដែលមានគម្រោង ធ្វើដំណើរទៅកាន់តំបន់ ឬប្រទេសណាមួយផ្សេងក្រៅពីប្រទេសកំណើតរបស់ខ្លួនដែលរស់នៅជាប្រចាំ តារាងធ្វើដំណើរជាលក្ខណៈអន្តរជាតិ ត្រូវតែជាសិទ្ធិតំណាង ដែលអនុញ្ញាតឱ្យឆ្លងកាត់ពីប្រទេសមួយទៅប្រទេសមួយផ្សេងទៀត និងត្រឡប់មកប្រទេសរបស់ខ្លួនវិញ។ សិទ្ធិតំណាងជាមូលដ្ឋានសម្រាប់ការធ្វើដំណើរ ជាលក្ខណៈអន្តរជាតិមានដូចជា លិខិតឆ្លងដែន ទិដ្ឋាការ លិខិតអនុញ្ញាតផ្សេងៗ(ដូចជាលិខិតអនុញ្ញាតទេសចរ សលាកបត្រទេសចរ លិខិតអនុញ្ញាតឱ្យបើកបរជាលក្ខណៈអន្តរជាតិ) លិខិតបញ្ជាក់សុខភាពនិងភាពគ្មានជំងឺឆ្លង និងចុងក្រោយគឺលិខិតបង់ពន្ធគយ។

### ៣.១. លិខិតឆ្លងដែន

លិខិតឆ្លងដែនគឺជាឯកសារដែលចេញដោយរដ្ឋាភិបាល និងជាការផ្តល់សិទ្ធិឱ្យពលរដ្ឋម្នាក់ៗដើម្បីធ្វើដំណើរទៅបរទេស។ លិខិតឆ្លងដែនបញ្ជាក់នូវអត្តសញ្ញាណ និងសញ្ជាតិរបស់អ្នកធ្វើដំណើរ ហើយផ្តល់សិទ្ធិដល់អ្នកធ្វើដំណើរ ចូលទៅកាន់ប្រទេសដទៃទៀត។ លិខិតឆ្លងដែនមានលក្ខណៈពិសេសមួយដែលបង្កលក្ខណៈងាយស្រួលដល់ការធ្វើដំណើរ ប្រកបដោយលក្ខណៈស្របច្បាប់ ត្រឹមត្រូវ។ ដូច្នេះប្រសិនបើគ្មានលិខិតឆ្លងដែនទេ នោះអាជ្ញាធរមានសមត្ថកិច្ចតាមបណ្តាច្រកចេញ-ចូល ជាពិសេស នៅចំណតអាកាសយានដ្ឋានអន្តរជាតិ មិនអាចឱ្យចេញចូលជាដាច់ខាត។ ទាំងអស់នេះតម្រូវឱ្យអ្នកធ្វើដំណើរគ្រប់រូបត្រូវមានលិខិតឆ្លងដែន។

ជាទូទៅលិខិតឆ្លងដែនមានបីប្រភេទ៖

- លិខិតឆ្លងដែនធម្មតាសម្រាប់ប្រជាពលរដ្ឋសាមញ្ញ សិស្ស និស្សិត
- លិខិតឆ្លងដែនផ្លូវការសម្រាប់មន្ត្រីរាជការ ដែលចេញទៅបរទេសក្នុងបេសកកម្ម
- លិខិតឆ្លងដែនការទូតសម្រាប់អង្គទូត ឬការទូត មន្ត្រីជាន់ខ្ពស់។

### ៣.២. ទិដ្ឋាការ

ក្រៅពីលិខិតឆ្លងដែន មនុស្សម្នាក់ៗទាមទារនូវទិដ្ឋាការ ដើម្បីចូលទៅប្រទេសមួយចំនួន។ ទិដ្ឋាការគឺចំណារយល់ព្រមមួយដែលបានធ្វើឡើងនៅក្នុងលិខិតឆ្លងដែន ឬចារដាក់ឯកសារដោយឡែកមួយដោយស្ថានទូត ឬស្ថានកុងស៊ុលនៃប្រទេសណាមួយ ដែលត្រូវធ្វើដំណើរទៅទស្សនា ហើយដែលមានប្រចាំការនៅប្រទេសរបស់ខ្លួនបើមាន ឬប្រចាំការនៅប្រទេសជិតខាង (ក្នុងករណីដែលប្រទេសរបស់ខ្លួនគ្មានស្ថានទូត ឬស្ថានកុងស៊ុលប្រចាំការ)។

ទិដ្ឋាការមានពីរប្រភេទៈ

- ទិដ្ឋាការសុំចូលស្នាក់នៅមានរយៈពេលយូរបំផុតមួយឆ្នាំ
- ទិដ្ឋាការសុំឆ្លងកាត់មានរយៈពេល ត្រឹម៤៨ម៉ោង។

ទិដ្ឋាការទាំងពីរប្រភេទនេះ អាចសុំចេញចូលម្តង ឬចេញចូលបានច្រើនដង។

### ៣.៣. សលាកបត្រទេសចរ

អ្នកដំណើរត្រូវប្រើប្រាស់លិខិតអនុញ្ញាតទេសចរ ឬសលាកបត្រទេសចរនៅពេលចូលទៅប្រទេសដទៃជាលើកដំបូង។ សំណុំបែបបទនៃលិខិតអនុញ្ញាតនេះ មានចែកជូនអ្នកដំណើរនៅតាមច្រកអន្តរជាតិ។ ក្នុងករណីខ្លះ សំណុំបែបបទមានចែកជូននៅព្រលានយន្តហោះមុនពេលចេញដំណើរ។ លិខិតអនុញ្ញាតចូលប្រទេស ឬសលាកបត្រទេសចរមានបោះត្រាដោយមន្ត្រីគយ ឬមន្ត្រីអន្តោប្រវេសន៍ពេលដែលអ្នកដំណើរចូលក្នុងប្រទេស។ អ្នកដំណើរត្រូវរក្សាទុកសំណុំបែបបទទាំងនេះ នៅអំឡុងពេលស្នាក់នៅ រហូតដល់ពេលត្រឡប់មកវិញ ដើម្បីបង្ហាញដល់មន្ត្រីអន្តោប្រវេសន៍នៅព្រលានយន្តហោះ មុនពេលចាកចេញ។

ចំពោះអ្នកធ្វើដំណើរដែលមានបំណងចង់បើកបររថយន្តផ្ទាល់ខ្លួនទៅបរទេស ត្រូវប្រើប្រាស់លិខិតអនុញ្ញាតបើកបរអន្តរជាតិ។

### ៣.៤. លិខិតបញ្ជាក់សុខភាព

នៅបណ្តាប្រទេសមួយចំនួន តម្រូវឱ្យមានលិខិតបញ្ជាក់ជាសកល អំពីការចាក់ថ្នាំបង្ការជំងឺឆ្លង (ជំងឺអ៊ុត ជំងឺអាសន្នរោគ ឬជំងឺគ្រុនលឿង)។

### ៣.៥. លិខិតបង់ពន្ធគយ

ទំនិញដែលទេសចរទិញ ដើម្បីនាំយកទៅកាន់ប្រទេសខ្លួនវិញ តម្រូវឱ្យបង់ពន្ធដែលកំណត់ដោយរដ្ឋាភិបាលប្រទេសទទួលទេសចរ។ តម្លៃនៃការបង់ពន្ធនេះហៅថាពន្ធគយ។ ពន្ធគយជាតម្លៃគិតជាសាច់ប្រាក់ពីម្ចាស់ទំនិញ។ ដូច្នេះ មុនពេលបានទទួលការអនុញ្ញាតឱ្យចូលក្នុងប្រទេសរបស់គេ ទេសចរត្រូវតែទៅបង្ហាញប្រាប់មន្ត្រីគយអំពីទំនិញដែលបានទិញ។ ទ្រព្យសម្បត្តិបុគ្គលដូចជាសម្លៀក

បំពាក់ គ្រឿងអលង្ការ និងម៉ាស៊ីនថតដែលជាកម្មសិទ្ធរបស់អ្នកដំណើរមិនត្រូវឱ្យបញ្ជាក់ប្រាប់ទេ ប្រសិនបើមិនមានបំណងយកទៅលក់ក្នុងប្រទេសមួយទៀតនោះ។ ប៉ុន្តែនៅបណ្តាប្រទេសមួយចំនួន កម្មសិទ្ធិរបស់អ្នកដំណើរត្រូវតែបញ្ជាក់ប្រាប់ដល់មន្ត្រីគយ។

**មេរៀនសង្ខេប**

ដើម្បីធ្វើឱ្យមានការទាក់ទាញភ្ញៀវទេសចរ មកទស្សនាកម្សាន្តនៅតំបន់ទេសចរណ៍ ឬតំបន់គោលដៅទេសចរណ៍ទាំងអស់ ទីភ្នាក់ងារទេសចរណ៍ត្រូវចេះរៀបចំសម្រួលការធ្វើដំណើរ ដូចជាគេត្រូវរៀបចំការផ្តល់ និងបកស្រាយព័ត៌មានសម្រាប់ភ្ញៀវទេសចរ មធ្យោបាយធ្វើដំណើរ និងរៀបចំបែបបទចេញ-ចូលទេសចរណ៍(មានលិខិតឆ្លងដែន ទិដ្ឋាការ លិខិតអនុញ្ញាតផ្សេងៗ លិខិតសុខភាពនិងភាពគ្មានជំងឺ និងលិខិតបង់ពន្ធគយ)។

- ***ព័ត៌មាន និងការបកស្រាយ*** មានគោលបំណងផ្តល់ចំណេះដឹងជាក់លាក់ដល់ទេសចរ អំពីតំបន់ដែលគេទស្សនា។
- ***មធ្យោបាយដឹកជញ្ជូន*** ក្នុងវិស័យទេសចរណ៍ ការផ្លាស់ប្តូរពីកន្លែងមួយទៅកន្លែងមួយទៀតអាស្រ័យទៅនឹងមធ្យោបាយដឹកជញ្ជូនមាន រថយន្ត យានយន្តតូចឬធំ នាវាតូចឬធំ ទូក រថភ្លើង យន្តហោះ... ជាមធ្យោបាយដែលមនុស្សប្រើប្រាស់សម្រាប់ចូលទៅកាន់តំបន់ ប្រទេស ឬទីបណាមួយ។
- ***សិទ្ធិតំណាងជាមូលដ្ឋានសម្រាប់ការធ្វើដំណើរ*** ជាលក្ខណៈអន្តរជាតិមាន លិខិតឆ្លងដែន ទិដ្ឋាការ លិខិតអនុញ្ញាតផ្សេងៗ លិខិតបញ្ជាក់សុខភាព និងភាពគ្មានជំងឺឆ្លង លិខិតពន្ធគយ។
- ***លិខិតឆ្លងដែន*** គឺជាឯកសារមួយបញ្ជាក់ពីអត្តសញ្ញាណ និងសញ្ជាតិរបស់អ្នកធ្វើដំណើរ ដែលចេញដោយរដ្ឋាភិបាល និងជាការផ្តល់សិទ្ធិឱ្យពលរដ្ឋម្នាក់ៗ ដើម្បីធ្វើដំណើរទៅបរទេស។
- ក្រៅពីលិខិតឆ្លងដែនមនុស្សម្នាក់ៗត្រូវមាន***ទិដ្ឋាការ***ដើម្បីចូលទៅប្រទេសមួយ។ ទិដ្ឋាការ គឺជាចំណារយល់ព្រមមួយដែលបានធ្វើឡើងនៅក្នុងលិខិតឆ្លងដែន ឬចារដាក់ឯកសារដោយឡែកមួយដោយស្ថានទូត ឬស្ថានកុងស៊ុលនៃប្រទេសជិតខាង (ក្នុងករណីដែលប្រទេសរបស់ខ្លួនគ្មានស្ថានទូត ឬស្ថានកុងស៊ុលនៅប្រចាំការ )។
- អ្នកដំណើរត្រូវប្រើប្រាស់***សលាកបត្រទេសចរ*** នៅពេលចូលទៅប្រទេសដទៃនោះជាលើកដំបូង ហើយដែលមានចែកជូននៅតាមច្រកអន្តរជាតិ ឬចែកជូននៅព្រលានយន្តហោះដើម្បីចេញដំណើរ។ សំណុំលិខិតមានបោះត្រារបស់មន្ត្រីគយ ឬមន្ត្រីអន្តោប្រវេសន៍ពេលដែលអ្នកដំណើរចូលក្នុងប្រទេសវិញ។ សំណុំបែបបទនេះត្រូវរក្សាទុកអំឡុងពេលស្នាក់នៅប្រទេសគេ រហូតដល់ពេលត្រឡប់មកប្រទេសខ្លួនវិញ ដើម្បីបង្ហាញដល់មន្ត្រីអន្តោប្រវេសន៍នៅច្រកអន្តរជាតិ ឬនៅព្រលានយន្តហោះ មុនពេលចាកចេញ។

- ***លិខិតអនុញ្ញាតបើកបរអន្តរជាតិ*** សម្រាប់ផ្តល់ដល់អ្នកដំណើរ ដែលមានគោលបំណង បើកបររថយន្តផ្ទាល់ខ្លួននៅបរទេស។
- នៅបណ្តាប្រទេសមួយចំនួនតម្រូវឱ្យមាន***លិខិតបញ្ជាក់ជាអន្តរជាតិមួយអំពីការចាក់ថ្នាំបង្ការជំងឺឆ្លង***។
- ***ទំនិញដែលទេសចរទិញ*** ដើម្បីនាំយកទៅប្រទេសរបស់ខ្លួនវិញ ***តម្រូវឱ្យបង់ពន្ធ***ដែលកំណត់ដោយរដ្ឋាភិបាលរបស់ប្រទេសទទួលទេសចរ។ តម្លៃនៃការបង់ពន្ធនេះហៅថាពន្ធគយ។

## សំណួរ

១. តើការធ្វើដំណើរត្រូវរៀបចំយ៉ាងដូចម្តេច ដើម្បីទាក់ទាញទេសចរអន្តរជាតិ មកទស្សនាក្នុងប្រទេសយើង?

២. ហេតុអ្វីទេសចរត្រូវការព័ត៌មាន មុនពេលទេសចរចេញទៅតំបន់ដែលត្រូវទស្សនា?

៣. តើការបកស្រាយមានប៉ុន្មានប្រភេទ? អ្វីខ្លះ?

៤. តើការបកស្រាយមានសារៈសំខាន់ដែរឬទេ? ហេតុអ្វី?

៥. តើទេសចរត្រូវមានឯកសារ ឬលិខិតអ្វីខ្លះ ទាក់ទងនឹងការធ្វើសំណុំបែបបទចេញ-ចូល?

# ខ្សែទស្សនកិច្ច

(ទ្រឹស្តី៣ម៉ោង អនុវត្ត៣ម៉ោង)

*សិក្សាមេរៀននេះចប់សិស្សអាចៈ*

- កំណត់និយមន័យខ្សែទស្សនកិច្ច
- រៀបរាប់ និងពន្យល់សមាសធាតុដែលមាននៅក្នុងខ្សែទស្សនកិច្ច។

ច្បាប់បានអនុញ្ញាតឱ្យភ្នាក់ងារទេសចរណ៍ធ្វើអាជីវកម្មជាអ្នកលក់ខ្សែទស្សនកិច្ច ដែលផលិតដោយការីទេសចរណ៍ លក់ដុំបន្ត ឬលក់រាយ ដើម្បីទទួលបានកម្រៃសេវាកម្ម ឬក៏ប្រាក់ចំណេញតាមរយៈកិច្ចព្រមព្រៀង។

## ១. និយមន័យ

ខ្សែទស្សនកិច្ចសំដៅដល់កញ្ចប់សេវាកម្មទេសចរណ៍ រៀបចំឡើងដោយការីទេសចរណ៍ រួមបញ្ចូលនូវសេវាកម្មយ៉ាងតិចពីរក្នុងចំណោមសេវាកម្មចាំបាច់ ដូចជា សេវាកម្មស្នាក់នៅទេសចរណ៍ សេវាកម្មដឹកជញ្ជូន សេវាកម្មម្ហូបអាហារនិងភេសជ្ជៈ ការធ្វើទស្សនកិច្ច សេវាកម្មមគ្គុទ្ទេសក៍ទេសចរណ៍ និងសេវាកម្មផ្សេងទៀតដែលពាក់ព័ន្ធ ដោយមានថ្លៃលក់មួយជាក់លាក់ និងស្ថិតក្នុងថេរវេលាប្រតិបត្តិជាកំណត់។

## ២. សេវាកម្មទេសចរណ៍

សេវាកម្មទេសចរណ៍ជាលទ្ធផលការងាររបស់ទីភ្នាក់ងារទេសចរណ៍ ដែលបានធ្វើឡើង ដើម្បីបំពេញនូវសេចក្តីត្រូវការរបស់អតិថិជនដែលជាអ្នកប្រើប្រាស់។ ការងារទាំងនេះ ជាការងាររៀបចំចាត់ចែងបម្រើឱ្យសេចក្តីត្រូវការលើការធ្វើដំណើរកម្សាន្តជាទេសចរណ៍ និងរៀបចំសេវាកម្មទេសចរណ៍ដែលជាតម្រូវការចាំបាច់ផ្សេងៗទៀត។ នៅក្នុងរចនាសម្ព័ន្ធការងារសេវាកម្មទេសចរណ៍ចែកជាពីរប្រភេទផ្សេងគ្នាគឺ ការងារចម្បង ឬគោល និងការងារបន្ថែមៈ

- *ការងារចម្បងដែលទីភ្នាក់ងារទេសចរណ៍ចាំបាច់ត្រូវបំពេញជំហានដំបូងមានៈ*
  - សេវាកម្មក្នុងផ្នែករៀបចំដឹកជញ្ជូន ដឹកនាំ និងបដិសណ្ឋារកិច្ច
  - ការផ្គត់ផ្គង់សេវាកម្មស្នាក់នៅ
  - ការផ្គត់ផ្គង់ចំណីអាហារសម្រាប់អ្នកទេសចរ
  - សេវាកម្មផ្នែកមគ្គុទ្ទេសក៍ទេសចរណ៍ជូនដំណើរ និងបកប្រែ។
- *ការងារបន្ថែម ៖*
  - សេវាកម្មផ្នែករៀបចំការទស្សនា

- សេវាកម្មផ្នែកការធានារ៉ាប់រងទេសចរណ៍
- សេវាកម្មផ្នែកមគ្គុទ្ទេសក៍ទេសចរណ៍ជូនដំណើរ និងបកប្រែ
- សេវាកម្មដទៃទៀតដែលមានចែងជាលក្ខខណ្ឌក្នុងការធ្វើដំណើរ
- សេវាកម្មផ្នែកជួសជុលសម្ភារៈផ្សេងៗ
- សេវាកម្មផ្នែកជួលសម្ភារៈប្រើប្រាស់
- ប្តូរប្រាក់ ឬប្តូររូបិយប័ណ្ណ
- ទូរស័ព្ទ ប៉ុស្តិ៍ប្រៃសណីយ៍
- បោកអ៊ុត កាត់សក់...។

ដូចដែលបានបង្ហាញខាងលើនេះ ភាពប្លែករវាងការងារចម្បង និងការងារបន្ថែមគឺស្ថិតនៅលើការផ្តល់សេវាមុន និងក្រោយ។ ជាមួយគ្នានេះដែរ អ្នកទេសចរត្រូវបានជូន ឬលក់ជូននូវទំនិញសម្ភារៈមួយចំនួនដូចជា ប្លង់ទីក្រុង ផែនទីមជ្ឈមណ្ឌលកម្សាន្ត និងសួនសត្វ វត្ថុអនុស្សាវរីយ៍ សម្ភារៈកីឡាសម្រាប់ទេសចរណ៍ និងសម្រាប់ការធ្វើដំណើរ។

## ៣. សមាសធាតុខ្សែទស្សនកិច្ច

សមាសធាតុខ្សែទស្សនកិច្ចជាសេវាកម្មសរុប (កញ្ចប់សេវាកម្មទាំងផ្នែកសេវាកម្មគោល និងសេវាកម្មបន្ទាប់បន្សំ(បន្ថែម)ដែលបង្កើតឡើងតម្រូវលើការធ្វើដំណើរកម្សាន្តទេសចរណ៍ និងសម្រាកលំហែកម្សាន្តរបស់ទេសចរ ឬអ្នកធ្វើដំណើរកម្សាន្ត អាស្រ័យតាមគោលការណ៍នៃការធ្វើដំណើររបស់គេ។ សមាសធាតុសេវាកម្មសំខាន់ៗបញ្ចូលក្នុងខ្សែទស្សនកិច្ចរួមមាន៖

- សេវាកម្មដឹកជញ្ជូនជាផ្នែកមួយនៃសេវាកម្មទេសចរណ៍ ដែលគេបូកបញ្ចូលក្នុងតម្លៃខ្សែទស្សនកិច្ចពីព្រលានយន្តហោះមកសណ្ឋាគារ និងនៅក្នុងកម្មវិធីកម្សាន្ត។ សេវាកម្មដឹកជញ្ជូនសំដៅជាពិសេសរថយន្តសម្រាប់ដឹកជញ្ជូនភ្ញៀវទេសចរដូចជា រថយន្តធម្មតា(រថយន្តដែលមានកៅអី៤ មានកៅអី១២ មានកៅអី២៥ មានកៅអី៣៥ មានកៅអី៤០) និងសេវាកម្មដឹកជញ្ជូនតាមរយៈរថភ្លើង និងនាវា។
- សេវាកម្មមគ្គុទ្ទេសក៍ត្រូវបានគេចាត់ទុកថា ជាសេវាកម្មផ្តល់ព័ត៌មាន បូកបញ្ចូលសេវាខ្សែទស្សនកិច្ច។ សេវានេះត្រូវបានគេគិតថ្លៃទៅតាមប្រភេទភាសា។
- សេវាកម្មផ្តល់អាហារមានដូចជាអាហារកញ្ចប់ អាហារថ្ងៃត្រង់ អាហារពេលល្ងាច និងអាហាររៀបចំផ្គត់ផ្គង់តាមការចាំបាច់។
- សេវាកម្មទស្សនាកម្សាន្តមានដូចជាសំបុត្រទស្សនា តំបន់ប្រវត្តិសាស្ត្រ រមណីយដ្ឋាន សារមន្ទីរ ឬទីតាំងកម្សាន្តដទៃទៀត។
- សេវាកម្មធានារ៉ាប់រងត្រូវបានអនុវត្ត ដោយហេតុថា ទេសចរប្រឈមនឹងឧបសគ្គ និងហានិភ័យជាច្រើនក្នុងរយៈពេលធ្វើដំណើរ និងសកម្មភាពទេសចរណ៍។ ឧទាហរណ៍ៈ បញ្ហាសុខភាព និងជំងឺ បញ្ហាបាត់បង់ទ្រព្យសម្បត្តិ ឬបាត់បង់ប្រាក់កាស គ្រោះថ្នាក់ជាយថាហេតុ បញ្ហារងរបួសឧប្បទ្ទវហេតុធម្មជាតិ និងបញ្ហាជីវិតផ្ទាល់។

- សេវាកម្មកីឡា និងកម្សាន្តបានដើរតួនាទីយ៉ាងសំខាន់ក្នុងការបំពេញបង្គ្រប់នូវគោលបំណងទេសចរណ៍បន្ថែមពីលើការដឹកជញ្ជូន ការស្នាក់នៅ និងម្ហូបអាហារ។ មូលដ្ឋានសេវាកម្មកីឡា និងកម្សាន្តមានច្រើនប្រភេទ និងមានទ្រង់ទ្រាយផ្សេងៗពីគ្នា ។

ឧទាហរណ៍: កន្លែងហែលទឹក សូណា ទីលានលេងតេនីស ទីលានលេងកូនបាល់ ទីលានវាយកូនគោល ទីលានហាត់ប្រាណ។ល។ ដើម្បីឱ្យស្របនឹងស្តង់ដាទេសចរណ៍អន្តរជាតិ កញ្ចប់ខ្សែទស្សនកិច្ចយ៉ាងតិចបំផុតត្រូវបានបញ្ចូលនូវសមាសធាតុពីរនៃសេវាកម្មទេសចរណ៍។

ឧទាហរណ៍: សេវាកម្មដឹកជញ្ជូន និងសេវាកម្មស្នាក់នៅ។ រីឯផ្នែកផ្សេងៗនៃសមាសធាតុសេវាកម្មទេសចរណ៍ ដូចជាសេវាកម្មអាហារ និងភេសជ្ជៈ សេវាកម្មកម្សាន្ត និងកម្មវិធីទស្សនកិច្ចអាចនិងបញ្ចូលក្នុងខ្សែទស្សនកិច្ចតាមសំណូមពរ តាមការឯកភាព ឬតាមការបញ្ជាទិញ។

**មេរៀនសង្ខេប**

- **ខ្សែទស្សនកិច្ច** គឺជាកញ្ចប់សេវាកម្ម ដែលបង្កើតឡើងក្នុងការធ្វើដំណើរកម្សាន្ត និងសម្រាកលំហែកម្សាន្តរបស់ទេសចរអាស្រ័យតាមគោលបំណងនៃការធ្វើដំណើរកម្សាន្តរបស់គេ។
- សមាសធាតុសំខាន់ៗដែលរួមបញ្ចូលក្នុងខ្សែទស្សនកិច្ចរួមមាន សេវាកម្មស្នាក់នៅ សេវាកម្មដឹកជញ្ជូន សេវាកម្មមគ្គុទ្ទេសក៍ សេវាកម្មផ្តល់អាហារ និងភេសជ្ជៈ សេវាកម្មទស្សនាកម្សាន្ត សេវាកម្មធានារ៉ាប់រង សេវាកម្មកីឡា និងកម្សាន្ត។ល។
- សេវាកម្មទេសចរណ៍ត្រូវបានគេចែកជាពីរប្រភេទគឺការងារចម្បង(សេវាកម្មក្នុងផ្នែកដឹកជញ្ជូន និងបដិសណ្ឋារកិច្ច ស្នាក់នៅ ចំណីអាហារ មគ្គុទ្ទេសក៍ទេសចរណ៍) និងការងារបន្ថែម(រៀបចំការទស្សនា ការធានារ៉ាប់រងទេសចរណ៍ ប្តូរប្រាក់ឬប្តូររូបិយប័ណ្ណ ទូរស័ព្ទ ប៉ុស្តិ៍ប្រៃសណីយ៍)
- សមាសធាតុខ្សែទស្សនកិច្ច ជាកញ្ចប់សេវាកម្មសរុបទាំងសេវាកម្មចម្បង និងសេវាកម្មបន្ទាប់បន្សំ។

## សំណួរ

១. តើខ្សែទស្សនកិច្ចជាអ្វី?

២. តើសេវាកម្មទេសចរណ៍ជាអ្វី?

៣. តើការងារចម្បង និងការងារបន្ថែមរបស់សេវាកម្មទេសចរណ៍មានអ្វីខ្លះ?

# ព្រឹត្តិការណ៍ទេសចរណ៍

**(ទ្រឹស្តី២ម៉ោង អនុវត្ត២ម៉ោង)**

### *សិក្សាមេរៀននេះចប់សិស្សអាច៖*

- រៀបរាប់ព្រឹត្តិការណ៍ទេសចរណ៍ជាតិ និងអន្តរជាតិ
- បែងចែកលក្ខណៈខុសគ្នារវាងព្រឹត្តិការណ៍ជាតិ និងអន្តរជាតិ
- រៀបចំខ្លួនចូលរួមព្រឹត្តិការណ៍ទេសចរណ៍សំខាន់ៗ។

ព្រឹត្តិការណ៍ទេសចរណ៍ជាផលិតផលទាក់ទាញមួយបែប ក្នុងការសម្រួលទេសចរដែលមកទស្សនា និងកម្សាន្ត។ ព្រឹត្តិការណ៍ទេសចរណ៍សំខាន់ៗមានពីរប្រភេទគឺ ព្រឹត្តិការណ៍ជាតិ និង ព្រឹត្តិការណ៍អន្តរជាតិ។

## ១. ព្រឹត្តិការណ៍ជាតិ

នៅព្រះរាជាណាចក្រកម្ពុជា ព្រឹត្តិការណ៍ជាតិសំខាន់ៗដែលបានរៀបចំរៀងរាល់ឆ្នាំមាន ៖ ទិវាជ័យជំនះលើរបបប្រល័យពូជសាសន៍ ពិធីបុណ្យមាឃបូជា ពិធីបុណ្យពិសាខបូជា ពិធីបុណ្យចូលឆ្នាំថ្មីប្រពៃណីជាតិនិងពិធីបុណ្យអង្គរសង្ក្រាន្ត ទិវានៃការចងចាំ ព្រះរាជពិធីច្រត់ព្រះនង្គ័ល ពិធីបុណ្យភ្ជុំបិណ្ឌ



*ព្រះរាជពិធីបុណ្យអុំទូក បណ្ដែតប្រទីប អកអំបុក សំពះព្រះខែ*



*សកម្មភាពល្បែងកម្សាន្តនៅពិធីបុណ្យចូលឆ្នាំខ្មែរ*

ទិវាប្រារព្ធពិធីព្រះវិញ្ញាណក្ខន្ធព្រះករុណាព្រះបាទសម្តេចព្រះនរោត្តមសីហនុ ព្រះមហាវីរក្សត្រព្រះវររាជបិតាឯករាជ្យបូរណភាពទឹកដី និងឯកភាពជាតិខ្មែរ "ព្រះបរមរតនកោដ្ឋ" ទិវាព្រះរាជពិធីគ្រងរាជព្រះបរមរាជសម្បត្តិរបស់ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថនរោត្តមសីហមុនី ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ព្រះរាជពិធីបុណ្យអុំទូកបណ្តែតប្រទីបអកអំបុកសំពះព្រះខែ និងទិវាឯករាជ្យជាតិ។



ពិធីបុណ្យច្រត់ព្រះនង្គ័ល



ទិវាឯករាជ្យជាតិ

ព្រឹត្តិការណ៍ជាតិសំខាន់ៗដូចបានរៀបរាប់ខាងលើ រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជាបានរៀបចំឱ្យមានព្រឹត្តិការណ៍ជាច្រើនដូចជា ៖

- ពិធីបុណ្យសមុទ្រនៅបណ្តាខេត្តទាំងបួន(ខេត្តព្រះសីហនុ ខេត្តកែប ខេត្តកំពត និងខេត្តកោះកុង) ដែលស្ថិតនៅតាមបណ្តោយឆ្នេរសមុទ្រ ដោយផ្លាស់វេនជារៀងរាល់ឆ្នាំចាប់ពីឆ្នាំ២០១១
- ពិធីបុណ្យទន្លេនៅតាមបណ្តាខេត្តដែលមានទន្លេឆ្លងកាត់ ដោយផ្លាស់វេនជារៀងរាល់ឆ្នាំចាប់ពីឆ្នាំ២០១៥
- សន្និសីទទេសចរណ៍-វប្បធម៌អន្តរជាតិនៅខេត្តសៀមរាបឆ្នាំ២០១៥
- ពិព័រណ៍ផលិតផលភូមិមួយផលិតផលមួយ
- ការរៀបចំកម្មវិធីសិល្បៈរួមអាស៊ាន-ចិនឆ្នាំ២០១៦
- ពិធីអបអរសាទរនៃការមកដល់ភ្ញៀវទី២លាននៅក្រុមអាកាសយានដ្ឋានអន្តរជាតិខេត្តសៀមរាប ដោយសហការជាមួយក្រុមហ៊ុនព្រលានយន្តហោះកម្ពុជា
- ការទទួលក្បួនរថយន្តមិត្តភាពអាស៊ាន-ឥណ្ឌានៅព្រះរាជាណាចក្រកម្ពុជា
- ការសម្តែងសិល្បៈវប្បធម៌ចម្រុះអាស៊ីបូព៌ានៅសៀមរាបអង្គរ
- ព្រឹត្តិការណ៍នៃការប្រកួតកីឡាគ្រប់ប្រភេទមានដូចជា បាល់ទាត់ បាល់ទះ ប្រដាល់សកលប្រដាល់ក្បាច់គុណបុរាណខ្មែរ។ល។
- ព្រឹត្តិការណ៍នៃការប្រជុំសន្និសីទ សិក្ខាសាលាថ្នាក់ជាតិ និងអន្តរជាតិ
- វេទិការជាតិ "កសិទេសចរណ៍ និងពិព័រណ៍ផលិតផលខ្មែរ
- រាត្រីសប្បុរសធម៌ ពិព័រណ៍ម្ហូបអាហារ និងការសម្តែងសិល្បៈអាស៊ាន-ឥណ្ឌា
- ពិធីបួងសួង និងអបអរសាទរការបញ្ចូល "តំបន់ប្រាសាទសំបូរព្រៃគុក" ក្នុងបញ្ជីបេតិកភណ្ឌពិភពលោកនៅខេត្តកំពង់ធំ ឆ្នាំ២០១៧

- ពិធីបួងសួងចម្រើនសេចក្ដីសុខជូនដល់ព្រះរាជាណាចក្រកម្ពុជា នៅមុខប្រាសាទអង្គរវត្ត ខេត្តសៀមរាប ឆ្នាំ២០១៧។

## ២. ព្រឹត្តិការណ៍អន្តរជាតិ

ក្រៅពីព្រឹត្តិការណ៍ជាតិ ព្រះរាជាណាចក្រកម្ពុជា បានរៀបចំព្រឹត្តិការណ៍អន្តរជាតិជាច្រើនដូចជាៈ

- កិច្ចប្រជុំកំពូលអាស៊ានឆ្នាំ២០០២ និងឆ្នាំ២០១២ ហើយកម្ពុជាទទួលសិទ្ធិជាម្ចាស់ផ្ទះរៀបចំកិច្ចប្រជុំនេះម្ដងទៀតនៅឆ្នាំ២០២២
- វេទិកាទេសចរណ៍អាស៊ានលើកទី៣០នៅឆ្នាំ២០១១ ហើយកម្ពុជាទទួលសិទ្ធិជាម្ចាស់ផ្ទះរៀបចំវេទិកាទេសចរណ៍អាស៊ានលើកទី៤០ នៅឆ្នាំ២០២១
- ការប្រកួតកីឡារត់ពាក់កណ្ដាលម៉ារ៉ាតុងអង្គរជារៀងរាល់ឆ្នាំ ដែលមានអ្នកចូលរួមមកពីបណ្ដាប្រទេសនានាជាច្រើនលើសកលលោក
- សន្និសីទទេសចរណ៍ និងវប្បធម៌អន្តរជាតិនៅខេត្តសៀមរាប ឆ្នាំ២០១៥
- ការសម្ដែងសិល្បៈរួមអាស៊ាន-ចិន ឆ្នាំ២០១៦
- ពិធីអបអរសាទរនៃការមកដល់ភ្ញៀវនៅអាកាសយានដ្ឋានអន្តរជាតិខេត្តសៀមរាប ដោយសហការជាមួយក្រុមហ៊ុនអាកាសចរណ៍កម្ពុជា
- ការរៀបចំទទួលក្បួនរថយន្តមិត្តភាពអាស៊ាន-ឥណ្ឌា នៅព្រះរាជាណាចក្រកម្ពុជា
- ការសម្ដែងសិល្បៈវប្បធម៌ចម្រុះអាស៊ីបូព៌ា នៅខេត្តសៀមរាប
- ព្រឹត្តិការណ៍ពិព័រណ៍ទេសចរណ៍កម្ពុជាអន្តរជាតិចាប់ពីឆ្នាំ២០១៧
- សន្និសីទស្ដីពីទេសចរណ៍ និងទីក្រុងបេតិកភណ្ឌ និងកិច្ចប្រជុំរដ្ឋមន្ត្រីទេសចរណ៍នៃកិច្ចសន្ទនាសហប្រតិបត្តិការអាស៊ីលើកទី២ ឆ្នាំ២០១៧
- កិច្ចប្រជុំវេទិកាសេដ្ឋកិច្ចពិភពលោកស្ដីពីអាស៊ានឆ្នាំ២០១៧
- ពិព័រណ៍ពាណិជ្ជកម្មទេសចរណ៍ចាប់ពីឆ្នាំ២០១៨
- វេទីការកំពូលទេសចរណ៍កម្ពុជា-ចិន ឆ្នាំ២០១៨ ក្រោមប្រធានបទ ការចាប់យកកាលានុវត្តភាពនៃការអភិវឌ្ឍវិស័យទេសចរណ៍នៅលើផ្លូវសូត្រ។
- ពិធីអបអរសាទរខួបអានុស្សាវរីយ៍លើកទី៦០នៃទំនាក់ទំនងការទូតកម្ពុជា-ចិន និងទទួលបេសកជនចិនរាប់ពាន់នាក់មកទស្សនាព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០១៨
- ពិធីអបអរសាទរ "ឆ្នាំវប្បធម៌-ទេសចរណ៍ កម្ពុជា-ចិន" និងដំណើរទស្សនកិច្ចនៃបេសកជនចិនចំនួន២០០០នាក់ ទស្សនាព្រះរាជាណាចក្រកម្ពុជាឆ្នាំ២០១៩
- សន្និសីទអន្តរជាតិលើកទី២ស្ដីពីកិច្ចព្រមព្រៀងទទួលស្គាល់គ្នាទៅវិញទៅមកលើអ្នកជំនាញទេសចរណ៍អាស៊ាន ឆ្នាំ២០១៨
- ការប្រកួតបាល់ទាត់អន្តរជាតិរវាងក្រុមកីឡាករជម្រើសជាតិកម្ពុជា ជាមួយជម្រើសជាតិនៃប្រទេសនានា នៅពហុកីឡដ្ឋានជាតិអូឡាំពិក

- កម្ពុជាទទួលបានសិទ្ធិជាម្ចាស់ផ្ទះរៀបចំព្រឹត្តិការណ៍ប្រកួតកីឡាស៊ីហ្គេមលើកទី៣២ ប្រចាំតំបន់អាស៊ីអាគ្នេយ៍ ដែលមានអ្នកចូលរួមមកពីបណ្ដាប្រទេសនានានៃតំបន់អាស៊ីអាគ្នេយ៍។



*ការរត់ប្រណាំងពាក់កណ្ដាលម៉ារ៉ាតុង*



*ការសម្ដែងសិល្បៈចម្រុះអាស៊ាន*

**មេរៀនសង្ខេប**

ព្រឹត្តិការណ៍ទេសចរណ៍កម្ពុជាមានពីរ គឺព្រឹត្តិការណ៍ជាតិ និងព្រឹត្តិការណ៍អន្តរជាតិ

***ព្រឹត្តិការណ៍ជាតិ*** សំដៅដល់ព្រឹត្តិការណ៍នានារបស់ជាតិដូចជា ពិធីបុណ្យចូលឆ្នាំ ភ្ជុំបិណ្ឌ ច្រត់ព្រះនង្គ័ល អុំទូក បុណ្យសមុទ្រ បុណ្យទន្លេ ទិវានៃការគ្រងរាជ្យសម្បត្តិរបស់ព្រះមហាក្សត្រខ្មែរ ទិវាបុណ្យឯករាជ្យជាតិ ការប្រកួតកីឡា។ល។

***ព្រឹត្តិការណ៍អន្តរជាតិ*** សំដៅដល់ព្រឹត្តិការណ៍នានាដែលទាក់ទង និងមានការចូលរួមពីជនជាតិបណ្ដាប្រទេសផ្សេងដូចជា កិច្ចប្រជុំកំពូលអាស៊ាន វេទិកាទេសចរណ៍អាស៊ាន ការប្រកួតកីឡាពាក់កណ្ដាលម៉ារ៉ាតុងអង្គរ សន្និសីទទេសចរណ៍ និងវប្បធម៌អន្តរជាតិ។ល។

## សំណួរ

១. តើព្រឹត្តិការណ៍ជាតិមានអ្វីខ្លះ?

២. តើព្រឹត្តិការណ៍អន្តរជាតិមានអ្វីខ្លះ?

៣. ចូររៀបរាប់ពីព្រឹត្តិការណ៍ទេសចរណ៍សំខាន់ៗនៅព្រះរាជាណាចក្រកម្ពុជាឱ្យបានចំនួន៥។

# បដិសណ្ឋារកិច្ច

**(ទ្រឹស្ដី៣ម៉ោង អនុវត្ត៦ម៉ោង)**

*សិក្សាមេរៀននេះចប់សិស្សអាចៈ*

- បង្ហាញពីរបៀបសំពះ ការញញឹម ការស្លៀកពាក់ និងការប្រើក្រសែភ្នែក
- ពណ៌នាពីសារៈសំខាន់នៃការធ្វើបដិសណ្ឋារកិច្ច។

បដិសណ្ឋារកិច្ចគឺជាការរៀបចំចាត់ចែងទទួលភ្ញៀវ និងយកចិត្តទុកដាក់ចំពោះភ្ញៀវប្រកបដោយភាពកក់ក្ដៅ រួសរាយរាក់ទាក់ និងផ្ដល់នូវទំនុកចិត្តដល់ភ្ញៀវ។

បុគ្គលិកបដិសណ្ឋារកិច្ចបានបង្កប់ចរិតលក្ខណៈនៃការយកចិត្តទុកដាក់ ជាពិសេសចំពោះភ្ញៀវច្រើនជាងបុគ្គលិកនៅក្នុងវិស័យជំនួញ និងក្នុងវិស័យនៃសេវាកម្មដទៃទៀត។ ជាទូទៅភ្ញៀវតែងតែធ្វើការកត់សម្គាល់ទៅលើលក្ខណសម្បត្តិបុគ្គលិក ដូចជាការស្វាគមន៍ ការបម្រើប្រកបដោយអាកប្បកិរិយាសុភាពរាបសាស្លូតបូត ភាពរួសរាយរាក់ទាក់ ស្នាមញញឹមដែលបង្កឱ្យមានលក្ខណៈកក់ក្ដៅ អត្តចរិតដែលសម្ដែងចេញជាប្រពៃណី និងវប្បធម៌ផ្ទាល់ខ្លួន។ លក្ខណៈទាំងអស់នេះទាមទារឱ្យបុគ្គលិកមានការរៀបចំទាំងផ្នែកលក្ខណសម្បត្តិទូទៅ និងសមត្ថភាពជំនាញវិជ្ជាជីវៈ។

## ១. ការសំពះ

ការសំពះគឺជាការលើកដៃទាំងពីរផ្ដុំប្រណម ម្រាមទាំងដប់ជារាងផ្កាឈូកក្រពុំ ឆ្ពោះត្រង់ទៅរកបុគ្គល ទៅរកទីឬវត្ថុដែលគួរគោរព។ ការសំពះគឺជាសកម្មភាពដ៏ល្អមួយដែលរាល់បុគ្គលិកបដិសណ្ឋារកិច្ចត្រូវតែសម្ដែងចំពោះភ្ញៀវទាំងអស់ ដោយមិនប្រកាន់វ័យ ពណ៌សម្បុរ ឬឋានៈ។ បុគ្គលិកមិនមែនស្វាគមន៍



*ការសំពះ*

តែចំពោះអតិថិជនផ្ទាល់ខ្លួននោះទេ តែត្រូវស្វាគមន៍ចំពោះភ្ញៀវគ្រប់រូបទាំងអស់ សូម្បីតែអ្នកដែលគ្រាន់តែមកសួរដំណឹង ឬព័ត៌មានបន្តិចបន្តួចក៏ដោយ។

ការគួរសមត្រូវធ្វើឡើងជាប្រចាំនៅពេលបានជួបភ្ញៀវ ដោយពុំចាំបាច់រង់ចាំឱ្យគាត់គួរសមដាក់បុគ្គលិកមុននោះទេ។ កាលណាភ្ញៀវឈានជើងចូលមកដល់ទីតាំងការងារភ្លាម បុគ្គលិកត្រូវធ្វើគារវកិច្ចជាមុនដោយលើកដៃសំពះរួចពោលពាក្យ ជម្រាបសួរ និងនៅពេលភ្ញៀវត្រឡប់ទៅវិញ ត្រូវតែជូនដំណើរភ្ញៀវដោយលើកដៃសំពះ រួចពោលពាក្យ ជម្រាបលា ជាភាសាជាតិ ឬភាសាបរទេស(ករណីភ្ញៀវជាជនជាតិបរទេស) ឬឱនក្បាលបន្តិច ជាកិច្ចគោរពលា ដោយភ្ជាប់ជាមួយការញញឹមផង។ ចំពោះពាក្យគួរសមទាំងនេះមិនត្រូវបន្លឺឱ្យឮខ្លាំងៗ ឬបន្លឺខ្សឹបតិចៗ ស្ទើរតែស្តាប់មិនបាននោះទេ គឺត្រូវបន្លឺដោយសម្លេងធម្មតា ប្រកបដោយទឹកមុខរីករាយ។

ទំនៀមទម្លាប់របស់ជនជាតិខ្មែរប្រកាន់យកការសំពះជាមធ្យោបាយនៃការគោរពគ្នា ការស្វាគមន៍ និងការប្រាស្រ័យទាក់ទងការងារផ្សេងៗ។

ការសំពះជម្រាបសួរមានខ្លឹមសារយ៉ាងសំខាន់ចំពោះភ្ញៀវ ពីព្រោះវាបានធ្វើឱ្យភ្ញៀវមានអារម្មណ៍ថាបុគ្គលិកយកចិត្តទុកដាក់ចំពោះគាត់ បុគ្គលិកបានស្វាគមន៍គាត់ និងបុគ្គលិកគោរពគាត់។

## ២. ការញញឹម

ការញញឹមគឺជាលក្ខណៈធម្មជាតិរបស់មនុស្ស ដែលមិនមែនជាការខិតខំប្រឹងធ្វើឡើយ ប៉ុន្តែវានាំឱ្យមានការទទួលស្គាល់ច្រើនពីភ្ញៀវ។ ការញញឹមនឹងធ្វើឱ្យភ្ញៀវសប្បាយរីករាយ ហើយទោះបីជាស្ថិតនៅក្នុងកាលៈទេសៈលំបាកនៃការតវ៉ា ការត្អូញត្អែររបស់ភ្ញៀវយ៉ាងណាក៏ដោយ ការញញឹមនឹងធ្វើឱ្យភ្ញៀវស្ងប់ចិត្ត កាត់បន្ថយនូវការមិនសប្បាយចិត្ត។




*ការញញឹម*

## ៣. ការស្លៀកពាក់

សម្លៀកបំពាក់ដែលបុគ្គលិកស្លៀកពាក់ ត្រូវថែរក្សាឱ្យបានស្អាតល្អគ្រប់ពេលវេលាមុននឹងចូលធ្វើការ ឬធ្វើបដិសណ្ឋារកិច្ចជាមួយភ្ញៀវ។ ភ្ញៀវអាចឱ្យតម្លៃខ្ពស់ទៅលើភាពស្អាតស្អំ និងសណ្តាប់ធ្នាប់

នៃសម្លៀកបំពាក់។ ភាពស្អាតស្អំ និងសណ្តាប់ធ្នាប់នៃការស្លៀកពាក់ គឺបង្ហាញពីការយកចិត្តទុកដាក់ និងព្យាយាមរបស់បុគ្គលិក។ សម្លៀកបំពាក់ស្អាត គឺអ៊ុតត្រឹមត្រូវ មិនរហែក មិនមានក្លិន (មានន័យថា បានបោកអ៊ុតជាប្រចាំ)។

បុគ្គលិកទាំងអស់នៅក្រៅម៉ោងធ្វើការ អាចស្លៀកពាក់បានតាមចំណូលចិត្ត តែនៅក្នុងចន្លោះពេលម៉ោងធ្វើការ ត្រូវស្លៀកពាក់ឯកសណ្ឋានឱ្យបានល្អស្អាត សមរម្យតាមការកំណត់។ ជាមួយគ្នានេះ ត្រូវចេះតុបតែងសម្អិតសម្អាងឱ្យបានល្អស្អាតសមរម្យនឹងការងារ។

## ៤. ការប្រើក្រសែភ្នែក

នៅក្នុងទំនាក់ទំនងជាមួយអតិថិជន ក្រសែភ្នែកជាមធ្យោបាយទាក់ទាញមួយដ៏ប្រសើរ ហេតុនេះ ក្នុងទំនាក់ទំនងនឹងមនុស្សម្នាក់ ការទាក់ក្រសែភ្នែកម្តងចំណាយពេលជាមធ្យមពី៥-១៥វិនាទីក្នុងពេលសន្ទនាគ្នា។ ក្នុងទំនាក់ទំនងជាមួយក្រុមចំណាយពេលជាមធ្យមពី៥-១៥វិនាទីសម្រាប់មើលមុខមនុស្សម្នាក់ៗក្នុងពេលនិយាយប្រាស្រ័យទាក់ទងគ្នា សូមទម្លាប់រៀនមើលមុខគ្នា ដើម្បីបង្កើតការទុកចិត្តខ្លួនឯងក្នុងការប្រើក្រសែភ្នែក។ សូមកុំយល់ថាការគ្រវាសភ្នែកជាការគ្រប់គ្រាន់សម្រាប់ការងារទាក់ទង។ ការថ្មឹកប្រសប់ប្រើក្រសែភ្នែកជាការសំខាន់ជាងការចោលកន្ទុយភ្នែក។ សូមកុំនិយាយឱនមើលដីឬមើលមេឃ ឬងាកមុខចេញដោយមិនមើលមុខអ្នកស្តាប់។ សូមចងចាំថា យើងកំពុងនិយាយទៅកាន់អ្នកស្តាប់ទាំងអស់គ្នា មិនមែនទៅកាន់នរណាម្នាក់នោះទេ (ចំពោះការនិយាយទៅកាន់មនុស្សជាក្រុម)។ ដូច្នេះយើងត្រូវសម្លឹងមើលមុខអ្នកស្តាប់ឱ្យបានគ្រប់ៗគ្នា។ ប្រសិនបើមិនធ្វើយ៉ាងនេះទេ អ្នកស្តាប់អាចមានការយល់ឃើញពីរយ៉ាង គឺគេស្មានថាយើងមិនមែននិយាយទៅកាន់គេទេ និងគេអាចចោទយើងថាមិនស្មោះត្រង់ជាមួយគេ ព្រោះតែនិយាយមិនមើលមុខ។ ការមិនឱ្យក្រសែភ្នែកជួបគ្នានេះ គឺជាប្រការមួយដែលគេមិនសូវចូលចិត្ត។ ចំពោះអតិថិជនមកពីលោកខាងលិចនិយមចូលចិត្តមើលមុខគ្នាក្នុងពេលសន្ទនា។ គេសន្មតថា ការនិយាយមិនមើលមុខគ្នា គឺជាការមិនសមរម្យ។

## ៥. ការយកចិត្តទុកដាក់បម្រើភ្ញៀវឱ្យបានរហ័សរហួន

នៅខណៈដែលភ្ញៀវចូលមកការិយាល័យធ្វើការរបស់អ្នក អ្នកត្រូវតែធ្វើគារវកិច្ចតបចំពោះភ្ញៀវដោយជាដំបូងត្រូវក្រោកឈរ ទាក់ទងដោយក្រសែភ្នែក ព្រមទាំងភ្ជាប់ដោយឃ្លាប្រយោគស្វាគមន៍។ ប្រសិនបើភ្ញៀវចូលមកការិយាល័យធ្វើការរបស់អ្នក ហើយអ្នកជាប់រវល់នៅកន្លែងដទៃទៀត អ្នកគួរតែប្រើប្រាស់កាយវិការ(ការប្រើប្រាស់ក្រសែភ្នែក ធ្វើសញ្ញាដៃ) ដែលអាចបញ្ជាក់ប្រាប់ថា អ្នកបានឃើញគាត់ហើយអ្នកនឹងបម្រើគាត់ក្នុងពេលបន្តិចទៀត។ នៅពេលភ្ញៀវមកដល់ ប្រសិនបើអ្នកជាប់រវល់ជាមួយនឹងអតិថិជនដទៃទៀត អ្នកត្រូវប្រើក្រសែភ្នែក ឬកាយវិការទាក់ទងជាមួយភ្ញៀវ ហើយប្រាប់ភ្ញៀវថា អ្នកនឹងបម្រើជូនគាត់នៅពេលបន្តិចទៀត។

## ៦. ការស្តាប់

មិនត្រូវបន្ទុចបង្អាក់ភ្ញៀវនៅរាល់ពេលគាត់កំពុងនិយាយ ត្រូវស្តាប់ដោយប្រុងប្រយ័ត្នចំពោះអ្វីដែលភ្ញៀវនិយាយ ដើម្បីឱ្យអ្នកអាចឆ្លើយតបទៅនឹងសំណើដ៏ពិតប្រាកដរបស់ភ្ញៀវបាន។

## ៧. ការអបអរសាទរ

កុំមកធ្វើការដោយមានទឹកមុខក្រៀមក្រំ ត្រូវមានទឹកមុខរីករាយពេលកំពុងបម្រើការងារ ត្រូវបង្ហាញថាអ្នកសប្បាយរីករាយក្នុងការធ្វើការងារ ភ្ញៀវនឹងមានអារម្មណ៍ថា អ្នកកំពុងបម្រើការងារដោយចិត្តសប្បាយរីករាយ។

## ៨. ការចេះលើកជាសំណួរ

នៅពេលអ្នកមិនយល់នូវអ្វីមួយ កុំខ្លាចរអែងក្នុងការសួរសំណួរ កុំត្រឡប់ទៅកន្លែងរបស់អ្នកវិញដោយភ្ជាប់ជាមួយនូវចម្ងល់ អ្នកនឹងមិនអាចបម្រើភ្ញៀវបានដោយត្រឹមត្រូវនោះទេ។

## ៩. ការធ្វើឱ្យភ្ញៀវមានទំនុកចិត្ត

ដើម្បីធ្វើឱ្យភ្ញៀវទុកចិត្តអ្នកត្រូវមានអារម្មណ៍ថា អ្នកអាចបំពេញការងារនេះបានដោយជាក់លាក់ យល់ដឹងពីផលិតផលរបស់ខ្លួន ដើម្បីប្រាប់ព័ត៌មានទៅភ្ញៀវ។ ធ្វើឱ្យភ្ញៀវមានអារម្មណ៍ដូចជានៅផ្ទះដោយនិយាយថា អ្នកនឹងបម្រើគាត់ដោយផ្ទាល់ និងធានាថា គាត់នឹងទទួលបាននូវបទពិសោធន៍ល្អៗក្នុងដំណើរកម្សាន្ត។

## ១០. ការបំពេញនូវចំណង់ និងតម្រូវការភ្ញៀវ

សំណួរ និងសំណើទាំងឡាយរបស់ភ្ញៀវត្រូវដោះស្រាយឆ្លើយតបនឹងតម្រូវការរបស់ភ្ញៀវឱ្យបានរហ័សរហួន។ ប្រសិនបើអ្នកជួបបញ្ហាដែលមិនអាចដោះស្រាយបាន ត្រូវសុំយោបល់ពីអ្នកគ្រប់គ្រង។

## ១១. ការដាក់ខ្លួនក្នុងស្ថានភាពភ្ញៀវ(ដាក់ខ្លួនជាអ្នកបម្រើ)

តើអ្នកចង់បានការស្វាគមន៍ភ្ញៀវដោយគ្មានការញញឹម ឬទុកឱ្យភ្ញៀវរង់ចាំតែម្នាក់ឯង? តើអ្នកធ្វើព្រងើយកន្តើយនៅពេលដែលភ្ញៀវមកដល់តុ ឬឆ្លើយទៅកាន់ភ្ញៀវដោយកំបុតខ្លីៗ? ត្រូវដាក់ខ្លួនអ្នកក្នុងស្ថានភាពភ្ញៀវដើម្បីឱ្យដឹងថា តើភ្ញៀវចូលចិត្តអ្វី មិនចូលចិត្តអ្វី ងាយស្រួលក្នុងការបម្រើ និងព្យាយាមផ្តល់ឱ្យភ្ញៀវបន្ទាប់ទៀតនូវសេវាកម្មដែលយើងចង់ទទួលដោយខ្លួនយើងផ្ទាល់។

## ១២. ការយល់ដឹងពីផលិតផលរបស់ខ្លួន

វាមិនមានលទ្ធភាពក្នុងការផ្តល់សេវាកម្មដ៏ល្អចំពោះភ្ញៀវទេ ប្រសិនបើមិនស្គាល់នូវផលិតផលដែលអ្នកកំពុងលក់។ អ្នកនឹងមានអារម្មណ៍មិនស្រួល។ អ្នកត្រូវតែយល់ដឹងនូវផលិតផលរបស់ខ្លួន ដឹងអំពីផលិតផលដែលមិនមានលក់នៅពេលខាងមុខ។

## ១៣. សេចក្តីរំពឹងរបស់ភ្ញៀវក្នុងតម្រូវការបន្ថែម

មានន័យថា ឆ្លើយតបនូវសំណើរបស់ភ្ញៀវ មុនពេលដែលគាត់សួររកអ្វីមួយ ដូចជាកែវរបស់ភ្ញៀវអស់ភេសជ្ជៈ ត្រូវចាក់បំពេញបន្ថែមជាលើកទី២។ កុំទុកឱ្យភ្ញៀវហៅឬបក់ដៃប្រាំនាទីមុនពេលដែលអ្នកឃើញ។

## ១៤. ការធ្វើឱ្យភ្ញៀវមានអារម្មណ៍ថាត្រូវបានគេស្វាគមន៍

ញញឹមជានិច្ចកាល ត្រូវប្រើឈ្មោះភ្ញៀវ(ប្រសិនបើស្គាល់) កុំនិយាយបញ្ឆិតបញ្ឆៀងឱ្យភ្ញៀវនៅពេលភ្ញៀវមានកំហុស កុំស្តីបន្ទោសចំពោះអ្នកធ្វើការជាមួយគ្នា ប្រើប្រាស់នូវគ្រប់ឱកាសដើម្បីនិយាយរៀបរាប់ពីអ្វីដែលយើងមាន កុំនិយាយអាក្រក់ពីកន្លែងធ្វើការរបស់អ្នកដោយស្របតាមភ្ញៀវ ប្រសិនបើអ្នកមិនអាចជួយភ្ញៀវ អ្នកត្រូវរាយការណ៍ទៅថ្នាក់លើ ប្រសិនបើភ្ញៀវទិតៀនឬតវ៉ា ត្រូវអរគុណចំពោះភ្ញៀវក្នុងការទិតៀន ផ្តល់យោបល់ ដែលធ្វើឱ្យយើងកាន់តែមានការប្រុងប្រយ័ត្នថែមទៀត។ ប្រសិនបើភ្ញៀវរង់ចាំ ហើយអ្នកកំពុងជាប់រវល់ អ្នកត្រូវធ្វើគារវកិច្ចតបចំពោះភ្ញៀវដោយប្រាប់ថា អ្នកនឹងបម្រើជូនពេលដ៏ឆាប់ខាងមុខ។ ប្រសិនបើអ្នកមិនអាចផ្តល់ឱ្យភ្ញៀវនូវអ្វីដែលភ្ញៀវស្នើសុំ សូមប្រាប់អ្នកគ្រប់គ្រងឬស្នើនូវដំណោះស្រាយណាមួយសមស្រប។

**មេរៀនសង្ខេប**

ក្នុងការធ្វើដំណើរ ការសម្រាកលំហែ និងកម្សាន្ត ភ្ញៀវតែងតែមានបំណងចង់ឃើញបុគ្គលិក សេវាកម្មទាំងអស់គោរព និងផ្តល់តម្លៃខ្ពស់ដល់ពួកគាត់។ ការគោរពដែលភ្ញៀវគ្រប់រូបចង់ឃើញគឺការធ្វើបដិសណ្ឋារកិច្ច មានន័យថាភ្ញៀវចង់ឃើញម្ចាស់អាជីវកម្មព្រមទាំងបុគ្គលិកនិយោជិតស្វាគមន៍ ឬធ្វើគារវកិច្ចទៅកាន់គាត់ដោយក្តីគោរព កោតសរសើរនិងស្រឡាញ់។

***បដិសណ្ឋារកិច្ច*** គឺជាសកម្មភាព និងឥរិយាបថដែលត្រូវអនុវត្តក្នុងការទទួលស្វាគមន៍ ការធ្វើគារវកិច្ចដោយក្តីគោរព ដើម្បីផ្តល់នូវភាពកក់ក្តៅ និងបំពេញនូវបំណងរបស់ភ្ញៀវ។

***បដិសណ្ឋារកិច្ចទាំងនោះមាន៖*** ការសំពះ ការញញឹម ការស្លៀកពាក់សមរម្យ ការប្រើក្រសែភ្នែកទាក់ទាញ ការយកចិត្តទុកដាក់បម្រើភ្ញៀវឱ្យបានរហ័សរហួន ការស្តាប់ដោយប្រុងប្រយ័ត្ន ការអបអរសាទរ ការចេះលើកជាសំណួរ ការធ្វើឱ្យភ្ញៀវមានទំនុកចិត្ត ការបំពេញនូវចំណង់និងតម្រូវការភ្ញៀវ ការដាក់ខ្លួនក្នុងស្ថានភាពជាអ្នកបម្រើភ្ញៀវ ការយល់ដឹងពីផលិតផលរបស់ខ្លួនសេចក្តីរំពឹងរបស់ភ្ញៀវក្នុងតម្រូវការបន្ថែម និងការធ្វើឱ្យភ្ញៀវមានអារម្មណ៍ថាត្រូវបានគេស្វាគមន៍។

## សំណួរ

១. បដិសណ្ឋារកិច្ចគឺជាអ្វី?

២. តើឥរិយាបថប៉ុន្មានយ៉ាងដែលអ្នកទទួលភ្ញៀវត្រូវអនុវត្ត? ចូររៀបរាប់ឥរិយាបថនីមួយៗ?

៣. តើការសំពះឆ្លុះបញ្ចាំងពីអ្វីខ្លះ?

៤. ហេតុអ្វីបានជាការញញឹមមានសារៈសំខាន់?

៥. តើការប្រើក្រសែភ្នែកនៅពេលប្រាស្រ័យទាក់ទងជាមួយភ្ញៀវមានប្រសិទ្ធភាពដូចម្តេចខ្លះ?

# ផលប្រយោជន៍នៃទេសចរណ៍

(ទ្រឹស្តី៥ម៉ោង)

*សិក្សាមេរៀននេះចប់សិស្សអាចៈ*

- ពណ៌នាផលប្រយោជន៍ទេសចរណ៍ក្នុងការអភិវឌ្ឍសង្គម សេដ្ឋកិច្ច វប្បធម៌ និងបរិស្ថាន
- បង្ហាញប្រភេទចំណូលពីវិស័យទេសចរណ៍
- ចូលរួមចំណែកជំរុញសេដ្ឋកិច្ចឱ្យដំណើរការទៅមុខជាប្រចាំ។

ទេសចរណ៍ជាលទ្ធភាពមួយដ៏ល្អប្រសើរ ក្នុងចំណោមលទ្ធភាពជាច្រើន ក្នុងការស្តារសេដ្ឋកិច្ច សង្គម វប្បធម៌ និងពង្រឹងកិច្ចការបរិស្ថានរបស់ប្រទេស។ ប្រទេសមួយចំនួនដែលមានភាពសម្បូរបែបនៃសម្បត្តិធម្មជាតិ ធនធានវប្បធម៌ ប្រវត្តិសាស្ត្រ ប្រាង្គប្រាសាទ អាចមានលទ្ធភាពច្រើនក្នុងការអភិវឌ្ឍវិស័យទេសចរណ៍ ។

## ១. ផលប្រយោជន៍សេដ្ឋកិច្ច

វិស័យទេសចរណ៍ បាននាំមកនូវចំណូលរាប់រយលានដុល្លារក្នុងមួយឆ្នាំៗ ដល់បណ្តាប្រទេសដែលទទួលទេសចរ។ ចំណូលទាំងនោះបានចូលរួមចំណែកក្នុងការបង្កើនល្បឿនសេដ្ឋកិច្ចជាតិទាំងមូល តាមរយៈការស្រូបយកនូវរូបិយប័ណ្ណបរទេស ផ្តល់ការងារធ្វើឱ្យជីវភាពប្រជាពលរដ្ឋមានលក្ខណៈល្អប្រសើរ និងជញ្ជីងសេដ្ឋកិច្ចមានលំនឹង។

*ផលប្រយោជន៍សេដ្ឋកិច្ចពីវិស័យទេសចរណ៍មានដូចតទៅៈ*

- ផ្តល់ចំណូលដល់ប្រជាពលរដ្ឋក្នុងតំបន់ ដោយសារការលក់ និងបម្រើសេវាកម្ម។ ឧទាហរណ៍៖ សេវាកម្មស្នាក់នៅ សេវាកម្មដឹកជញ្ជូន អាហារ និងភេសជ្ជៈ ការលក់ទំនិញ ការប្រើប្រាស់វត្ថុអនុស្សាវរីយ៍ និងសេវាកម្មកម្សាន្តផ្សេងៗ។
- ប្រភពចំណូលរូបិយប័ណ្ណបរទេស ដែលមានតម្លៃសម្រាប់ការអភិវឌ្ឍសេដ្ឋកិច្ច។ ឧទាហរណ៍៖ ចំណូលពីទិដ្ឋាការ ពន្ធលើការផ្តល់អាជ្ញាប័ណ្ណអាជីវកម្មទេសចរណ៍ ពន្ធនាំចូលទំនិញ ម្ហូបអាហារ និងភេសជ្ជៈ ពន្ធព្រលានយន្តហោះ ពន្ធដីធ្លី ពន្ធប្រាក់ចំណេញ។ ផលចំណេញពីការវិនិយោគ ចំណូលពីការលក់សំបុត្រទស្សនាទីតាំងវប្បធម៌ ប្រវត្តិសាស្ត្រ សារមន្ទីរ និងទីតាំងទេសចរណ៍ដែលរដ្ឋគ្រប់គ្រង។
- ចំណូលទេសចរណ៍ត្រូវបានគណនាដោយផ្អែកទៅលើបរិមាណទឹកប្រាក់ដែលទេសចរចំណាយនៅក្នុងប្រទេស ឬតំបន់ទេសចរណ៍។
- ការប៉ាន់ស្មានលើការចំណាយរបស់ទេសចរ នៅក្នុងប្រទេសដែលពួកគេបានមកដល់មាន៖

- ចំណាយលើការស្នាក់នៅ
- ចំណាយលើការដឹកជញ្ជូន
- ចំណាយលើម្ហូបអាហារ និងភេសជ្ជៈ
- ចំណាយលើការទស្សនា និងខ្សែទស្សនកិច្ច
- ចំណាយលើទំនិញប្រើប្រាស់ វត្ថុអនុស្សាវរីយ៍ សម្ភារៈចាំបាច់ និងចំណាយផ្សេងៗ
- ប្រាក់ដែលទេសចរចំណាយក្នុងប្រទេស ឬតំបន់ដែលពួកគាត់មកដល់ ត្រូវបានកំណត់ថាជាចំណូលទេសចរណ៍។

*វិធីសាស្ត្រពង្រឹងផលប្រយោជន៍សេដ្ឋកិច្ចពីវិស័យទេសចរណ៍មានដូចជា៖*

- ជំរុញ និងលើកទឹកចិត្តដល់ការវិនិយោគក្នុងស្រុកដើម្បីរក្សាប្រាក់ចំណូល និងផលចំណេញ
- ជំរុញផលិតកម្មវិស័យឧស្សាហកម្មដែលបម្រើឱ្យទេសចរណ៍
- កាត់បន្ថយ និងត្រួតពិនិត្យយ៉ាងតឹងរ៉ឹង លើការនាំចូលនូវទំនិញ និងសម្ភារៈទេសចរណ៍
- បង្កើនប្រសិទ្ធភាពគ្រប់គ្រងការអភិវឌ្ឍផលិតផលទេសចរណ៍ ដែលទាក់ទាញ និងមានតម្លៃ
- មានគោលនយោបាយទៅលើតម្លៃត្រឹមត្រូវ ចំពោះសេវាកម្មទេសចរណ៍សម្រាប់ភ្ញៀវជាតិ និងអន្តរជាតិ
- គ្រប់គ្រងការប្រើប្រាស់រូបិយបណ្ណបរទេសឱ្យបានត្រឹមត្រូវ ព្រមទាំងលើកកម្ពស់គុណភាពការបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈ និងគុណធម៌ក្នុងការងារទេសចរណ៍
- ស្ថិរភាពការងារជំនាញ និងបង្កើនបទពិសោធន៍ការងារឱ្យបានច្បាស់លាស់
- ធានាបែងចែកប្រាក់កម្រៃឱ្យមានតុល្យភាពទៅតាមទំហំការងារជំនាញ និងសមត្ថភាព។

## ២. ផលប្រយោជន៍សង្គម

*វិស័យទេសចរណ៍បានផ្តល់ផលប្រយោជន៍ជាច្រើនដល់សង្គម៖*

- ធ្វើឱ្យល្អប្រសើរឡើងនូវកម្រិតជីវភាពរស់នៅរបស់ប្រជាជនក្នុងសង្គមជាតិ
- ចូលរួមចំណែកក្នុងការបំបាត់នូវភាពគ្មានការងារធ្វើ និងភាពក្រីក្រនៅក្នុងសង្គម
- បង្កើតឡើងនូវទីតាំង ឬមណ្ឌលលំហែកាយ មណ្ឌលសេវាកម្មបម្រើការលំហែផ្នែកអារម្មណ៍
- ធ្វើឱ្យមានភាពកាន់តែល្អប្រសើរឡើងនូវការគោរពរាប់អានគ្នា និងការទំនាក់ទំនងគ្នា
- ផ្តល់បទពិសោធន៍ ឬការយល់ដឹងពីស្ថានភាព និងរបៀបរស់នៅរបស់ប្រជាជននៅក្នុងសង្គម
- ជំរុញដល់ការសិក្សា និងពង្រឹងសណ្តាប់ធ្នាប់ ស្ថិរភាពនយោបាយ និងជំនាញបច្ចេកទេស
- បង្កើនចំណេះដឹងដល់ប្រជាពលរដ្ឋអំពីសារប្រយោជន៍នៃសម្បត្តិវប្បធម៌ និងបេតិកភណ្ឌជាតិ
- បង្កើតច្បាប់ បទបញ្ញត្តិសម្រាប់ ទប់ស្កាត់អំពើចោរកម្មលួច ប្លន់ នៅតំបន់ទេសចរណ៍។

*វិធីសាស្ត្រពង្រឹងផលប្រយោជន៍សង្គមពីវិស័យទេសចរណ៍៖*

- ធានាសុវត្ថិភាព និងសន្តិសុខដល់ទេសចរ ឱ្យបានព្រមទាំងបង្កើតការជឿទុកចិត្ត

- បង្កលក្ខណៈងាយស្រួលក្នុងការបំពេញបែបបទទិដ្ឋាការសម្រាប់ការពន្យារយៈពេលស្នាក់នៅដល់ទេសចរ
- មានវិធានការ និងបង្កើនការអនុវត្តច្បាប់ដើម្បីលុបបំបាត់ឧក្រិដ្ឋកម្មផ្សេងៗ
- គ្រប់គ្រងត្រួតពិនិត្យ និងមានវិធានការណ៍បំបាត់ការប្រើប្រាស់ និងជួញដូរគ្រឿងញៀន
- បំបាត់ចោលនូវអាជីវកម្មផ្លូវភេទ និងអនុវត្តច្បាប់តឹងរ៉ឹងទៅលើការជួញដូរកុមារ
- ផ្សព្វផ្សាយ និងណែនាំឱ្យបានទូលំទូលាយអំពីរបៀបបង្ការជំងឺឆ្លង។

## ៣. ផលប្រយោជន៍វប្បធម៌

*វិស័យទេសចរណ៍បានផ្តល់ផលប្រយោជន៍ជាច្រើនដល់វប្បធម៌៖*

- រួមចំណែកក្នុងការអភិរក្សសំណង់វប្បធម៌ ប្រវត្តិសាស្ត្រ បេតិកភណ្ឌជាតិ និងធនធានវប្បធម៌ផ្សេងៗ
- លើកទឹកចិត្តរៀបចំសម្តែង សិល្បៈ ល្ខោន របាំ និងការប្រគំតន្ត្រី
- ខិតខំរក្សាអត្តសញ្ញាណជាតិ អត្តចរិត អាកប្បកិរិយា របៀបរស់នៅ ទំនៀមទម្លាប់ ប្រពៃណី
- ផ្តល់ឱកាស សម្រាប់ការផ្លាស់ប្តូរ ផ្នែកវប្បធម៌ រវាងទេសចរ និងពលរដ្ឋម្ចាស់ស្រុក
- នាំឱ្យមានការយោគយល់គ្នារវាងជាតិសាសន៍មួយ ទៅជាតិសាសន៍មួយទៀត។

*វិធីសាស្ត្រពង្រឹងផលប្រយោជន៍វប្បធម៌ ពីវិស័យទេសចរណ៍មាន៖*

- ផ្តល់ព័ត៌មានអំពីទំនៀមទម្លាប់ ប្រពៃណី និងលក្ខណៈនៃវប្បធម៌ផ្សេងៗរបស់ម្ចាស់ស្រុកដល់ភ្ញៀវ ដើម្បីឱ្យភ្ញៀវទេសចរបានយល់ដឹងនិងគោរពតាម
- ជំរុញឱ្យមានការរៀបចំការិយាល័យព័ត៌មាននៅគ្រប់តំបន់ចេញចូលនៃទេសចរ ជាពិសេសព័ត៌មានអំពីសិទ្ធិដែលទេសចរនៅក្នុងតំបន់បានមកដល់
- ណែនាំ និងអប់រំដល់យុវវ័យឱ្យត្រងត្រាប់វប្បធម៌បរទេសណាដែលល្អ ហើយវប្បធម៌ណាដែលត្រូវចៀសវាង ព្រោះធ្វើឱ្យប្រាសចាក និងប៉ះពាល់ដល់វប្បធម៌ជាតិ
- រក្សាទំនៀមទម្លាប់ ប្រពៃណី ភាសា សាសនា របាំ តន្ត្រី សិល្បៈ និងបណ្តាសិប្បកម្មដែលមានលក្ខណៈដើមនៅក្នុងស្រុក។ រៀបចំឱ្យមានសាលមហោស្រព ការសម្តែងសិល្បៈ ឱ្យបានល្អប្រសើរ
- រក្សាឱ្យបានគង់វង្សនូវសំណង់ វប្បធម៌ ប្រវត្តិសាស្ត្រ សម្បត្តិបេតិកភណ្ឌជាតិ និងសំណង់ដែលមានរចនាបទស្ថាបត្យកម្មបុរាណ
- បង្កើតច្បាប់ ដើម្បីទប់ស្កាត់ការលួចលាក់វត្ថុបុរាណ
- បណ្តុះម្ចាស់ស្រុកឱ្យសម្តែងអត្តចរិត អាកប្បកិរិយាស្លូតបូត សុភាពរាបសារក្នុងការស្វាគមន៍ភ្ញៀវទេសចរ ទោះជាបរិមាណភ្ញៀវទេសចរកើនឡើងច្រើនយ៉ាងណាក៏ដោយ
- បង្កើនការអប់រំប្រជាជន និងទេសចរឱ្យយល់ពីតម្លៃនៃវិស័យទេសចរណ៍ចូលរួមក្នុងការការពារអភិរក្សវប្បធម៌ប្រពៃណី និងប្រាង្គប្រាសាទដើម្បីភាពយូរអង្វែងនៃវិស័យទេសចរណ៍

- រៀបចំនិងតម្រូវឱ្យមានការកំណត់ចំនួនទេសចរដែលចូលទស្សនាតំបន់ ទីកន្លែង ឬមណ្ឌលទេសចរណ៍ឱ្យបានត្រឹមត្រូវ ដើម្បីធានានូវលទ្ធភាពនៃការទទួលដែលមិនមានផលប៉ះពាល់
- បង្កើននូវកិច្ចសហប្រតិបត្តិការ រវាងក្រសួងទេសចរណ៍និងក្រសួងដែលពាក់ព័ន្ធក្នុងការត្រួតពិនិត្យ និងវាយតម្លៃ ផលប៉ះពាល់ទាំងឡាយពីវិស័យទេសចរណ៍។

## ៤. ផលប្រយោជន៍បរិស្ថាន

*ផលប្រយោជន៍បរិស្ថានមានៈ*

- រួមចំណែកដ៏សំខាន់ក្នុងកិច្ចការថែរក្សា និងការពារបរិស្ថានធម្មជាតិមាន រុក្ខជាតិ សត្វព្រៃ ទឹកធ្លាក់ បឹង ស្ទឹង ទន្លេ សមុទ្រ កោះ ឆ្នេរខ្សាច់ និងធម្មជាតិកម្រដទៃទៀត
- រួមចំណែកក្នុងកិច្ចការថែរក្សា និងការពារបរិស្ថានសង្គមដូចជា ការរៀបចំសហគមន៍ឱ្យមានរបៀបរៀបរយ និងមានសោភណភាព យកចិត្តទុកដាក់លើបញ្ហាអនាម័យ
- ផ្លាស់ប្តូរបទពិសោធន៍ទៅវិញទៅមករវាងភ្ញៀវទេសចរ និងម្ចាស់ស្រុក អំពីរបៀបរស់នៅស្អាតប្រកបដោយអនាម័យត្រឹមត្រូវ និងមានសុខុមាលភាព
- ជួយជំរុញដល់ការរៀបចំសេវាកម្មទេសចរណ៍ឱ្យកាន់តែប្រសើរឡើង តាមកម្រិតស្តង់ដាត្រឹមត្រូវ ឧទាហរណ៍ៈ សណ្ឋាគារ ផ្ទះសំណាក់ ភោជនីយដ្ឋាន រង្គសាល ទីតាំងកម្សាន្តទេសចរណ៍...
- ធ្វើឱ្យប្រសើរឡើងនូវការគ្រប់គ្រងកាកសំណល់ និងបង្កើនការយល់ដឹងផ្នែកបរិស្ថានដល់សហគមន៍ និងទេសចរតាមរយៈការផ្តល់ព័ត៌មាន និងស្លាកសញ្ញាផ្តល់ដំណឹង។

*វិធីសាស្ត្រពង្រឹងផលប្រយោជន៍បរិស្ថានពីវិស័យទេសចរណ៍ៈ*

- អភិវឌ្ឍបណ្តាញផ្លូវគោក ផ្លូវទឹក ផ្លូវអាកាសឱ្យបានល្អប្រសើរ
- ប្រើប្រាស់មធ្យោបាយដឹកជញ្ជូនមានគុណភាព និងទំនើបសមស្របទៅនឹងស្ថានភាព
- មានវិធីសាស្ត្រ និងបច្ចេកទេសល្អប្រសើរ ដើម្បីគ្រប់គ្រងកាកសំណល់រឹង និងរាវ
- រៀបចំចំណតរថយន្តឱ្យបានគ្រប់គ្រាន់ និងត្រឹមត្រូវតាមមណ្ឌលសេវាកម្មទេសចរណ៍
- មិនបំផ្លាញ និងបង្កើនការថែរក្សា ព្រៃឈើ មិនសម្លាប់សត្វព្រៃធ្វើជាអាហារ
- បង្កើនការអនុវត្តច្បាប់ការពារបរិស្ថាន និងគ្រប់គ្រងធនធានធម្មជាតិឱ្យមានប្រសិទ្ធភាព
- ការពារ និងគ្រប់គ្រងផលប៉ះពាល់នៃគម្រោងអភិវឌ្ឍវិស័យទេសចរណ៍ទៅលើបរិស្ថាន
- ជំរុញការអនុវត្តច្បាប់ ឬអនុក្រឹត្យ ស្តីពីដំណើរការវាយតម្លៃផលប៉ះពាល់បរិស្ថានបង្កើតនូវការអនុវត្តច្បាប់សម្រាប់គ្រប់គ្រង និងអភិរក្សបរិស្ថានធម្មជាតិឱ្យមាននិរន្តរភាព។

**មេរៀនសង្ខេប**

វិស័យទេសចរណ៍រួមចំណែកយ៉ាងសំខាន់ក្នុងការផ្តល់ប្រយោជន៍*សេដ្ឋកិច្ច សង្គម វប្បធម៌ និងបរិស្ថានៈ*

- ជាប្រភពដ៏សំខាន់មួយក្នុងការរកប្រាក់ចំណូលដល់ពលរដ្ឋក្នុងតំបន់ទេសចរណ៍
- ជាប្រភពចំណូលដល់ពលរដ្ឋ និងរាជរដ្ឋាភិបាលក្នុងវិស័យទេសចរណ៍
- រួមចំណែកអភិវឌ្ឍសេដ្ឋកិច្ចជាតិ
- ជាចលករជំរុញការអភិវឌ្ឍអាជីវកម្ម កន្លែងកម្សាន្ត(រមណីយដ្ឋាន) ដើម្បីទាក់ទាញទេសចរ
- ជំរុញឱ្យមានការយកចិត្តទុកដាក់ថែរក្សាសម្បត្តិធម្មជាតិ វប្បធម៌ បេតិកភណ្ឌជាតិ
- ជំរុញឱ្យមានការរីកដុះដាលអាជីវកម្មដឹកជញ្ជូន និងពង្រីកកន្លែងផ្តល់សេវាកម្មគមនាគមន៍
- បង្កើនបរិមាណលក់ទំនិញឧស្សាហកម្ម វត្ថុអនុស្សាវរីយ៍ដែលផលិតនៅក្នុងប្រទេស
- លំហូរចូលមកក្នុងតំបន់ និងប្រទេសអភិវឌ្ឍទេសចរណ៍នូវរូបិយវត្ថុបរទេស
- រួមចំណែកដ៏សំខាន់ក្នុងកិច្ចការថែរក្សា និងការពារបរិស្ថានធម្មជាតិ
- បង្កើនការយល់ដឹងផ្នែកបរិស្ថានដល់សហគមន៍ និងទេសចរ។

## សំណួរ

១. តើវិស័យទេសចរណ៍ផ្តល់ប្រយោជន៍អ្វីខ្លះដល់ប្រទេសជាតិ?

២. តើទេសចរត្រូវចំណាយទៅលើអ្វីខ្លះក្នុងដំណើរទេសចរណ៍របស់ពួកគេ?

៣. តើវិស័យទេសចរណ៍ផ្តល់ផលប្រយោជន៍អ្វីខ្លះដល់សេដ្ឋកិច្ច?

៤. តើវិស័យទេសចរណ៍ផ្តល់ផលប្រយោជន៍អ្វីខ្លះដល់សង្គម?

៥. តើវិស័យទេសចរណ៍ផ្តល់ផលប្រយោជន៍អ្វីខ្លះដល់វប្បធម៌?

៦. តើវិស័យទេសចរណ៍ផ្តល់ផលប្រយោជន៍អ្វីខ្លះដល់បរិស្ថាន?

# ការប្រឡងប្រណាំងទីក្រុងស្អាត

*(ទ្រឹស្តី៦ម៉ោង អនុវត្ត៨ម៉ោង)*

*សិក្សាមេរៀននេះចប់សិស្សអាច*

- រៀបរាប់ពីគណៈកម្មាធិការជាតិវាយតម្លៃទីក្រុងស្អាត
- បង្ហាញគោលបំណងនៃការប្រឡងប្រណាំងទីក្រុងស្អាត
- រៀបរាប់ស្តង់ដាទីក្រុងស្អាត និងនីតិវិធី
- ពន្យល់ពីអត្ថប្រយោជន៍នៃការចូលរួមក្នុងការប្រឡងប្រណាំងទីក្រុងស្អាត
- ចូលរួមក្នុងការប្រឡងប្រណាំងទីក្រុងស្អាតដោយចាប់ផ្តើមពីខ្លួនឯងផ្ទាល់។

ការប្រឡងប្រណាំងទីក្រុងស្អាតនឹងរៀបចំជារៀងរាល់បីឆ្នាំម្តង ហើយទីក្រុងជ័យលាភីនឹងទទួលបានរង្វាន់ និងស្លាកសញ្ញា ដែលមានសុពលភាពសម្រាប់រយៈពេលបីឆ្នាំ ការប្រឡងប្រណាំងទីក្រុងស្អាត គឺជាប្រព័ន្ធនៃការផ្តល់ឡាបិល និងចំណាត់ថ្នាក់ដល់ក្រុងទទួលបានជ័យលាភី ពោលគឺពុំមែនជាការប្រកួតប្រជែងរវាងទីក្រុងបេក្ខភាពទាំងឡាយដោយផ្ទាល់នោះទេ។ ទីក្រុងទាំង២៦ និងខណ្ឌទាំង១៤នៃរាជធានីភ្នំពេញត្រូវចូលរួមការប្រឡងប្រណាំងនេះដោយកាតព្វកិច្ច។

**"ទីក្រុងស្អាត"** គឺសំដៅដល់ទីក្រុងណាដែលមានបរិស្ថាន អនាម័យ សណ្តាប់ធ្នាប់ គួបផ្សំនឹងហេដ្ឋារចនាសម្ព័ន្ធទ្រទ្រង់គ្រប់គ្រាន់ ដែលផ្តល់នូវភាពកក់ក្តៅ និងមជ្ឈដ្ឋានរស់នៅល្អប្រសើរដល់ប្រជាជនក្នុងទីក្រុង និងទេសចរ។

## ១. គណៈកម្មាធិការជាតិវាយតម្លៃទីក្រុងស្អាត

គណៈកម្មាធិការជាតិវាយតម្លៃទីក្រុងស្អាត ត្រូវបានបង្កើតឡើងក្រោមព្រះរាជក្រឹត្យលេខ នស/រក/០៦១១/៦១៤ ចុះថ្ងៃទី២៥ ខែមិថុនា ឆ្នាំ២០១១ ស្តីពីការបង្កើត "គណៈកម្មាធិការជាតិវាយតម្លៃទីក្រុងស្អាត" ដែលហៅកាត់ថា "គ.ជ.វ.ទ"។ "គ.ជ.វ.ទ" មានតួនាទីគ្រប់គ្រង ជំរុញ និងធានាលើដំណើរការចលនាប្រឡងប្រណាំងទីក្រុងស្អាត។

"គ.ជ.វ.ទ" មានសម្តេចនាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជាជាប្រធានកិត្តិយស និង ឯកឧត្តមរដ្ឋមន្ត្រីក្រសួងទេសចរណ៍ជាប្រធាន និងសមាជិកជាតំណាងមកពីក្រសួង និងស្ថាប័នពាក់ព័ន្ធ។

## ២. គោលបំណងនៃការប្រឡងប្រណាំងទីក្រុងស្អាត

ការប្រឡងប្រណាំងទីក្រុងស្អាត គឺជាការរួមចំណែកដល់ការពន្លឿនការអភិវឌ្ឍយុទ្ធសាស្រ្តស្នូលរបស់រាជរដ្ឋាភិបាលកម្ពុជាដូចជា៖

- ជំរុញការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធគ្រប់ផ្នែកដូចជា ផ្លូវថ្នល់ ស្ពាន ប្រព័ន្ធផ្គត់ផ្គង់ទឹកស្អាត សាលារៀន មន្ទីរពេទ្យជាដើម

- ពង្រីកបន្ថែមនូវសន្តិសុខ សុវត្ថិភាពសង្គមតាមរយៈការចូលរួមបន្ថែមទៅក្នុងគោលនយោបាយ "ភូមិឃុំមានសុវត្ថិភាព"
- ពង្រឹងគុណភាពសេវាសាធារណៈ និងសេវាទេសចរណ៍
- ចូលរួមដល់ការអភិវឌ្ឍទេសចរណ៍បៃតងនៅកម្ពុជា
- ចូលរួមដល់ការធ្វើសមាហរណកម្មកម្ពុជាទៅក្នុងតំបន់ និងសកលលោក។

ជារួមការប្រឡងប្រណាំងទីក្រុងស្អាតធ្វើឡើងក្នុងគោលបំណង លើកកម្ពស់សោភណភាពបរិស្ថាន អនាម័យ និងសណ្តាប់ធ្នាប់ទីក្រុងនៃព្រះរាជាណាចក្រកម្ពុជា ជាពិសេសចូលរួមក្នុងសកម្មភាព និងយុទ្ធសាស្ត្រអភិវឌ្ឍន៍នានារបស់រាជរដ្ឋាភិបាលតាមរយៈ៖

- ផ្តួចផ្តើម និងបទដ្ឋានគំរូជាមូលដ្ឋានសំដៅធ្វើឱ្យបរិស្ថានល្អ ភាពស្អាត និងមជ្ឈដ្ឋានរស់នៅកាន់តែល្អប្រសើរឡើងនៅតាមបណ្តាទីក្រុង
- បញ្ជ្រាបការយល់ដឹងដល់រដ្ឋបាលថ្នាក់ក្រោមជាតិ និងប្រតិបត្តិករទេសចរណ៍ពីសារៈសំខាន់នៃការគ្រប់គ្រងបរិស្ថាន និងភាពស្អាតឱ្យស្របតាមទស្សនវិស័យនៃការអភិវឌ្ឍទេសចរណ៍ប្រកបដោយនិរន្តរភាព
- ជំរុញលើកទឹកចិត្តដល់អ្នកដើរតួនាទីសំខាន់ៗក្នុងវិស័យទេសចរណ៍(ដូចជាម្ចាស់សណ្ឋាគារ ម្ចាស់ភោជនីយដ្ឋាន និងអ្នកគ្រប់គ្រងសម្បទាទេសចរណ៍ផ្សេងៗទៀត)
- ចូលរួមកសាងប្លង់មេអភិវឌ្ឍទីក្រុង
- ចូលរួមគិតគូរដល់ភាពស្អាត និងមជ្ឈដ្ឋានរស់នៅល្អប្រសើរ តាមតំបន់ទីក្រុងទាំងនោះ
- ពង្រឹងសកម្មភាពនៃការកាត់បន្ថយភាពក្រីក្រតាមរយៈវិស័យទេសចរណ៍ ដោយជំរុញពង្រីកលំហូរភ្ញៀវទេសចរនៅគ្រប់តំបន់នៃព្រះរាជាណាចក្រកម្ពុជា។

## ៣. ស្តង់ដាទីក្រុងស្អាត

ការប្រឡងប្រណាំងទីក្រុងស្អាតនេះ ធ្វើឡើងដោយផ្អែកលើ "ឯកសារស្តង់ដាទីក្រុងស្អាត" ដែលរួមមានសូចនាករគោលចំនួន៧ បែងចែកជាសូចនាករលម្អិតចំនួន៣៣ ហើយត្រូវបានកំណត់ធ្វើការវាយតម្លៃដោយផ្អែកលើលក្ខណវិនិច្ឆ័យចំនួន៧៧។

សូចនាករគោលទាំង៧នៃស្តង់ដាទីក្រុងស្អាតរួមមាន៖

- **សូចនាករគោលស្តីពីការរៀបចំ និងគ្រប់គ្រងបរិស្ថាន** គឺផ្តោតទៅលើការរៀបចំទីក្រុង ការគិតគូរពីគុណភាពទឹក គុណភាពខ្យល់ ការបំពុលដោយសំឡេង និងការប្រើប្រាស់ថាមពលដែលគិតគូរដល់បរិស្ថាន។
- **សូចនាករគោលស្តីពីភាពស្អាត** គឺផ្តោតទៅលើភាពស្អាតនៅតាមកន្លែងសាធារណៈ ដូចជាអគារសាធារណៈ សួនច្បារ សួនកម្សាន្ត បង្គន់សាធារណៈ ភាពស្អាតនៅតាមទីកន្លែងនិងវិថីសំខាន់ៗ។
- **សូចនាករគោលស្តីពីការគ្រប់គ្រងសំណល់**គឺ ផ្តោតទៅលើការគ្រប់គ្រងសំណល់រឹង ការគ្រប់គ្រងសំណល់រាវ ការស្តុកសំណល់រឹង ការបែងចែកសំណល់រឹង និងប្រព្រឹត្តិកម្មសំណល់រាវ

ជាដើម។

- **សូចនាករស្តីពីការបញ្ជ្រាបការយល់ដឹង** គឺផ្តោតទៅលើការបញ្ជ្រាបការយល់ដឹងពីបរិស្ថាន និងភាពស្អាតដល់ប្រជាជនមូលដ្ឋាន សាធារណជន ប្រតិបត្តិករទេសចរណ៍ និងទេសចរ។
- **សូចនាករគោលស្តីពីតំបន់បៃតង** គឺផ្តោតលើការបង្កើតឱ្យមានតំបន់បៃតង ការរៀបចំ និងការថែទាំគ្រប់គ្រងតំបន់បៃតងនៅក្នុងទីក្រុង។
- **សូចនាករគោលស្តីពីសុវត្ថិភាពសុខាភិបាល សន្តិសុខ និងសណ្តាប់ធ្នាប់ទីក្រុង**។
- **សូចនាករគោលស្តីពីហេដ្ឋារចនាសម្ព័ន្ធ និងសម្បទាទេសចរណ៍** គឺផ្តោតលើការជំរុញឱ្យមានបន្ថែមទៀតនូវហេដ្ឋារចនាសម្ព័ន្ធផ្លូវថ្នល់ គ្រឹះស្ថានអប់រំ ផែនការមេសម្រាប់ការអភិវឌ្ឍទេសចរណ៍ មជ្ឈមណ្ឌល ។ល។

## ៤. នីតិវិធីនៃការប្រឡងប្រណាំងទីក្រុងស្អាត

ក្រុង ឬខណ្ឌដែលទទួលបានជ័យលាភី មានសុពលភាពរយៈពេល៣ឆ្នាំ។ នីតិវិធីនៃការប្រឡងប្រណាំងទីក្រុងស្អាតលើកទី១មាន៦ដំណាក់កាលធំៗៈ

| | | |
|---|---|---|
| ដំណាក់កាលទី១ | : | ការផ្តល់ និងទទួលពាក្យសុំចូលរួមការប្រឡងប្រណាំងទីក្រុងស្អាត |
| ដំណាក់កាលទី២ | : | ការពិនិត្យ និងវាយតម្លៃបឋមលើពាក្យសុំចូលរួមការប្រឡងប្រណាំងរបស់ទីក្រុង/ខណ្ឌបេក្ខភាព។ |
| ដំណាក់កាលទី៣ | : | ការបំពេញសំណុំឯកសារ ដែលខ្វះខាតដោយទីក្រុង/ខណ្ឌបេក្ខភាព។ |
| ដំណាក់កាលទី៤ | : | ការពិនិត្យលើឯកសារ ទីតាំង និងការវាយតម្លៃជាលើកចុងក្រោយរបស់គ.ជ.វ.ទ។ |
| ដំណាក់កាលទី៥ | : | ការប្រកាសលទ្ធផលនៃការប្រឡងប្រណាំងទីក្រុងស្អាត។ |
| ដំណាក់កាលទី៦ | : | ការរៀបចំពិធីប្រកាស និងផ្តល់រង្វាន់ដល់ទីក្រុង/ខណ្ឌជ័យលាភី។ |

**ទីក្រុងជ័យលាភីចែកចេញជាបីកម្រិតៈ**

១. ឡាបិល រូបផ្កាវំដួលបីទង នឹងត្រូវប្រគល់ជូនទីក្រុងណាដែលទទួលបាន ពិន្ទុពី៥៨ដល់៧៧ (លក្ខណវិនិច្ឆ័យយ៉ាងហោចណាស់ស្មើនឹង ៧៥%នៃពិន្ទុសរុប)

២. ឡាបិល រូបផ្កាវំដួលពីរទង នឹងត្រូវប្រគល់ជូនទីក្រុងណាដែលទទួលបាន ពិន្ទុពី៤៦ដល់៥៧ (លក្ខណវិនិច្ឆ័យយ៉ាងហោចណាស់ស្មើនឹង៦០%នៃពិន្ទុសរុប)

៣. ឡាបិល រូបផ្កាវំដួល១ទង នឹងត្រូវប្រគល់ជូនទីក្រុងណាដែលទទួលបាន ពិន្ទុពី៣១ដល់៤៥ (លក្ខណវិនិច្ឆ័យយ៉ាងហោចណាស់ស្មើនឹង៤០%នៃពិន្ទុសរុប)

# ៥. អត្ថប្រយោជន៍នៃការចូលរួមក្នុងការប្រឡងប្រណាំងទីក្រុងស្អាត

គំរូវិញ្ញាបនបត្រទទួលស្គាល់ទីក្រុងជ័យលាភី




វិញ្ញាបនបត្រទទួលស្គាល់ទីក្រុងជ័យលាភី
ដែលទទួលបានស្លាកសញ្ញារូបផ្ការំដួល ១ ទង

៧

គំរូវិញ្ញាបនបត្រទទួលស្គាល់ទីក្រុងជ័យលាភី




វិញ្ញាបនបត្រទទួលស្គាល់ទីក្រុងជ័យលាភី
ដែលទទួលបានស្លាកសញ្ញារូបផ្ការំដួល ២ ទង

៦

គំរូវិញ្ញាបនបត្រទទួលស្គាល់ទីក្រុងជ័យលាភី




វិញ្ញាបនបត្រទទួលស្គាល់ទីក្រុងជ័យលាភី
ដែលទទួលបានស្លាកសញ្ញារូបផ្ការំដួល ៣ ទង

៥

ឧបសម្ព័ន្ធនៃអនុក្រឹត្យលេខ ២៩ អនក្រ.បក ចុះថ្ងៃទី ២៤ ខែ កុម្ភៈ ឆ្នាំ២០១២
ស្តីពីការកំណត់ពានរង្វាន់សម្រាប់ការប្រឡងប្រណាំងទីក្រុងស្អាត
ពានរង្វាន់សម្រាប់ទីក្រុងជ័យលាភី



ពានរង្វាន់សម្រាប់ទីក្រុងជ័យលាភី ដែលទទួលបានស្លាកសញ្ញារូបផ្ការំដួល ១ ទង

ពានរង្វាន់សម្រាប់ទីក្រុងជ័យលាភី ដែលទទួលបានស្លាកសញ្ញារូបផ្ការំដួល ២ ទង

ពានរង្វាន់សម្រាប់ទីក្រុងជ័យលាភី ដែលទទួលបានស្លាកសញ្ញារូបផ្ការំដួល ៣ ទង

*គំរូវិញ្ញាបនបត្រទីក្រុងជ័យលាភីតាមលំដាប់នៃចំនួនផ្ការំដួល និង ពានរង្វាន់ជ័យលាភីទីក្រុងស្អាត*

ការប្រឡងប្រណាំងទីក្រុងស្អាតផ្តល់ផលប្រយោជន៍ជាច្រើនសម្រាប់គ្រប់ភាគីពាក់ព័ន្ធដូចជា៖

### ៥.១. ទីក្រុងជ័យលាភី

- ទីក្រុងជ័យលាភីទទួលបានពានរង្វាន់ជ័យលាភីទីក្រុងស្អាត
- ទីក្រុងជ័យលាភីទទួលស្លាកសញ្ញាជាការលើកទឹកចិត្តក្នុងការថែរក្សា និងលើកកម្ពស់ស្តង់ដាបរិស្ថានទីក្រុងឱ្យមានសោភណភាព ដែលវាជាកិត្តិយសមួយសម្រាប់ជ័យលាភី
- ជួយលើកកម្ពស់កិត្តិយសទីក្រុង បង្ហាញដល់ភ្ញៀវទេសចរ និងគ្រប់ភាគីពាក់ព័ន្ធពិសេសអ្នកវិនិយោគ អង្គការជាតិ និងអន្តរជាតិ
- ទទួលបានឧត្តមភាព និងអត្ថប្រយោជន៍ប្រៀបធៀបលើទីក្រុងដទៃទៀត ដោយធានាបាននូវផលប៉ះពាល់ជាអប្បរមាលើបរិស្ថាន។

### ៥.២. ប្រជាជនក្នុងទីក្រុង

- ជួយលើកកម្ពស់លក្ខណ្ឌរស់នៅរបស់ប្រជាជនក្នុងទីក្រុងឱ្យមានភាពប្រសើរ
- អប់រំពីផលប៉ះពាល់ ដែលបណ្តាលមកពីសកម្មភាពប្រចាំថ្ងៃទៅលើបរិស្ថាន សង្គម និងខ្លួនរបស់ពួកគាត់ផ្ទាល់
- បញ្ជ្រាបការយល់ដឹងដល់ប្រជាជនក្នុងទីក្រុងឱ្យយល់ដឹងពីសារៈសំខាន់នៃបរិស្ថានស្អាតនៅក្នុងទីក្រុង និងនៅតាមទីប្រជុំជន។

### ៥.៣. ឧស្សាហកម្មទេសចរណ៍

ប្រើប្រាស់ធ្វើជាគំរូមូលដ្ឋានក្នុងការអភិវឌ្ឍឧស្សាហកម្មទេសចរណ៍ ប្រកបដោយនិរន្តរភាព។ ទីក្រុងស្អាតគឺជាឧបករណ៍មួយដែលអាចប្រើប្រាស់ក្នុងការផ្សព្វផ្សាយពី"សេវាកម្មបៃតង"។

### ៥.៤. អ្នកទេសចរ

- ទទួលបាននូវសេវាកម្មទេសចរណ៍ប្រកបដោយគុណភាពល្អ
- អប់រំភ្ញៀវទេសចរជាតិ និងអន្តរជាតិឱ្យយល់ដឹងពីផលប៉ះពាល់នៃសកម្មភាពរបស់ពួកគេទៅលើបរិស្ថាន
- ផ្តល់ព័ត៌មានដល់ភ្ញៀវទេសចរថា ជាទីក្រុងស្អាត គឺជាជម្រើសដ៏ល្អសម្រាប់ពួកគេក្នុងការជ្រើសរើសកន្លែងលំហែកាយក្នុងអំឡុងពេលវិស្សមកាល។

ជារួមការប្រឡងប្រណាំងទីក្រុងស្អាត ជាយន្តការសំខាន់មួយក្នុងការឆ្លើយតបទៅនឹងបញ្ហាបម្រែបម្រួលអាកាសធាតុ ពោលគឺចូលរួមកសាង"សេដ្ឋកិច្ចបៃតង"នៅកម្ពុជា។

## ៦. ការប្រឡងប្រណាំងទីក្រុងស្អាត

ដើម្បីគាំទ្រដល់ការប្រឡងប្រណាំងទីក្រុងស្អាត គណៈកម្មាធិការជាតិវាយតម្លៃទីក្រុងស្អាតបានដាក់ចេញនូវយុទ្ធនាការ៖

- យុទ្ធនាការ "ទីក្រុងស្អាតជាទីក្រុងដែលគ្មានសំរាមជាថង់ប្លាស្ទិចហើរតាមខ្យល់"

- យុទ្ធនាការ "ទេសចរម្នាក់ ដើមឈើមួយដើម"
- យុទ្ធនាការ "យុវជន និងទីក្រុងស្អាត"
- យុទ្ធនាការ "ផ្សារស្អាត សាលាស្អាត"
- យុទ្ធនាការ "កម្ពុជាស្អាត" ជាដើម។

ដូចនេះ ក្នុងនាមប្អូនជាសិស្ស និងពលរដ្ឋខ្មែរមួយរូប ដើម្បីចូលរួមចលនាប្រឡងប្រណាំងទីក្រុងស្អាត ប្អូនៗត្រូវគាំទ្រក្នុងសកម្មភាពនានាដូចក្នុងយុទ្ធនាការខាងលើ។

**មេរៀនសង្ខេប**

ការប្រឡងប្រណាំងទីក្រុងស្អាត ធ្វើឡើងក្នុងគោលបំណង លើកកម្ពស់សោភណភាព
បរិស្ថាន អនាម័យ និងសណ្ដាប់ធ្នាប់ទីក្រុងនៃព្រះរាជាណាចក្រកម្ពុជា ជាពិសេសចូលរួមក្នុងសកម្មភាព និងយុទ្ធសាស្ត្រអភិវឌ្ឍន៍នានារបស់រាជរដ្ឋាភិបាល។ ការប្រឡងប្រណាំងទីក្រុងស្អាតនេះធ្វើឡើងដោយផ្អែកលើ "ឯកសារស្តង់ដាទីក្រុងស្អាត" ដែលរួមមានសូចនាករគោលចំនួន៧ បែងចែកជាសូនាករលម្អិតចំនួន៣៣ ហើយត្រូវបានកំណត់ធ្វើការវាយតម្លៃដោយផ្អែកលើលក្ខណវិនិច្ឆ័យចំនួន៧៧។ ការប្រឡងប្រណាំងទីក្រុងនឹងរៀបចំជារៀងរាល់បីឆ្នាំម្ដង ហើយទីក្រុងជ័យលាភីនឹងទទួលបានរង្វាន់ និងស្លាកសញ្ញា ដែលមានសុពលភាពសម្រាប់រយៈពេលបីឆ្នាំ។ សម្រាប់ជ័យលាភីទីក្រុងស្អាតត្រូវបានចែកជាបីកម្រិតគឺ ឡាបិលរូបផ្កាវិដួល៣ទង ២ទង និង១ទង។

ជារួមការប្រឡងប្រណាំងទីក្រុងស្អាត បានផ្ដល់នូវផលប្រយោជន៍ជាច្រើនសម្រាប់គ្រប់ភាគីពាក់ព័ន្ធ ពិសេសទីក្រុងជ័យលាភី ប្រជាជនក្នុងទីក្រុង ឧស្សាហកម្មទេសចរណ៍ និងអ្នកទេសចរ។

**"ទីក្រុងស្អាត សុខសុវត្ថិភាពល្អ ទេសចរណ៍មានកំណើន"**

## សំណួរ

១. ចូររៀបរាប់ពីសមាសភាពក្នុងគណៈកម្មាធិការជាតិវាយតម្លៃទីក្រុងស្អាត?

២. តើការប្រឡងប្រណាំងទីក្រុងស្អាតជាអ្វី?

៣. តើការចូលរួមក្នុងចលនាប្រឡងប្រណាំងទីក្រុងស្អាតផ្ដល់ផលប្រយោជន៍អ្វីខ្លះ?

៤. ក្នុងនាមប្អូនជាសិស្ស និងជាពលរដ្ឋខ្មែរមួយរូប តើប្អូនត្រូវធ្វើដូចម្ដេចខ្លះក្នុងការចូលរួមប្រឡងប្រណាំងទីក្រុងស្អាត?

# សំណល់ប្លាស្ទិច និងបរិស្ថាន

**(ទ្រឹស្តី២ម៉ោង អនុវត្ត២ម៉ោង)**

### *សិក្សាមេរៀននេះចប់សិស្សអាចៈ*

- យល់ដឹងអំពីអ្វីជាសំណល់ប្លាស្ទិច និងផលប៉ះពាល់សំណល់ប្លាស្ទិចលើបរិស្ថាន
- យល់ដឹងអំពីដំណោះស្រាយ ចំពោះបញ្ហាសំណល់ប្លាស្ទិចតាមរយៈគោលការណ៍3Rៈ ការកាត់បន្ថយ ការប្រើប្រាស់ឡើងវិញ និងការកែច្នៃ
- យល់ដឹងអំពីវិធីសាស្ត្រកាត់បន្ថយសំណល់ប្លាស្ទិច ។

បច្ចុប្បន្នបញ្ហាបរិស្ថាន ជាបញ្ហាប្រឈមដ៏ស្មុគ្រស្មាញមួយ ដែលពិភពលោកកំពុងជួបប្រទះ។ បញ្ហាបរិស្ថាននេះ បង្កឡើងមួយចំណែកធំពីសកម្មភាពមនុស្សដោយផ្ទាល់ និងដោយប្រយោល តាមរយៈសកម្មភាពឧស្សាហកម្ម ពាណិជ្ជកម្ម ទីផ្សារ និងការប្រើប្រាស់ក្នុងជីវភាពប្រចាំថ្ងៃបង្កឱ្យមានការកើនឡើងនៃសំណល់។ សំណល់ទាំងនោះមួយភាគធំជាប្រភេទសំណល់ផលិតផលប្លាស្ទិច ពិសេសថង់ប្លាស្ទិចដែលបាននឹងកំពុងបង្កផលប៉ះពាល់ និងគំរាមកំហែងដល់បរិស្ថាន ក៏ដូចជាជីវភាពរស់នៅប្រចាំថ្ងៃរបស់មនុស្ស សត្វ និងជីវៈចម្រុះយ៉ាងធ្ងន់ធ្ងរ។

បញ្ហាសំណល់ពិសេសថង់ប្លាស្ទិចជាបញ្ហារបស់យើងទាំងអស់គ្នា។ ដើម្បីឆ្លើយតបនឹងបញ្ហាទាំងនេះ គណៈកម្មាធិការជាតិវាយតម្លៃទីក្រុងស្អាត បានរៀបចំជាយុទ្ធសាស្ត្រនានា និងវិធានការណ៍ផ្សេងៗក្នុងការដាក់ចេញនូវយុទ្ធនាការ "ទីក្រុងស្អាតគឺជាទីក្រុងដែលគ្មានសំរាមជាថង់ប្លាស្ទិចហើរតាមខ្យល់" ដែលជាការគាំទ្រ និងបង្កើនការយកចិត្តទុកដាក់បន្ថែម នៃបញ្ហាបរិស្ថាននេះផងដែរ ដោយសំដៅជំរុញការអនុវត្តផែនការយុទ្ធសាស្ត្រនេះ ឱ្យកាន់តែមានប្រសិទ្ធភាពក្នុងការកាត់បន្ថយបរិមាណសំណល់កុំឱ្យកើនឡើងឥតឈប់ឈរក្នុងបរិស្ថាន។

## ១. ផលប៉ះពាល់សំណល់ប្លាស្ទិចចំពោះបរិស្ថាន

សព្វថ្ងៃគេឃើញសំណល់ប្លាស្ទិចនៅរាយប៉ាយតាមដងផ្លូវ ឬនៅតាមទីវាល ជួនកាលទើរនៅតាមមែកឈើ ដែលធ្វើឱ្យមានផលប៉ះពាល់ដល់សោភណភាព។ ម្យ៉ាងទៀតសំណល់ប្លាស្ទិចជាវត្ថុដែលមិនរលាយក្នុងទឹក ធ្វើឱ្យស្ទះចរន្តទឹកហូរ ហើយបង្កជាទឹកជំនន់ និងបណ្តាលឱ្យហេដ្ឋារចនាសម្ព័ន្ធសាធារណៈខូចខាតទាំងស្រុង រួមទាំងផ្តល់ផលប៉ះពាល់យ៉ាងធ្ងន់ធ្ងរដល់បរិស្ថាន និងចុងក្រោយគេយកសំណល់ប្លាស្ទិចទាំងនោះទៅចាក់ជាគំនរ នៅទីលានផ្ទុកសំណល់ ដែលទាមទាររយៈពេលប្រហែលប្រមាណជា១០០០ឆ្នាំ ដើម្បីរលាយ ហើយធ្វើឱ្យទឹក និងដីរងការពុលយ៉ាងធ្ងន់ធ្ងរ។

សំណល់ប្លាស្ទិចបង្កឱ្យមានផលប៉ះពាល់ដូចតទៅៈ

### ១.១. ចំពោះបរិស្ថានស្តុកសំណល់

ដោយការកែច្នៃសំណល់ប្លាស្ទិច ដើម្បីប្រើប្រាស់ឡើងវិញនៅមានកម្រិត។ ដូចនេះសំណល់ប្លាស្ទិចភាគច្រើនគេយកទៅចាក់គរនៅតាមទីលានផ្ទុកសំណល់ ដែលនាំឱ្យតម្រូវការទំហំនៃទីលានកាន់តែធំ និងនាំឱ្យមានការប្រើប្រាស់ទីលានផ្ទុកសំរាមមិនមាននិរន្តរភាពផងដែរ។

### ១.២. ចំពោះទឹក

សំណល់ប្លាស្ទិចជាសារធាតុមិនរលាយក្នុងទឹក វាអណ្តែតនៅក្នុងទឹក ឬហូរទៅតាមចរន្តទឹក ដែលអាចបង្កឱ្យមានការរាំងស្ទះដល់ផ្លូវទឹក ហើយបង្កជាគ្រោះទឹកជំនន់។ ម៉្យាងទៀត ការចាក់ ឬបង្ហូរសំរាមដែលមានសំណល់ប្លាស្ទិចទៅក្នុងសមុទ្រ វានឹងរាំងស្ទះដល់ចរាចររបស់មនុស្ស និងសត្វសមុទ្រ។ មួយវិញទៀត សត្វសមុទ្រទាំងនោះអាចនឹងស៊ីសំណល់ប្លាស្ទិច ដែលបណ្តាលឱ្យងាប់បានយ៉ាងងាយ។ ម៉្យាងទៀត សំណល់ប្លាស្ទិចរាំងពន្លឺព្រះអាទិត្យ មិនឱ្យចាំងចូលដល់បាតសមុទ្របាន ដែលជាមូលហេតុធ្វើឱ្យរុក្ខជាតិដែលដុះលូតលាស់នៅបាតសមុទ្រនោះងាប់ផងដែរ ព្រោះរុក្ខជាតិបៃតងត្រូវការពន្លឺព្រះអាទិត្យសម្រាប់ផលិតអាហារចិញ្ចឹមខ្លួនឯង និងបញ្ចេញឧស្ម័នអុកស៊ីសែន សម្រាប់ដំណើរដង្ហើមរបស់សត្វ ដទៃទៀត ដែលរស់នៅក្នុងមជ្ឈដ្ឋាននោះ តាមដំណើររស្មីសំយោគ។ ដូចនេះ បើគ្មានពន្លឺព្រះអាទិត្យទេនោះ ក៏គ្មានដំណើររស្មីសំយោគដែរ ធ្វើឱ្យរុក្ខជាតិមិនអាចផលិតអាហារបានសម្រាប់ចិញ្ចឹមខ្លួន និងមជ្ឈដ្ឋានដែលសត្វរស់នៅគ្មានអុកស៊ីសែនសម្រាប់ដកដង្ហើម ដែលជាមូលហេតុធ្វើឱ្យរុក្ខជាតិ និងសត្វងាប់បាន។

### ១.៣. ចំពោះសត្វ

ការចោលសំណល់ប្លាស្ទិចនៅទីលានចាក់សំរាមតាមស្ទឹង បឹង ទន្លេ និងសមុទ្រ គឺជាមូលហេតុចម្បងធ្វើឱ្យសត្វងាប់ព្រោះសត្វទាំងនោះស៊ីសំណល់ប្លាស្ទិចជាអាហារ ដើម្បីចិញ្ចឹមជីវិតដែលបង្កឱ្យសត្វងាប់បាន។ ជារៀងរាល់ឆ្នាំមានត្រី និងបក្សីរាប់លានក្បាលងាប់ដោយសារការស៊ីសំណល់ប្លាស្ទិចធ្វើឱ្យប្រព័ន្ធរំលាយអាហាររបស់សត្វមិនអាចដំណើរការបាន។

### ១.៤. ចំពោះមនុស្ស

ប្លាស្ទិចភាគច្រើនផលិតពីសារធាតុគីមីពុល ដែលធ្វើឱ្យមានការប៉ះពាល់យ៉ាងខ្លាំងដល់សុខភាពរបស់មនុស្ស។ ប្លាស្ទិចភាគច្រើនផលិតចេញពីសារធាតុ "ប៉ូលីអេទីឡែន" និងជាតិពណ៌របស់ប្លាស្ទិចជ្រាបចូលទៅក្នុងអាហារ ហើយបង្កគ្រោះថ្នាក់ដល់សុខភាពរបស់មនុស្ស នៅពេលដែលគេធ្វើការវេចខ្ចប់។ លើសពីនេះផងដែរ សារធាតុគីមីដែលមាននៅក្នុងប្លាស្ទិចធ្វើឱ្យសែន របស់មនុស្សប្រែប្រួល ហើយក្រូម៉ូសូមត្រូវបានបំផ្លាញ ព្រមទាំងធ្វើឱ្យស្ត្រីសម្រាលកូនមុនពេលកំណត់ រលូតកូន ហើយកុមារលូតលាស់ឆាប់រហ័សខុសប្រក្រតី។ ចំពោះទារកវិញជាតិគីមីអាចបញ្ហាឱ្យខូចប្រព័ន្ធភាពស៊ាំនៃរាងកាយ ហើយចុះខ្សោយដែលងាយស្រួលក្នុងការឆ្លងជំងឺផ្សេងៗ។

## ២. ដំណោះស្រាយចំពោះបញ្ហាសំណល់ប្លាស្ទិច

បញ្ហាសំណល់ប្លាស្ទិចជាបញ្ហាប្រឈមចំពោះប្រទេសកម្ពុជានាពេលបច្ចុប្បន្ននេះ ព្រោះរាល់ទំនិញ ឬវត្ថុទាំងឡាយសុទ្ធតែប្រើប្រាស់សារធាតុប្លាស្ទិចដើម្បីវេចខ្ចប់។ ដូចនេះ បរិមាណនៃសំណល់ប្លាស្ទិចមានការកើនឡើងយ៉ាងឆាប់រហ័សដែលជាផលប៉ះពាល់យ៉ាងធ្ងន់ធ្ងរទៅលើបរិស្ថាន។

គោលការណ៍សម្រាប់ដោះស្រាយចំពោះបញ្ហាសំណល់ប្លាស្ទិចមានដូចតទៅ៖

### ២.១. គោលការណ៍កាត់បន្ថយ

កាត់បន្ថយការប្រើប្រាស់សារធាតុប្លាស្ទិចសម្រាប់ការវេចខ្ចប់(ថង់ ប្រអប់ កំប៉ុង ដប។ល។)ជំនួសដោយសារធាតុសរីរាង្គ(ស្លឹកចេក ស្លឹកឈូក ខ្សែ។ល។)ឬប្រើប្រាស់កំប្រោង ថង់សំពត់សម្រាប់ទៅផ្សារ។ ការកាត់បន្ថយការប្រើប្រាស់សារធាតុប្លាស្ទិចមានន័យថាយើងបន្ថយសំណល់ប្លាស្ទិចក្នុងគំនរសំរាម។

### ២.២. គោលការណ៍ប្រើប្រាស់ឡើងវិញ

ថង់ ឬដបប្លាស្ទិចមួយភាគធំដែលបានបោះចោល ដោយការប្រើប្រាស់បានត្រឹមតែមួយដង គឺជាការប្រើប្រាស់ថង់ ឬដបប្លាស្ទិចពុំអស់លទ្ធភាព។ យើងអាចយកថង់ ឬដបប្លាស្ទិចដែលនៅល្អ ស្អាតមកប្រើប្រាស់ឡើងវិញបាន រហូតដល់ពេលដែលអ្នកយល់ថា វាអស់លទ្ធភាព។ ការអនុវត្តបែបនេះអាចជួយកាត់បន្ថយការចំណាយរបស់យើងទៅលើការទិញថង់ប្លាស្ទិចផងដែរ។

### ២.៣. គោលការណ៍កែច្នៃឡើងវិញ

ការកែច្នៃសំណល់ប្លាស្ទិចដែលយើងគិតថា មិនអាចប្រើប្រាស់វាបន្តទៀតបាននោះ យកមកច្នៃប្រឌិតឡើងវិញជាវត្ថុសិល្បៈ ឬវត្ថុតាំងលម្អផ្សេងៗទៀត ឬប្រមូលសំណល់ប្លាស្ទិចដែលអាចកែច្នៃបានលក់ឱ្យអ្នកប្រមូលទិញសំណល់ផ្សេងៗ។

ដូចនេះយើងទាំងអស់គ្នាត្រូវចូលរួមកាត់បន្ថយសារធាតុប្លាស្ទិចដោយ៖

- កាត់បន្ថយការវេចខ្ចប់រាល់ពេលដែលយើងទិញសម្ភារៈថ្មីៗ
- គួរតែប្រើប្រាស់ថង់ដែលផលិតពីសំពត់ ឬកំប្រោងជំនួសការប្រើប្រាស់ថង់ប្លាស្ទិច
- អាចរក្សាទុកថង់(ឬដប កំប៉ុង)ប្លាស្ទិចដែលនៅល្អស្អាត ទុកប្រើប្រាស់ឱ្យអស់លទ្ធភាព
- រួមគ្នាប្រើប្រាស់ថង់បរិស្ថាន
- កែច្នៃសំណល់ប្លាស្ទិចឱ្យទៅជាវត្ថុប្រើប្រាស់ផ្សេងៗឡើងវិញ
- ចូលរួមអនុវត្តគោលការណ៍ទាំងបីខាងលើគឺការកាត់បន្ថយ ការប្រើប្រាស់ឡើងវិញ និងការកែច្នៃឡើងវិញនៃសារធាតុប្លាស្ទិច
- ផ្សព្វផ្សាយដល់ក្រុមហ៊ុន សហគ្រាសនានាក្នុងការលើកទឹកចិត្តចំពោះអតិថិជនរបស់ខ្លួនឱ្យកាត់បន្ថយការវេចខ្ចប់ដោយថង់ប្លាស្ទិច
- ប្រើប្រាស់ថង់បរិស្ថាន ដើម្បីជួយកាត់បន្ថយការប្រើប្រាស់ថង់ប្លាស្ទិច
- ចៀសវាងការបោះចោលសំណល់ប្លាស្ទិចនៅតាមទីសាធារណៈ ឬតាមទីវាលព្រោះធ្វើឱ្យមានផលប៉ះពាល់ដល់សោភណភាព

- ត្រូវវេចខ្ចប់សំណល់ប្លាស្ទិចដែលប្រើប្រាស់រួចឱ្យបានត្រឹមត្រូវ មុននឹងយកទៅដាក់ក្នុងធុងសំរាម
- កាត់បន្ថយការប្រើប្រាស់ថង់ប្លាស្ទិចដោយប្រើកញ្ចប់ក្រដាសក្នុងការដាក់ឥវ៉ាន់
- ប្រើប្រាស់ស្លឹករុក្ខជាតិដែលមាននៅជុំវិញគេហដ្ឋាន ដូចជាស្លឹកចេក ឬស្លឹកឈូកក្នុងការវេចខ្ចប់ជំនួសឱ្យការប្រើប្រាស់ថង់ប្លាស្ទិច
- ធ្វើការកែច្នៃថង់ប្លាស្ទិចជាវត្ថុសិល្បៈជំនួសឱ្យការបោះចោលនៅទីលានចាក់សំរាម
- លើកទឹកចិត្តដល់ម្ចាស់ភោជនីយដ្ឋាន អាហារដ្ឋាន សណ្ឋាគារក្នុងការប្រើប្រាស់ស្លឹករុក្ខជាតិ ដូចជាស្លឹកចេក ស្លឹកឈូក។ល។ដើម្បីវេចខ្ចប់ម្ហូបអាហារ ក៏ជាការកាត់បន្ថយការប្រើប្រាស់ថង់ប្លាស្ទិចដែរ។



*ថង់ធ្វើពីសំពត់*



*អាហារវេចខ្ចប់ដោយស្លឹកចេក*

**មេរៀនសង្ខេប**

បច្ចុប្បន្នសំណល់ប្លាស្ទិច គឺជាបញ្ហាប្រឈមមួយក្នុងពិភពលោកចំពោះបរិស្ថានក៏ដូចជាជីវភាពប្រចាំថ្ងៃរបស់មនុស្ស សត្វ និងជីវៈចម្រុះ។ ប្លាស្ទិចជាសារធាតុមិនរលាយ និងបង្កការប៉ះពាល់យ៉ាងខ្លាំងដល់បរិស្ថាន និងជីវិត។ ដោយមានការកើនឡើងឥតឈប់ឈរនូវបរិមាណសំណល់ប្លាស្ទិច ក្នុងបរិស្ថាន ដូច្នេះរាជរដ្ឋាភិបាលកម្ពុជា អង្គការ សមាគម និងសង្គមស៊ីវិលជាច្រើនបានខិតខំយកចិត្តទុកដាក់ដល់បញ្ហានេះ ដោយបានធ្វើការផ្សព្វផ្សាយពីផលប៉ះពាល់នៃសំណល់ប្លាស្ទិចចំពោះបរិស្ថាន មនុស្ស សត្វ។ល។

ក្នុងដំណោះស្រាយចំពោះសំណល់ប្លាស្ទិច គណៈកម្មាធិការជាតិវាយតម្លៃទីក្រុងស្អាតបានសហការជាមួយដៃគូពាក់ព័ន្ធបានរៀបចំយុទ្ធសាស្ត្រនានា និងគោលការណ៍ផ្សេងៗ ដោយសំដៅជំរុញឱ្យកាន់តែមានប្រសិទ្ធភាព ដូចជា គោលការណ៍កាត់បន្ថយ គោលការណ៍ប្រើប្រាស់ឡើងវិញ និងគោលការណ៍កែច្នៃឡើងវិញ។

ដូចនេះដើម្បីដោះស្រាយចំពោះបញ្ហាសំណល់ប្លាស្ទិក តម្រូវឱ្យមានការចូលរួមពីយើងអស់គ្នា ទាំងប្រជាពលរដ្ឋ សិស្ស និស្សិត អាជីវករ ប្រតិបត្តិករទេសចរណ៍ ត្រូវមានការផ្លាស់ប្តូរឥរិយាបទ និងការគិតគូអំពីបញ្ហាសំណល់ប្លាស្ទិច តាមរយៈការអនុវត្តគោលការណ៍ 3Rគឺ៖

ទី១ ការកាត់បន្ថយបរិមាណសំណល់

ទី២ ការប្រើប្រាស់ឡើងវិញ

ទី៣ ការកែច្នៃឡើងវិញ។

**"ប្រជាពលរដ្ឋគ្រប់រូបជាម្ចាស់នៃភាពស្អាត និងភាពបៃតងនៅតាមទីក្រុងរបស់ខ្លួន"**

## សំណួរ

**១-** តើសំណល់ប្លាស្ទិចបណ្ដាលឱ្យមានផលប៉ះពាល់ទៅលើអ្វីខ្លះ? ផលប៉ះពាល់យ៉ាងដូចម្ដេច?

**២-** ដើម្បីកុំឱ្យមានការកើនឡើងឥតឈប់ឈរនូវបរិមាណសំណល់ប្លាស្ទិចក្នុងបរិស្ថាន តើយើងត្រូវមានគោលការណ៍អ្វីខ្លះ?ចូរពន្យល់ពីគោលការណ៍នីមួយៗ។

**៣-** ដើម្បីចូលរួមក្នុងការកាត់បន្ថយការប្រើប្រាស់ថង់ប្លាស្ទិច តើយើងត្រូវធ្វើដូចម្ដេចខ្លះ ?

# ឯកសារយោង


- រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា : អនុក្រឹតលេខ១៦ អនក្រ.បក ស្តីពីចំណាត់ថ្នាក់សណ្ឋាគារ និងសេវាកម្មស្នាក់នៅ ចុះថ្ងៃទី១១ ខែមិថុនា ឆ្នាំ២០០៤
- រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា : អនុក្រឹតលេខ១៩១ អនក្រ.បក ស្តីពីមគ្គុទ្ទេសក៍ទេសចរណ៍ ចុះថ្ងៃទី១៧ ខែសីហា ឆ្នាំ២០១១
- រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា : គោលនយោបាយជាតិលើវិស័យទេសចរណ៍នៅព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៨
- ព្រះរាជក្រមលេខ នស/រកម/០៦/០៩/០០៧ ច្បាប់ស្តីពីទេសចរណ៍ ចុះថ្ងៃទី១០ ខែមិថុនា ២០០៩
- ក្រសួងទេសចរណ៍ : ប្រកាសស្តីពីស្តង់ដាអប្បបរមាសម្រាប់រមណីយដ្ឋានទេសចរណ៍ ចុះថ្ងៃទី៥ ខែមីនា ឆ្នាំ២០០៩
- ក្រសួងទេសចរណ៍ : មគ្គុទ្ទេសក៍ទេសចរណ៍តំបន់ភ្នំពេញ និងសៀមរាបអង្គរ ឆ្នាំ២០០៦
- ក្រសួងទេសចរណ៍ : មគ្គុទ្ទេសក៍ទេសចរណ៍តំបន់សៀមរាបអង្គរ ឆ្នាំ២០០៨
- គណៈកម្មាធិការជាតិវាយតម្លៃទីក្រុងស្អាត : ការប្រឡងប្រណាំងទីក្រុងស្អាតផ្តើមចេញពីយើងទាំងអស់គ្នា
- គណៈកម្មាធិការជាតិវាយតម្លៃទីក្រុងស្អាត : សំណល់ប្លាស្ទិក និងបរិស្ថានយើងទាំងអស់គ្នា
- គណៈកម្មាធិការជាតិវាយតម្លៃទីក្រុងស្អាត : របាយការណ៍ស្តីពីដំណើរការរៀបចំវេទិកាការទេសចរណ៍ ២០១១
- សម្តេចព្រះសង្ឃរាជ គណៈមហានិកាយ ជោតញ្ញាណោ ជួន ណាត : វចនានុក្រមខ្មែរ ភាគទី១ និងភាគទី២ ពុទ្ធសាសនបណ្ឌិត្យ បោះពុម្ពលើកទី៥ ១៩៦៧
- ច្រឡឹង សុមេធា : វចនានុក្រមទេសចរណ៍-សណ្ឋាគារ-ភោជនីយដ្ឋាន អង់គ្លេស-ខ្មែរ បោះពុម្ពលើកទី៣ ២០០៨
- ច្រឡឹង សុមេធា - វ៉ាត វ៉ាន់វីរៈ : ទេសចរណ៍ បោះពុម្ពលើកទី៣ ២០០៨
- ច្រឡឹង សុមេធា : មគ្គុទ្ទេសក៍ទេសចរណ៍ បោះពុម្ពលើកទី៣ ២០១១
- ច្រឡឹង សុមេធា - យ៉ែម ច័ន្ទរិទ្ធ - វ៉ាត វ៉ាន់វីរៈ : ការគ្រប់គ្រងភោជនីយដ្ឋាន បោះពុម្ពលើកទី៣ ឆ្នាំ២០១១
- ច្រឡឹង សុមេធា - វ៉ាត វ៉ាន់វីរៈ - ហ៊ោយ ភិរក្ស : ឥទ្ធិពលទេសចរណ៍ បោះពុម្ពលើកទី១ ២០១២
- ច្រឡឹង សុមេធា - យ៉ែម ច័ន្ទរិទ្ធ - វ៉ាត វ៉ាន់វីរៈ : ដំណើរការសណ្ឋាគារ បោះពុម្ពលើកទី៣ ឆ្នាំ២០១១
- បណ្ឌិត គឹម ប៊ុនណារ៉ា - បណ្ឌិត ឯក រដ្ឋា - ឯម ខេឌី - សាំង ចន្ធូ : អេកូទេសចរណ៍
- រ៉ា ស៊ីហេង - ស៊ុំ សុចិន្តា - ហុង វណ្ណៈ : អេកូទេសចរណ៍

- កែវ ភួង : តំបន់ទេសចរណ៍នៃព្រះរាជាណាចក្រកម្ពុជា
- បណ្ឌិត សួន វ៉ានី - ស៊ុត តារា - យិន ច័ន្ទសុធី : ទេសចរណ៍ បច្ចេកទេស និងសហប្រតិបត្តិការអាជីវកម្ម
- បណ្ឌិត សួន វ៉ានី - ជីវ សុងហាក់ - ទឹម សុធា : ទីភ្នាក់ងារទេសចរណ៍ ការប្រតិបត្តិការខ្សែទស្សនកិច្ច និងដំណើរកម្សាន្ត
- បណ្ឌិត សួន វ៉ានី : សញ្ញាណ និងទ្រឹស្តីទេសចរណ៍ ២០០២
- បណ្ឌិត សួន វ៉ានី - ខូវ ណៃឡេង : ប្រតិបត្តិការដំណើរទេសចរណ៍ និងខ្សែទស្សនកិច្ច ២០១៣
- បណ្ឌិត សួន វ៉ានី : គ្រប់គ្រងទីភ្នាក់ងារទេសចរណ៍ ២០១២
- បណ្ឌិត សួន វ៉ានី - បណ្ឌិត សួន នាងឆវី - ណុប ច័ន្ទ : សិល្បៈទំនាក់ទំនង និងបដិសណ្ឋារកិច្ចឆ្នាំ២០១២
- យិន សូរិយា : ផ្សព្វផ្សាយទីផ្សារទេសចរណ៍ ២០០៨
- យិន សូរិយា - ម៉ែន ប្រាជ្ញវុឌ្ឍី - អាន់ ម៉ារីយ៉ាម៉ាក់ខេណា : ទេសចរណ៍សហគមន៍ ទស្សនទាន និងដំណើរការ ២០០៩
- យិន សូរិយា - បណ្ឌិត ត្រៃវើស្វ ហៀល - អាលីសុន រ៉ូសេតូ : ផ្សព្វផ្សាយការយល់ដឹងពីទេសចរណ៍សហគមន៍ ២០០៧
- ហែម សោភ័ន្ត : មគ្គុទ្ទេសក៍ទេសចរណ៍ប្រកបដោយអាជីពវិជ្ជាជីវៈ។